**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

**សារណាបញ្ចប់ការសិក្សា**

# នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

( ស្រាវជ្រាវចាប់ពីថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០២៤ ដល់ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០២៤ )


ស្រាវជ្រាវដោយ ៖

និស្សិតឈ្មោះ កញ្ញា **ប៊ុន ស្រីម៉ត់**

កញ្ញា **អៀង មរកត**

ណែនាំដោយ

លោក **តា សុន្ធា**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២៤

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរសារណា ២០២៤

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

**សារណាបញ្ចប់ការសិក្សា**

# នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

( ស្រាវជ្រាវចាប់ពីថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០២៤ ដល់ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០២៤ )

ស្រាវជ្រាវដោយ ៖

និស្សិតឈ្មោះ កញ្ញា **ប៊ុន ស្រីម៉ត់**

កញ្ញា **អៀង មរកត**

ណែនាំដោយ

លោក **តា សុទ្ធា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២៤

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរសារណា ២០២៤

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **ម៉ុន ស្រីម៉ត់** និងឈ្មោះ **អៀង មរកត** ជានិស្សិតផ្នែកបរិញ្ញាបត្រច្បាប់ ជំនាន់ទី២៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា២០២០-២០២៤។

សូមធ្វើការសម្តែងនូវការកត្តញ្ញូ និងការដឹងគុណដ៏ជ្រាលជ្រៅបំផុតចំពោះ៖

លោក អ្នកមានគុណទាំងពីររូប ដែលបានផ្តល់នូវកំណើត និងចិញ្ចឹមបីបាច់ថែរក្សា ព្រមទាំងលះបង់នូវកម្លាំងកាយ និងកម្លាំងចិត្ត លះបង់គ្រប់យ៉ាង ដើម្បីឱ្យយើងខ្ញុំទាំងពីរអាចមានឱកាសក្នុងការសិក្សារៀនសូត្រ តាំងពីថ្នាក់មត្តេយ្យ រហូតដល់ថ្នាក់បរិញ្ញាត្រ។ លោកទាំងពីរ បានចូលរួមចំណែកក្នុងការផ្តល់នូវកម្លាំងចិត្ត ទំនុកបម្រុងគ្រប់សព្វបែបយ៉ាង និងការទូន្មានប្រៀនប្រដៅប្រកបដោយព្រហ្មវិហារធម៌ ក្នុងគោលបំណងចង់ឱ្យយើងខ្ញុំអាចក្លាយទៅជា កូនល្អ សិស្សល្អ និងជាសសរទ្រូងនៃប្រទេសជាតិ។ ក្នុងនាមពួកខ្ញុំជាកូនៗគ្មានអ្វីអាចតបស្នងសងគុណដ៏ធំមួយនេះបានទេ ដូច្នេះហើយពួកខ្ញុំមានតែការខិតខំប្រឹងប្រែងសិក្សារៀនសូត្រ ឱ្យអស់ពីកម្លាំងកាយ និងចិត្ត ដើម្បីអាចបំពេញនូវបំណង និងឱ្យសាកសមនូវការលះបង់របស់លោកទាំងពីរ។ យើងខ្ញុំសង្ឃឹមថាលោកទាំងទ្វេរនឹងត្រេកអរ សប្បាយចិត្តជាមួយនឹងការខិតខំប្រឹងប្រែងក្នុងការសិក្សារបស់យើងខ្ញុំអស់រយៈពេលជាច្រើនឆ្នាំមកនេះ។

ឯកឧត្តម សាកលវិទ្យាល័យធិការ សាកលវិទ្យាល័យធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរស-រង ប្រធានការិយាល័យ អនុប្រធានការិយាល័យ និងលោក លោកស្រី សាស្ត្រាចារ្យ ទាំងអស់នៃ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានផ្តល់ឱកាសឱ្យយើងខ្ញុំទាំងពីររូបបានចូលសិក្សាទទួលនូវចំណេះដឹង និងបង្ហាត់បង្ហាញ តាមរយៈការបង្រៀនយ៉ាងចិត្តទុកដាក់ អស់ពីកម្លាំងកាយ និងចិត្ត ចំពោះផ្នែកនីតិសាស្ត្រ អស់រយៈពេល៤ឆ្នាំមកនេះ។

លោកគ្រូ **តា សុទ្ធា** ដែលបានណែនាំយើងខ្ញុំ ក្នុងការសរសេរចងក្រងសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រនេះផងដែរ ដែលបានចំណាយពេលដ៏មានតម្លៃ ដើម្បីធ្វើការបង្ហាត់បង្ហាញអស់ពីកម្លាំងកាយ កម្លាំងចិត្ត និងណែនាំកែតម្រូវផ្តល់នូវចំណេះដឹងយ៉ាងច្រើន ក៏ដូចជាផ្តល់ជាប្រសាសន៍ និងតម្រង់ទិសដៅ អោយយើងខ្ញុំក្នុងការបង្កើតកិច្ចការស្រាវជ្រាវបានជោគជ័យ។

ជាចុងបញ្ចប់ យើងខ្ញុំសូមបួងសួងទៅដល់វត្ថុស័ក្តសិទ្ធិទាំងអស់ក្នុងលោក ជួយថែរក្សាការពារ និងប្រសិទ្ធពរជ័យជូនដល់អស់លោកទាំងអស់ ជួបតែសេចក្តីចម្រើន សុខភាពល្អ អាយុយឺនយូរ និង ទទួលបានជោគជ័យគ្រប់ភារៈកិច្ចនិងជួបតែពុទ្ធិពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

បន្ទាប់ពីឆ្លងកាត់ការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ អស់រយៈ០៤ឆ្នាំ នៅ **សាកលវិទ្យា-ល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** នូវមុខវិជ្ជាជាច្រើនដែលទាក់ទងទៅនឹងវិស័យច្បាប់នៅក្នុង ព្រះរាជាណាចក្រកម្ពុជា យ៉ាងទូលំទូលាយ ប្រកបដោយភាពច្បាស់លាស់ ក្រោមការយកចិត្តទុកដាក់យ៉ាងខ្ពង់ខ្ពស់ពីសំណាក់ លោកគ្រូ អ្នកគ្រូ និងសាស្ត្រាចារ្យនានា និង ដោយមានការបង្ហាត់បង្ហាញអស់ពីកម្លាំងកាយចិត្ត និងជួយជ្រោមជ្រែង ទើបធ្វើឱ្យយើងខ្ញុំអាចឈានដល់ការចងក្រងសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាន់ទី២៤ និងដើម្បីចូលរួមជាចំណែកក្នុងការចែករំលែកនូវចំណេះដឹងដល់និស្សិតជំនាន់ក្រោយផង។

សម្រាប់ការសរសេរសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រនេះ យើងខ្ញុំបានសម្រេចចិត្តជ្រើសរើសយកប្រធានបទមួយដែលទាក់ទងនៅក្នុងដំណាក់កាលមួយនៃនីតិវិធីជម្រះក្តីលើកទីមួយ នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ដែលមានប្រធានបទ **នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល**។ ការជ្រើសរើសប្រធានបទនេះ គឺមានគោលបំណងចង់ឱ្យអ្នកសិក្សា អ្នកស្រាវជ្រាវ និងនិស្សិតជំនាន់ក្រោយ អាចយល់កាន់តែច្បាស់អំពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដែលជាដំណាក់កាលមួយដែលសំខាន់ក្នុងការដោះស្រាយរឿងក្តីរដ្ឋប្បវេណី នៅក្នុងប្រព័ន្ធតុលាការ។

យើងខ្ញុំសង្ឃឹមថា សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រនេះ អាចជាជំនួយ ជួយសម្រួលដល់ការសិក្សា និងស្រាវជ្រាវ ដល់អ្នកសិក្សា អ្នកស្រាវជ្រាវ និងនិស្សិតជំនាន់ក្រោយ ជាពិសេសនិស្សិតដែលកំពុងសិក្សាបរិញ្ញាបត្រនីតិសាស្ត្រឆ្នាំទី៤ ដែលសិក្សាមុខវិជ្ជានីតិវិធីរដ្ឋប្បវេណីស្រាប់ អាចឱ្យស្វែងយល់កាន់តែច្បាស់បន្ថែមទៀត បន្ថែមពីនេះទៀត យើងខ្ញុំក៏ចង់បន្សល់ទុកនូវស្នាដៃមួយសម្រាប់ជាការចងចាំមួយដែលមិនអាចបំភ្លេចបាន ក្នុងនាមយើងខ្ញុំជានិស្សិតដែលធ្លាប់បានសិក្សា និងបណ្តុះបណ្តាល ផ្នែកនីតិសាស្ត្រនៅ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច នេះផងដែរ។

យើងខ្ញុំក៏សូមការអធ្យាស្រ័យទុកជាមុននូវរាល់កំហុសខុសឆ្គងប្រការណាមួយដែលកើតមានឡើងដោយអចេតនានូវពាក្យពេចន៍ក៏ដូចជាអក្ខរាវិរុទ្ធទាំងឡាយដែលមាននៅក្នុងសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រមួយនេះ ហើយយើងខ្ញុំរីករាយស្វាគមន៍ទទួលរាល់មតិរិះគន់ក្នុងន័យស្ថាបនាចំពោះចំណេះដឹងរបស់យើងខ្ញុំដើម្បីបំពេញចំណុចខ្វះខាតរបស់យើងខ្ញុំទាំងអស់មកជាល្អគ្រប់ជ្រុងជ្រោយវិញ។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម**.....................................................................................................១

**ជំពូកទី១**

**សញ្ញាណទូទៅនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល**

**១.១ និយមន័យ និងសារប្រយោជន៍នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល**...៣

១.១.១ និយមន័យ.....................................................................................៣

១.១.២ សារៈប្រយោជន៍នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល....................................៣

១.១.៣ គោលបំណងនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល........................................៤

**១.២ គោលការណ៍ទូទៅ នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល**....................៤

១.២.១ គោលការណ៍ចំពោះមុខ.........................................................................៤

១.២.២ គោលការណ៍អសាធារណៈ.....................................................................៥

**១.៣ សិទ្ធិអំណាចតុលាការ និងភាគី**...........................................................៥

១.៣.១ សិទ្ធិអំណាចរបស់តុលាការ ក្នុងការដឹកនាំនីតិវិធីបណ្តឹង...............................៥

១.៣.២ សិទ្ធិអំណាចរបស់ភាគីនៅក្នុងបណ្តឹង...........................................................៦

១.៣.៣ ការទទួលខុសត្រូវរបស់តុលាការ និង ភាគី.....................................................៦

**១.៤ ភាសាដែលប្រើក្នុងតុលាការ សិទ្ធិរបស់ភាគីក្នុងការស្នើសុំឱ្យមានអ្នកបកប្រែ**..៦

**ជំពូកទី២**

**ដំណើរការនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល**

**២.១ សកម្មភាពរបស់តុលាការនិងភាគីនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផ.**៨

២.១.១ សកម្មភាពតុលាការ..............................................................................៨

២.១.១.១ កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល...............................៨

២.១.១.២ ការសាកល្បងផ្សះផ្សា.....................................................................៩

២.១.១.៣ ករណីការផ្សះផ្សាមិនបានសម្រេច.........................................................១០

២.១.១.៤ ដីកាសម្រេចដែលមិនមែនជាសាលក្រម.....................................................១៩

២.១.២ សកម្មភាពភាគី ........ ២១
២.១.២.១ ដើមចោទ ........ ២២
២.១.២.២ ចុងចម្លើយ ........ ២៣
២.១.២.៣ ពេលវេលាដែលត្រូវដាក់មធ្យោបាយតទល់ ឬការពារខ្លួន ........ ២៣
២.១.២.៤ ការដកពាក្យបណ្ដឹងរបស់ភាគី ........ ២៥
**២.២ កំណាត់ហេតុស្ដីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល** ........ ២៦
២.២.១ ចំណុចជារូបមន្តនៃកំណត់ហេតុស្ដីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ........ ២៧
២.២.២ ចំណុចសារធាតុនៃកំណត់ហេតុស្ដីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ........ ២៧
២.២.៣ ការប្ដឹងតវ៉ាចំពោះសេចក្ដីកកត់ត្រានៃកំណត់ហេតុ ........ ២៨
**២.៣ សមត្ថកិច្ចដឹកនាំនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល** ........ ២៨

# ជំពូកទី៣

# ការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

**៣.១ សកម្មភាពដែលត្រូវបំពេញនៅពេលបញ្ចប់ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល** ........ ២៩
៣.១.១ ការបញ្ជាក់អំពីអង្គហេតុដែលត្រូវបំភ្លឺ ........ ២៩
៣.១.២ ការកំណត់កាលបរិច្ឆេទលើកទីមួយនៃការទាញហេតុផលដោយផ្ទាល់មាត់ ........ ២៩
**៣.២ អានុភាពនៃការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល** ........ ២៩
៣.២.១ ការលើកចោលមធ្យោបាយតទល់ ឬការពារខ្លួនថ្មី ........ ៣០
៣.២.២ ករណីលើកលែងចំពោះការដាក់មធ្យោបាយទល់ ឬការពារខ្លួនថ្មី ........ ៣០
**សេចក្ដីសន្និដ្ឋាន** ........ ៣២
**អនុសាសន៍** ........ ៣៤
**ឯកសារយោង**
**បញ្ជីឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

ស្ថាប័នតុលាការ ជាស្ថាប័នឯករាជ្យដែលមានយុត្តាធិការដាច់ដោយឡែកពីស្ថាប័នពីរផ្សេងទៀតរបស់រដ្ឋ គឺស្ថាប័ននីតិបញ្ញត្តិ និងនីតិប្រតិបត្តិ។ ហើយប្រព័ន្ធតុលាការជាស្ថាប័នដែលមានភាព អាព្យាក្រឹតបំផុតសម្រាប់បម្រើភាពខ្វះចន្លោះប្រហោងរបស់ច្បាប់។ នីតិវិធីជំនុំជម្រះរឿងក្តីរដ្ឋប្បវេណី គឺជានីតិវិធីមួយដ៏សំខាន់ ដែលនាំឱ្យវិវាទអាចទទួលបានចំណាត់ការពីតុលាការ។ ម៉្យាងទៀតការជំនុំជម្រះរបស់តុលាការ គឺជាមធ្យោបាយស្របច្បាប់មួយដែលអាចផ្តល់ភាពយុត្តិធម៌ដល់ជនស្លូតត្រង់ដែលត្រូវគេបំពានសិទ្ធិ ដូច្នេះ ការដំណើរការនៃការជំនុំជម្រះនេះត្រូវធ្វើទៅតាមនីតិវិធីដែលច្បាប់បានកំណត់ ចៀសវាងការជំនុំជម្រះដែលធ្វើទៅតាមទំលាប់ ឬធ្វើទៅតាមការយល់ឃើញរបស់តុលាការ ដែលជាហេតុអាចនាំឱ្យមានភាពលម្អៀង គ្មានភាពយុត្តិធម៌ និងគ្មានសមភាពរវាងភាគីនៃបណ្តឹង ជាពិសេសគឺអំពើពុករលួយនឹងអាចកើតឡើងដោយបើកចំហ ប្រសិនបើពុំមាននីតិវិធីសម្រាប់ការគ្រប់គ្រងដល់ដំណើរការជម្រះក្តីរបស់តុលាការ។ ក្រមនីតិវិធីរដ្ឋប្បវេណី គឺជាបទដ្ឋានមួយដែលកំណត់អំពីបែបបទដែលតុលាការ ក៏ដូចជាភាគី នៃរឿងក្តីត្រូវប្រតិបត្តិតាមនៅក្នុងដំណើរការនៃការដោះស្រាយវិវាទផ្នែករដ្ឋប្បវេណី។ ជាទូទៅ ក្នុងករណីដែលមានវិវាទរដ្ឋប្បវេណីកើតមានឡើង គូភាគីមានមានសិទ្ធិក្នុងការជ្រើសរើសការដោះស្រាយវិវាទនោះនៅក្រៅប្រព័ន្ធតុលាការបាន ពោលគឺភាគីអាចមានជម្រើសក្នុងការជ្រើសរើសការដោះស្រាយវិវាទ រដ្ឋប្បវេណីនៅក្រៅប្រព័ន្ធតុលាការ និងក្នុងប្រព័ន្ធតុលាការ។

នៅពេលដែលពាក្យបណ្តឹងបានចូលទៅដល់តុលាការ តុលាការនឹងចាប់ផ្តើមចាត់ចែងនូវពាក្យបណ្តឹង និងដំណើរការនីតិវិធី តាំងពីការពិនិត្យពាក្យបណ្តឹង រហូតដល់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ដើម្បីចេញនូវសាលក្រម។ ប៉ុន្តែមុននឹងឈានដល់ការទាញហេតុផលដោយផ្ទាល់មាត់ គឺត្រូវធ្វើការឆ្លងកាត់នូវដំណាក់កាលមួយជាមុនសិនគឺ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដែលធ្វើឡើងក្នុងគោលបំណង រៀបចំការអះអាងរបស់ភាគី កំណត់នូវចំណុចវិវាទ និងរៀបចំភស្តុតាង ដើម្បីត្រៀមសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់។ លើសពីនេះទៅទៀត ដំណាក់កាលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល អាចបញ្ចប់វិវាទរវាងភាគីបានក្នុងករណីដែលភាគីមានបំណងចង់ផ្សះផ្សាគ្នា ដោយហេតុថាមិនចង់បន្តនីតិវិធីតទៅទៀត។ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដែលជាទូទៅ គឺធ្វើឡើងក្នុងចំនួន ២ដង ឬ ៣ដង រហូតតុលាការអាចកំណត់នូវចំណុចវិវាទនៃបណ្តឹងបាន ទើបចៅក្រមសម្រេចឱ្យភាគីភាគីធ្វើការដាក់នូវភស្តុតាង និងធ្វើការកំណត់កាលបរិច្ឆេទទាញហេតុផលដោយផ្ទាល់មាត់។ ដោយមើលឃើញពីសារៈសំខាន់នៃដំណាក់កាល នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ទើបសារណាបញ្ចប់ការសិក្សាស្តីពី នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ត្រូវបានចងក្រងឡើង ក្នុងគោលបំណងចង់ ពង្រឹង និងពង្រីក និងចែករំលែកនូវចំណេះដឹង អំពីដំណាក់កាលមួយនេះឱ្យបានកាន់តែច្បាស់ និងបញ្ជាក់ច្បាស់ពីដំណាក់

កាលនីមួយៗដែលមាននៅក្នុង នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដើម្បីឱ្យការសិក្សា និងការស្រាវជ្រាវ កាន់តែមានភាពងាយស្រួល និងច្បាស់លាស់។

ដើម្បីជាជំនួយក្នុងការសិក្សា ស្រាវជ្រាវឱ្យបានស៊ីជម្រៅអំពី នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលថា តើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល មានសារៈសំខាន់ដូចម្ដេចខ្លះនៅក្នុងនីតិវិធីជំនុំជម្រះលើកទី១ នៃរឿងក្ដីរដ្ឋប្បវេណី? តើនៅដំណាក់កាលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដំណើរការទៅដោយរបៀបណាខ្លះ? និងមានអានុភាពនៅពេលណា?

ជាការឆ្លើយតប ទៅនឹងបញ្ហាចំណោទគតិយុត្តដែលបានចោទខាងលើ និងដើម្បីធ្វើការសិក្សាស្រាវជ្រាវឱ្យបានស៊ីជម្រៅ និងគ្រប់ជ្រុងជ្រោយ ហើយច្បាស់លាស់ យើងខ្ញុំបានធ្វើការបែងចែកសារណាបញ្ចប់ការសិក្សានេះជា ០៣ (បី) ជំពូកធំៗដែលក្នុងនោះរួមមានដូចជា៖

**ជំពូកទី១៖ សញ្ញាណទូទៅនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល**

**ជំពូកទី២៖ ដំណើរការនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល**

**ជំពូកទី៣៖ ការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល។**

# ជំពូកទី១

## សញ្ញាណទូទៅនៃនីតិវិធីត្រៀម

## សម្រាប់ការទាញហេតុផល

# ជំពូកទី១

# សញ្ញាណទូទៅនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នៅក្នុងនីតិវិធីនៃបណ្ដឹងរដ្ឋប្បវេណីមានច្រើនដំណាក់កាលជាច្រើន ដោយមានការចាប់ផ្ដើមពីដំណាក់កាល នៃការដាក់ពាក្យបណ្ដឹង នីតិត្រៀមសម្រាប់ការទាញហេតុផល ការទាញហេតុផលដោយផ្ទាល់មាត់ និងការជំនុំជម្រះក្ដី។ នៅក្នុងការដោះស្រាយរឿងក្ដីរដ្ឋប្បវេណី នីតិវិធីនៃការជំនុំជម្រះរឿងក្ដីគឺផ្ដោតសំខាន់ទៅលើ នីតិវិធីចំនួន២ សំខាន់ៗ ដែលក្នុងនោះរួមមាន នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និង ការទាញហេតុផលដោយផ្ទាល់មាត់។ ប៉ុន្តែនៅក្នុងប្រធាននេះបកស្រាយតែនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលតែប៉ុណ្ណោះ។

ជាគោលការណ៍នៃនីតិវិធីរដ្ឋប្បវេណី គឺភាគីនៃបណ្ដឹងមានសិទ្ធិទាមទារឲ្យតុលាការធ្វើការសាកសួរ ដើម្បីអាចមានឱកាសបញ្ចេញមតិផ្ទាល់ខ្លួនពាក់ព័ន្ធនឹងរឿងក្ដី ហើយនឹងមានឱកាសនិយាយតទល់ចំពោះមុខដូចគ្នារវាងដើមចោទ និងចុងចម្លើយ។ ដូចនេះការធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គឺដើម្បីឆ្លើយតបទៅនឹងគោលការណ៍ខាងលើ នេះហើយក៏ដើម្បីជួយសម្រួលដល់ការជម្រះក្ដីនៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់ផងដែរ។

## ១.១ និយមន័យ និងសារប្រយោជន៍នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

### ១.១.១ និយមន័យ

នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គឺជាដំណាក់កាលដើមមួយនៃនីតិវិធីរដ្ឋប្បវេណីដែលធ្វើឡើងដើម្បីផ្ដល់ឱកាសដល់តុលាការក្នុងការរៀបចំនូវសេចក្ដីអះអាងរបស់ភាគី បំភ្លឺនូវចំណុចវិវាទនៃរឿងក្ដីដែលគូភាគីមិនយល់ព្រមស្របគ្នា និងរៀបចំនូវភស្តុតាងដែល ទាក់ទង និងចំណុចវិវាទនៃរឿងក្ដីនោះ ដើម្បីធ្វើការវិនិច្ឆ័យរឿងក្ដីនៅក្នុងនីតិវិធីនៃការទាញហេតុ ផលដោយផ្ទាល់មាត់ឱ្យបានល្អិតល្អន់។[1]

### ១.១.២ សារៈប្រយោជន៍នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

សារៈប្រយោជន៍នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គឺដើម្បីលើកកំពស់ និងសម្រួលដល់ការជម្រះក្ដីនៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់និងផ្ដល់សមភាព និងភាព យុត្តិធម៌ដល់ភាគីនៃវិវាទ តាមរយៈការជួបគ្នាផ្ទាល់នៅក្នុងពេលតែមួយ និងកន្លែងតែមួយ ដើម្បីធ្វើការ អះអាងអំពីអង្គហេតុ និងការដាក់ភស្តុ-តាងជូនតុលាការ។ មួយវិញទៀត នីតិវិធីនេះអាចធ្វើការជម្រះក្ដី នៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់មិនមានភាពស្មុគស្មាញ ពីព្រោះតុលាការអាចស្នើឲ្យភាគី ដកការអះអាងអំពីអង្គហេតុណាដែលមិនមានសារៈប្រយោជន៍ចំពោះការសម្រេចសេចក្ដី និងអាចផាត់ចោលនូវអង្គហេតុណា ដែលភាគីធ្វើការអះអាងដូចគ្នា ដោយចាត់ទុកថាជាអង្គហេតុដែលពុំមានវិវាទ។ ការណ៍ដែលនាំឲ្យមានភាពស្មុគស្មាញគឺថា នៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់ ភាគីនីមួយៗ តែងតែលើកឡើងនូវអង្គហេតុ ផ្សេងៗដែលខ្លួនយល់ថាមានសារៈប្រយោជន៍សម្រាប់ខ្លួនឯង ដោយពុំ គិតថាអង្គហេតុទាំងនោះ មាន ឬ គ្មានសារៈសំខាន់ចំពោះរឿងក្ដីនោះទេ។ ស្របពេល

[1] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ១០៣។

ជាមួយគ្នានេះផងដែរភាគីនីមួយៗតែងតែតវ៉ាចំពោះការលើកឡើងនូវអង្គហេតុទាំងអស់របស់ភាគីម្ខាងទៀត ហើយព្យាយាមដាក់ភស្តុតាងទាំងឡាយណាដែលខ្លួនគិតថាមានប្រយោជន៍សម្រាប់ខ្លួនឯង។ ក៏ប៉ុន្តែ ការធ្វើបែបនេះនឹងនាំឲ្យការជម្រះក្តីមានភាពស្មុគស្មាញនិង អូសបន្លាយដោយឥតប្រយោជន៍ និង ធ្វើឱ្យមានការលំបាកក្នុងការស្វែងរកការពិត ។ ហេតុដូច្នេះហើយ មុននឹង ចាប់ផ្តើមធ្វើការទាញហេតុផលដោយផ្ទាល់មាត់ តុលាការត្រូវពិគ្រោះជាមួយភាគីទាំងសងខាង ត្រូវរៀបចំ សេចក្តីអះអាងរបស់ភាគី និង ត្រូវបំភ្លឺនូវចំណុចវិវាទ តាមវិធីសាស្ត្រដូចតទៅៈ (១) ស្នើឱ្យភាគីដកការ អះអាងអំពីអង្គហេតុដែលមិនមានប្រយោជន៍ចំពោះការសម្រេចអំពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិដែលជាកម្មវត្ថុ នៃបណ្តឹង និង ផាត់ចោលនូវអង្គហេតុទាំងឡាយណាដែលភាគីធ្វើការអះអាងដូចគ្នា ចំពោះចំណុចជាសារវ័ន្តនៃ ការពិនិត្យភស្តុតាង ដោយចាត់ទុកថាជាអង្គហេតុដែលពុំមានវិវាទ (២) ជាងនេះទៅទៀត ចំពោះភស្តុតាង ដែលត្រូវពិនិត្យទាក់ទងនឹងចំណុចវិវាទ តុលាការត្រូវធានាឱ្យបាននូវការពិនិត្យដោយសមូហវិធី ដោយត្រូវយកចិត្តទុកដាក់តែទៅលើភស្តុតាងដែលសំខាន់ និង មានតម្លៃតែប៉ុណ្ណោះ។[2]

ដោយសារហេតុផលនេះហើយ បានជាក្រមនីតិវិធីរដ្ឋប្បវេណី ចែងថា នៅមុនការជម្រះក្តីដោយការទាញហេតុផលដោយ ផ្ទាល់មាត់ ត្រូវរៀបចំនីតិវិធីសម្រាប់ការត្រៀមទាញហេតុផល ។

### ១.១.៣ គោលបំណងនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ជានីតិវិធីនៃការត្រៀមរៀបចំសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ ដើម្បីលើកកម្ពស់ និងសម្រួលដល់ការជម្រះក្តីនៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់។ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល មានគោលបំណងសំខាន់ដូចជាៈ ១.រៀបចំការអះអាងរបស់ភាគី ២.រៀបចំចំណុចវិវាទនៃរឿងក្តី និង ៣.រៀបចំភស្តុតាងដែលទាក់ទងនឹងចំណុចវិវាទនៃរឿងក្តី ដើម្បីអាចធ្វើការវិនិច្ឆ័យរឿងក្តីនៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ឱ្យបានល្អិតល្អន់។[3]

ចំពោះរឿងក្តីចំនួនទឹកប្រាក់តិច ដែលមានគោលបំណងធ្វើការដោះស្រាយវិវាទឱ្យបានឆាប់រហ័ស តាមនីតិវិធីងាយស្រួល តុលាការត្រូវកំណត់កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ភ្លាម បន្ទាប់ពីការដាក់ពាក្យបណ្តឹង ដោយមិនចាំបាច់ធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលទេ។[4]

## ១.២ គោលការណ៍ទូទៅ នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

### ១.២.១ គោលការណ៍ចំពោះមុខ

ដើម្បីធានានូវសិទ្ធិទាមទារឱ្យសាកសួរ ឱ្យមានប្រសិទ្ធិភាព ការជម្រះក្តីត្រូវតែធ្វើឡើងដោយកោះហៅភាគី ទាំងសងខាងឱ្យមកបង្ហាញខ្លួននៅកាលបរិច្ឆេទតែមួយ ហើយត្រូវឱ្យភាគីប្រឈមមុខដាក់គ្នាដោយផ្ទាល់។ ប្រសិនបើអនុញ្ញាតឱ្យតុលាការអាចកោះហៅភាគីតែម្ខាង ហើយស្តាប់ការអះអាងរបស់ភាគីនោះ ដោយពុំមាន

[2] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ១២៧។

[3] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ១០៣។

[4] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ២២៣។

វត្តមានរបស់ភាគីម្ខាងទៀត នោះអាចនឹងប៉ះពាល់ទៅដល់ទំនុកចិត្តរបស់ភាគី ទៅលើយុត្តិធម៌នៃការវិនិច្ឆ័យ។ ហេតុនេះហើយបានជាមានបញ្ញត្តិចែងថា ជាគោលការណ៍ តុលាការត្រូវវិនិច្ឆ័យ ដោយគោរពតាមគោលការណ៍ចំពោះមុខ ពោលគឺត្រូវកោះហៅភាគីទាំងសងខាងឱ្យភាគីទាំងសងខាងថ្លែងពីអំណះអំណាងរបស់ខ្លួន និងជជែកតតាំងគ្នាទៅវិញទៅមក។[5] ចំពោះគោលការណ៍ចំពោះមុខនេះ ក៏មាន ករណីលើកលែងមួយចំនួនដែរ។[6]

### ១.២.២ គោលការណ៍អសាធារណៈ

ជាគោលការណ៍ កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល មិនចាំបាច់បើកជាសាធារណៈទេ។ មានន័យថា តុលាការធ្វើតែចំពោះភាគីទាំងសងខាងដោយមិនបាច់បើកសវនាការជាសាធារណៈទេ ដោយអាចធ្វើនៅបន្ទប់ចៅក្រមបាន។ ប៉ុន្តែ តុលាការអាចអនុញ្ញាតឱ្យអ្នកដែលតុលាការយល់ឃើញថាសមរម្យចូលស្តាប់ជាអ្នកសង្កេតការណ៍បាន ។ នេះសបញ្ជាក់ឱ្យឃើញថា អ្នកដែលអាចចូលរួមបានគឺត្រូវមានការអនុញ្ញាតពីតុលាការ ហើយចូលរួមស្តាប់ក្នុងនាមជាអ្នកសង្កេតការណ៍បាន។[7]

## ១.៣ សិទ្ធិអំណាចតុលាការ និងភាគី

ការដឹកនាំនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ធ្វើឡើងដោយប្រធានក្រុមប្រឹក្សាជំនុំជម្រះដែលត្រូវធ្វើការដឹកនាំ និងចាត់ចែងនីតិវិធីនេះ។ ប្រធានក្រុមប្រឹក្សាជំនុំជម្រះអាចអនុញ្ញាតឱ្យជនណាម្នាក់និយាយបាន និងហាមឃាត់ជនដែលមិនស្តាប់បញ្ជារបស់ខ្លួនមិនឱ្យនិយាយបាន។

### ១.៣.១ សិទ្ធិអំណាចរបស់តុលាការ ក្នុងការដឹកនាំនីតិវិធីបណ្តឹង

ការគ្រប់គ្រងនីតិវិធីឱ្យដើរទៅមុខ ព្រមទាំងចាត់ចែង និងការរៀបចំជំនុំជម្រះ គឺជាសិទ្ធិអំណាច និងការទទួលខុសត្រូវរបស់តុលាការ។ ដើម្បីឱ្យការជំនុំជម្រះអាចប្រព្រឹត្តទៅដោយពេញលេញ និងឆាប់រហ័ស គេត្រូវធ្វើយ៉ាងណាឱ្យនីតិវិធីដំណើរការទៅមុខយ៉ាងលឿន ហើយធ្វើការចាត់ចែងឱ្យបានសមរម្យ ស្របទៅតាមស្ថានភាពនៃការជំនុំជម្រះ។ ហេតុដូច្នេះសិទ្ធិអំណាចនៃការគ្រប់គ្រងនីតិវិធី ដែលបានផ្តល់ឱ្យតុលាការនោះហៅថា សិទ្ធិអំណាចក្នុងការដឹកនាំនីតិវិធីបណ្តឹង។ ជាគោលការណ៍សិទ្ធិអំណាចក្នុងការដឹកនាំនីតិវិធីបណ្តឹង គឺជាសិទ្ធិអំណាចតុលាការត្រូវអនុវត្តដោយតុលាការ ដូចជា សិទ្ធិឱ្យបំភ្លឺ ការលើកចោមធ្យោបាយតទល់ ឬ ការពារខ្លួន ដែលបានដាក់យឺតយ៉ាវការបំបែក និង ការរួមបញ្ចូលរឿងក្តី និងការចូលរួមរបស់អ្នកបកប្រែ ជាអាទិ៍។ ខ្លឹមសារនៃការដឹកនាំនីតិវិធីមានវិសាលភាព គ្របដណ្តប់ទៅលើដំណើរការទាំងមូលនៃការជំនុំជម្រះ មានដូចជា ការកំណត់កាលបរិច្ឆេទ និងការផ្លាស់ប្តូរកាលបរិច្ឆេទ ការសម្រេចអំពីការពន្យាអំឡុងពេលដែលបញ្ហាទាក់ទងទៅនឹងនីតិវិធីទាំងស្រុង ការរៀបចំ និងការចាត់ចែងសកម្មភាពរបស់ភាគី នៅកាលបរិច្ឆេទដែលបានកំណត់ ជាដើម។

---

[5] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៣ កថាខណ្ឌទី២។

[6] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ២០០។។

[7] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៣ កថាខណ្ឌទី២។

### ១.៣.២ សិទ្ធិអំណាចរបស់ភាគីនៅក្នុងបណ្តឹង

ក្រមនីតិវិធីរដ្ឋប្បវេណី ទទួលស្គាល់នូវសិទ្ធិអំណាចរបស់ភាគី នៅក្នុងការបំភ្លឺទំនាក់ទំនងអង្គហេតុនៃរឿងក្តី ឬ អាចហៅម៉្យាងទៀតថា សិទ្ធិអំណាចរបស់ភាគីក្នុងការផ្តល់សម្ភារៈជាមូលដ្ឋានផ្សេងៗ ពាក់ព័ន្ធនឹងអង្គហេតុចាំបាច់ដើម្បីឱ្យតុលាការអាចចេញសាលក្រមបាន។ ដោយតុលាការមិនអាចយកអង្គហេតុណាដែលភាគីមិនបានអះអាង មកធ្វើជាមូលដ្ឋាននៃសាលក្រមបានឡើយ។[8] មានន័យថា ភាគីមានសិទ្ធិសេរីភាពក្នុងការអះអាង ឬ មិនអះអាងអំពីអង្គហេតុណាមួយ ហើយមានសិទ្ធិអំណាចក្នុងការកំណត់ទំហំនៃអង្គហេតុដែលតុលាការត្រូវពិចារណានៅពេលធ្វើសេចក្តីសម្រេច។ ម៉្យាងវិញទៀតបើទោះបីជាមានអង្គហេតុជាក់ស្តែង ដែលមានប្រយោជន៍សម្រាប់ភាគីក៏ដោយ តែបើភាគីមិនអះអាងទេ តុលាការមិនអាចពិនិត្យអង្គហេតុនោះ ដើម្បីចេញសាលក្រមបានឡើយ។ ការណ៍នេះធ្វើឱ្យភាគីរងនូវការខូចប្រយោជន៍ ដោយសារតែតុលាការមិនអាចទទួលស្គាល់អានុភាពគតិយុត្តដែលមានប្រយោជន៍សម្រាប់ភាគីនោះ។ ដោយហេតុនេះហើយ ភាគិត្រូវធ្វើការអះអានូវអង្គហេតុដែលមានប្រយោជន៍ដល់ខ្លួន ប្រសិនបើចង់ឈ្នះក្តី។

**ឧទាហរណ៍៖** ទោះបីជាអង្គហេតុថា ដើមចោទជាម្ចាស់អចលនវត្ថុក៏ដោយ តែប្រសិនបើដើមចោទមិនបានអះអាងទេ តុលាការមិនអាចយកអង្គហេតុនោះមកពិចារណាបានឡើយ ហើយដោយហេតុនេះតុលាការមិនអាចទទួលស្គាល់ថា អចលនវត្ថុនោះជារបស់ដើមចោទបានឡើយ។

### ១.៣.៣ ការទទួលខុសត្រូវរបស់តុលាការ និង ភាគី

ក្នុងនាមជាអ្នកគ្រប់គ្រងនីតិវិធីរដ្ឋប្បវេណី តុលាការត្រូវប្រឹងប្រែងធានាឱ្យបានថា រឿងក្តីរដ្ឋប្បវេណីត្រូវបានប្រព្រឹត្តឡើងដោយមានភាពយុត្តិធម៌ និង ឆាប់រហ័ស ។ នេះគឺជាកាតព្វកិច្ចជាមូលដ្ឋានដ៏ចម្បងបំផុត របស់តុលាការ។ ដោយឡែក ចំពោះភាគីវិញ ក្នុងខណៈដែលពួកគេត្រូវបានអនុញ្ញាតឱ្យអនុវត្តបណ្តឹងតាម ឆន្ទៈរបស់ខ្លួន ដើម្បីឈ្នះក្តី តែពួកគេត្រូវបានហាមឃាត់មិនឱ្យអនុវត្តបណ្តឹងដោយមិនស្មោះត្រង់ និង ដោយ ទុច្ចរិត ចំពោះភាគីម្ខាងទៀតឡើយ។ សកម្មភាពបណ្តឹងដែលត្រូវបានចាត់ទុកថាមិនមាន ភាពស្មោះត្រង់ ត្រូវកំណត់ទៅតាមករណីជាក់ស្តែងនីមួយៗ។ នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី មានចែងបញ្ញត្តិពាក់ព័ន្ធទៅនឹងអានុភាពមិនអំណោយផលមួយចំនួន ដែលកើតចេញពីការមិនគោរពកាតព្វកិច្ចអនុវត្ត សកម្មភាពបណ្តឹងដោយស្មោះត្រង់ និង សុចរិត។[9]

## ១.៤ ភាសាដែលប្រើក្នុងតុលាការ សិទ្ធិរបស់ភាគីក្នុងការស្នើសុំឱ្យមានអ្នកបកប្រែ

ក្រមនីតិវិធីរដ្ឋប្បវេណី ចែងថា នៅក្នុងតុលាការ ត្រូវប្រើភាសាខ្មែរ ដែលជាភាសាផ្លូវការរបស់ព្រះរាជាណាចក្រកម្ពុជា ហើយភាគីដែលមិនអាចយល់ភាសាខ្មែរ អាចស្នើសុំអ្នកបកប្រែដែលមានលក្ខណសម្បត្តិ គ្រប់គ្រាន់បាន។ លើសពីនេះទៅទៀត នៅក្នុងករណីដែលភាគីមិនមានលទ្ធភាពជួលអ្នកបកប្រែដែលមាន លក្ខណសម្បត្តិទេ ដោយមូលហេតុថាគាត់ពុំស្គាល់អ្នកបកប្រែដែលមានលក្ខណៈសម្បត្តិ ជាអាទិ៍ តុលាការត្រូវ ផ្តល់អ្នកបកប្រែ

[8] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ២០០។

[9] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ១៤០។

ដែលមានលក្ខណសម្បត្តិ ឱ្យភាគីនោះ។[10] នៅពេលដែលភាគីណាមួយមិនអាច យល់ភាសាខ្មែរបាន ភាគីនោះពុំអាចថ្លែងពីអំណះអំណាងរបស់ខ្លួន និង ពុំអាចតតាំងចំពោះការអះអាង របស់ភាគីម្ខាងទៀតបានឡើយ។ ក្នុងន័យនេះ បញ្ញត្តិដែលចែងថា ភាគីនោះអាចជួលអ្នកបកប្រែដោយខ្លួនឯងនិង អូសបន្លាយដោយឥតប្រយោជន៍ និង ធ្វើឲ្យមានការលំបាកក្នុងការស្វែងរកការពិត។ ជាងនេះទៅទៀត តុលាការអាចចម្រាញ់យកតែភស្តុតាងណាដែលសំខាន់ និង មានតម្លៃសម្រាប់អង្គហេតុតែប៉ុណ្ណោះ។

[10] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៥។

# ជំពូកទី២

## ដំណើរការនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

# ជំពូកទី២
# ដំណើរការនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

## ២.១ សកម្មភាពរបស់តុលាការ និងភាគីនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គឺជានីតិវិធីដែលត្រៀមសម្រាប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ដើម្បីលើកកំពស់ និងសម្រួលដល់ការជំនុំជម្រះក្ដីនៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់ ហេតុដូច្នេះហើយទើបក្រមនីតិវិធីបានកំណត់សកម្មភាពមួយចំនួនដែលមានភាពចាំបាច់ដូចជា៖ សកម្មភាពតុលាការ និងសកម្មភាពរបស់ភាគី។

### ២.១.១ សកម្មភាពតុលាការ

មុនដល់ដំណាក់កាលនៃនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ តុលាការត្រូវធ្វើសកម្មភាពមួយចំនួនជាមុនសិន មុននឹងឈានដល់ការជម្រះក្ដី ហើយក្រមនីតិវិធីរដ្ឋប្បវេណីក៏បានកំណត់នូវសកម្មភាពដែលតុលាការនឹងត្រូវធ្វើមានដូចជា៖ កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ការសាកល្បងផ្សះផ្សា និងក្នុងករណីដែលតុលាការពុំអាចសម្រេចបាននូវការផ្សះផ្សាបាន។

#### ២.១.១.១ កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

តុលាការ ត្រូវកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកដំបូង ក្នុងអំឡុងពេល ៣០ ថ្ងៃ បន្ទាប់ពីថ្ងៃដែលពាក្យបណ្ដឹងត្រូវបានដាក់។[11] ការកំណត់បែបនេះ គឺចេញមកអំពីការគិតគូរដែលថា ចុងចម្លើយនឹងមានពេលវេលាគ្រប់គ្រាន់ក្នុងការរៀបចំការការពារខ្លួន និងថាការចាប់ផ្ដើមនីតិវិធី នឹងមិនមានការយឺតយ៉ាវ។

នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ត្រូវធ្វើឡើងនៅកាលបរិច្ឆេទដែលភាគីសងអាចចូលរួមបាន។[12] គោលការណ៍ចំពោះមុខ[13] ត្រូវបានធានាយ៉ាងពេញលេញនៅក្នុងនីតិវិធីនេះ ហេតុនេះ បន្ទាប់ពីបានកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលហើយ តុលាការត្រូវកោះហៅភាគីទាំងសងខាង។ ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ តុលាការអាចធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបាន ទោះបីជាភាគីម្ខាងមិនមានវត្តមានក៏ដោយ ក្នុងករណីដែលតុលាការបានបញ្ជូនដីកាកោះ និងបានផ្ដល់ឱកាសឱ្យភាគីនោះបង្ហាញខ្លួននោះបង្ហាញខ្លួនហើយ។

[11] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៨០ កថាខណ្ឌទី២។

[12] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ១០៥ កថាខណ្ឌទី១។

[13] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៣ កថាខណ្ឌទី២។

កាលបរិច្ឆេទនៃ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលមិនចាំបាច់បើជាសាធារណៈទេ។[14] នេះគឺដោយសារតែ នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការគ្រាន់តែធ្វើការកំណត់នូវចំណុចវិវាទ តាមរយៈការរៀបចំការអះអាងរបស់ភាគី និងគ្រាន់តែរៀបចំនូវភស្តុតាងដែលត្រូវ ពិនិត្យតែប៉ុណ្ណោះ។ លើសពីនេះទៅទៀត នៅក្នុងករណីជាច្រើន ការធ្វើនីតិវិធីនេះ នៅក្រៅសាលសវនាការ ត្រូវបានចាត់ទុកថាជាការសមស្របហើយ (ដូចជាធ្វើក្នុងបន្ទប់របស់ចៅក្រម ជាដើម)។

ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ តុលាការអាចអនុញ្ញាតឱ្យជនដែលខ្លួនយល់ឃើញថា សមរម្យ ដូចជាសមាជិកគ្រួសាររបស់ភាគី ឬជនដែលមានផលប្រយោជន៍ពាក់ព័ន្ធដទៃទៀត ចូលស្តាប់ជាអ្នកសង្កេតការណ៍បាន។[15] ម្យ៉ាងទៀត សកម្មភាពដែលបានធ្វើក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនេះ ត្រូវបានសេចក្តីថ្លែងការណ៍ នៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់ នាពេលក្រោយ និងត្រូវបំភ្លឺអំពីបញ្ហាទាំងអស់នេះ នៅក្នុងសវនាការជាសាធារណៈ។[16] ចំពោះការអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យអ្នកសង្កេតការណ៍ចូលស្តាប់ គឺជាឆន្ទានុសិទ្ធិរបស់តុលាការ។ នៅពេលធ្វើការសម្រេចអំពីការអនុញ្ញាត ឬមិនអនុញ្ញាតនេះ តុលាការត្រូវពិចារណាអំពីមូលហេតុនៃការស្នើសុំចូលស្តាប់ ព្រមទាំងមតិរបស់ភាគី ផងដែរ។ ក្នុងករណីដែលការស្នើសុំចូលស្តាប់ ត្រូវបានធ្វើឡើងដោយបុគ្គលដែលមានការពាក់ព័ន្ធទៅនឹងរឿងក្តី ជាគោលការណ៍ តុលាការអាចផ្តល់ការអនុញ្ញាតចំពោះការស្នើសុំនោះបាន ប្រសិនបើការចូលស្តាប់នោះ មិនទំនងជានឹងបង្កបញ្ហាដល់ការជម្រះក្តីទេ។

បើភាគីបានដាក់ពាក្យសុំឱ្យប្តូរកាលបរិច្ឆេទ ភាគីនោះត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់អំពីមូលហេតុដែលការប្តូរកាលបរិច្ឆេទនោះត្រូវធ្វើជាចាំបាច់។ ការប្តូរកាលបរិច្ឆេទនៃ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ មិនត្រូវបានអនុញ្ញាតទេ លើកលែងតែករណីដែលមានមូលហេតុមិនអាចចៀសវាងបាន។ ការប្តូរកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកដំបូង អាចអនុញ្ញាតឱ្យបាន ប្រសិនបើមានការព្រមព្រៀងគ្នាពីសំណាក់គូភាគី។[17]

ការកោះហៅតាមកាលបរិច្ឆេទត្រូវធ្វើដោយបញ្ជូនដីកាកោះ ឬ ដោយជូនដំណឹងអំពីកាលបរិច្ឆេទ ទៅអ្នកដែលបានបង្ហាញខ្លួននៅតុលាការចំពោះបណ្តឹងដែលបានពាក់ព័ន្ធ។[18]

### ២.១.១.២ ការសាកល្បងផ្សះផ្សា

នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការត្រូវសាកល្បងធ្វើការផ្សះផ្សាជាដំបូងសិន លើកលែងតែក្នុងករណីដែលយល់ឃើញថាមិនសមរម្យ។[19] ដោយសារថា នីតិវិធីរដ្ឋប្បវេណី មានគោលបំណងធ្វើការ

[14] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៣ កថាខណ្ឌទី១។

[15] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ១០៥ កថាខណ្ឌទី២។

[16] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ១១៦ កថាខណ្ឌទី១។

[17] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ២៤១។

[18] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ២៤២។

[19] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ១០៤។

កំណត់អំពអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិ និងកាតព្វកិច្ចតាមច្បាប់សារធាតុ ដែលអាចចាត់ចែងបាន ដោយផ្អែកលើការព្រមព្រៀងរវាងភាគី ដូច្នេះទោះបីជានៅពេលដែលនីតិវិធីបណ្ដឹងត្រូវបានចាប់ផ្ដើមហើយក៏ដោយ ប្រសិនបើភាគីបានកំណត់ថាសិទ្ធិ ឬកាតព្វកិច្ចនោះ មានអត្ថិភាព ឬ គ្មាន តាមរយៈការសះជាហើយភាគីសម្រេចចិត្តបញ្ចប់វិវាទនោះ គេអាចនិយាយបានថា វាគឺជាលទ្ធផលដែលគួរឱ្យចង់បាន។ ហេតុនេះហើយបានជាក្រមនីតិវិធីរដ្ឋប្បវេណីចែងថានៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដែលជាសកម្មភាពដំបូងបំផុតនៃការជម្រះក្ដី តុលាការត្រូវណែនាំឱ្យភាគីទាំងសងខាង សះជានឹងគ្នា។[20] ប៉ុន្តែផ្ទុយទៅវិញ ក្នុងករណីដែលតុលាការយល់ឃើញថា ការព្យាយាមសាកល្បងផ្សះផ្សា មិនសមរម្យទេដូចជា ក្នុងករណីដែលសិទ្ធិ ឬ កាតព្វកិច្ច ដែលជាកម្មវត្ថុនៃបណ្ដឹង គឺជាប្រភេទនៃសសិទ្ធិ ឬ កាតព្វកិច្ចដែលមិនអាចចាត់ចែងបានដោយគ្រាន់តែផ្អែកលើការព្រមព្រៀងរបស់ភាគីប៉ុណ្ណោះទេ ឬ ក្នុងករណីដែលអាកប្បកិរិយារបស់ភាគី បង្ហាញយ៉ាងច្បាស់ថា ពួកគេគ្មានឆន្ទៈធ្វើការផ្សះផ្សាទេនោះ តុលាការមិនចាំបាច់ណែនាំឱ្យភាគីសះជានឹងគ្នាឡើយ។

ម៉្យាងទៀត ប្រសិនបើ តាមរយៈការវិនិច្ឆ័យអំពីស្ថានភាពនៃបណ្ដឹង តុលាការយល់ឃើញថា វិវាទនោះអាចដោះស្រាយដោយការផ្សះផ្សាបាន តុលាការអាចសាកល្បងធ្វើការផ្សះផ្សា នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនៅពេលក្រោយមក ឬ នៅក្នុងនីតិវិធីនៃការទាញហេតុផលតែម្ដងក៏បាន។[21] នៅពេលណែនាំឱ្យភាគីសះជាគ្នា តុលាការអាចប្រើវិធីមួយ ដោយឱ្យភាគីម្ខាងចេញពីបន្ទប់ ហើយតុលាការស្ដាប់ការអះអាងរបស់ភាគីម្ខាងទៀត និង ធ្វើដូច្នេះម្ដងទៀតចំពោះភាគីម្ខាងទៀត (គេហៅថា "ការសួរឆ្លាស់គ្នា")។ ក៏ប៉ុន្តែ បើប្រើវិធីនេះ ភាគីម្ខាងមិនអាចដឹងថាតើតុលាការ និងភាគីម្ខាងទៀត បានពិគ្រោះគ្នាពីរឿងអ្វីខ្លះនោះទេ ហើយការណ៍នេះ នឹងធ្វើឱ្យនីតិវិធីនៃការផ្សះផ្សា មានភាពមិនច្បាស់លាស់។ ហេតុដូច្នេះ វិធីសាស្ត្រនេះ អាចប្រើបានតែក្នុងករណីដែលមានការព្រមព្រៀងច្បាស់លាស់រវាងភាគី ក្នុងការធ្វើបែបនេះ តែប៉ុណ្ណោះ។

**ឧទាហរណ៍៖** នៅក្នុងបណ្ដឹងពាក់ព័ន្ធនឹងកិច្ចសន្យាលក់ ទិញឡាន ដែលលោក A បានទាមទារឱ្យប្រគល់ឡាន ដោយអះអាងថា ខ្លួនបានរំលាយកិច្ចសន្យាដោយសារតែលោក B មិនបានបង់ថ្លៃឡានតាមការកំណត់ ក្នុងករណីនេះដើមចោទបានធ្វើសម្បទាន (លះបង់ផលប្រយោជន៍របស់ខ្លួន) ដោយលើកលែងកាតព្វកិច្ចបង់ថ្លៃឡានដែលមិនទាន់បង់ ហើយផ្ដល់អំឡុងពេលសម្រាប់ប្រគល់ឡានមកវិញ ក្នុងរយៈពេល ១ខែ រីឯចុងចម្លើយវិញក៏ទទួលស្គាល់នូវការបញ្ចប់កិច្ចសន្យាលក់ ទិញឡាន ដោយការរំលាយកិច្ចសន្យា ដោយមានមូលហេតុមិនបានបង់ថ្លៃឡាន ហើយសន្យាថា ១ខែ ក្រោយ ខ្លួននឹងប្រគល់ឡាននោះជូនលោក A វិញ។

ក្នុងករណីមានការសះជា ការលះបង់នូវការទាមទារ ឬ ការទទួលស្គាលនូវការទាមទារ ត្រូវបានកត់ត្រានៅក្នុងកំណត់ កំណត់ត្រានេះ មានអានុភាពដូចគ្នានឹងសាលក្រមស្ថាពរ។ [22]

[20] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ១០៤។

[21] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៩៧។

[22] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ២២២។

### ២.១.១.៣ ករណីការផ្សះផ្សាមិនបានសម្រេច

ក្នុងករណីដែលការផ្សះផ្សាមិនបានសម្រេចទេ តុលាការត្រូវចាប់ផ្តើមការត្រៀមរៀបចំសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់។ ដោយសារថា នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល មានគោលបំណងធ្វើការរៀបចំនូវការអះអាងរបស់ភាគី ធ្វើការកំណត់នូវចំណុចវិវាទ និងធ្វើការរៀបចំនូវភស្តុតាងដែលទាក់ទងទៅនឹងចំណុចវិវាទ នៅក្នុងនីតិវិធីនេះ តុលាការត្រូវបង្គាប់ឱ្យភាគីដាក់ជាមុន នូវការអះអាង និងភស្តុតាង ដែលពួកគេមានបំណងនឹងដាក់នៅពេលធ្វើការទាញហេតុផលដោយផ្ទាល់មាត់។ ហេតុនេះហើយ ត្រង់ចំណុចនេះ ការត្រៀមរៀបចំសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ មានលក្ខណៈប្រហាក់ប្រហែលទៅនឹងការហាត់សមធ្វើនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ដែរ។

នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការត្រូវអនុវត្តសិទ្ធិឱ្យបំភ្លឺ និងរៀបចំមធ្យោបាយតទល់ ឬ ការពារខ្លួននោះ ជាពិសេស ត្រូវរៀបចំការអះអាងរបស់ភាគីទាំងសងខាង ដើម្បីកំណត់ចំណុចវិវាទ ពិតប្រាកដនៃរឿងក្តី ហើយតុលាការត្រូវរៀបចំនូវភស្តុតាងពាក់ព័ន្ធនឹងចំណុចវិវាទនោះ ដែលត្រូវធ្វើការពិនិត្យនៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់។ នេះគឺជាផ្នែកសំខាន់បំផុតនៃការជម្រះក្តី នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល។[23]

#### (ក) ការបញ្ជាក់អំពីចំណុចវិវាទ តាមរយៈការរៀបចំនូវការអះអាង និង ការរៀបចំភស្តុតាង

ជាទូទៅ ចំណុចទាំងឡាយណាដែលភាគីទាំងសងខាងប្រកែកគ្នា (ជាធម្មតា គឺអង្គហេតុ) គេហៅថាចំណុចវិវាទ។ ក្នុងករណីដែលភាគីណាម្ខាង បានអះអាងអំពីអត្ថិភាពនៃអង្គហេតុណាមួយ ក្រមនីតិវិធីរដ្ឋប្បវេណីបែងចែកអាកប្បកិរិយារបស់ភាគីម្ខាងទៀតជាបួនប្រភេទ។ ទី១ ភាគីម្ខាងទៀតនោះ អាចធ្វើសេចក្តីថ្លែងការណ៍បដិសេធនូវអត្ថិភាពនៃអង្គហេតុនោះ ដែលការធ្វើបែបនេះ គេហៅថា ការបដិសេធ (ការមិនទទួលស្គាល់)។ ទី២ ភាគីនោះ អាចធ្វើសេចក្តីថ្លែងការណ៍ទទួលស្គាល់អត្ថិភាពនៃអង្គហេតុនេះ ដែលគេហៅថា ការសារភាព។[24] ទី ៣ ភាគីនោះ អាចធ្វើសេចក្តីថ្លែងការណ៍ថា ខ្លួនមិនបានដឹងអំពីអត្ថិភាពនៃអង្គហេតុនោះទេ ដែលការធ្វើបែបនេះ គេហៅថា សេចក្តីថ្លែងការណ៍អំពីការមិនបានដឹង។ ទី ៤ ចុងក្រោយគេ គឺករណីដែលភាគីនោះមិនឆ្លើយថាអ្វីទាំងអស់។ ក្នុងចំណោមករណីទាំងនេះ អង្គហេតុ គឺជាចំណុចវិវាទ នៅក្នុងករណីទី១ តែនៅក្នុងករណីទី២ អង្គហេតុមិនមែនជាចំណុចវិវាទទេ។ បញ្ហាកើតមានឡើងចំពោះករណីពីរចុងក្រោយ។ នៅក្នុងករណីនៃការធ្វើសេចក្តីថ្លែងការណ៍អំពីការមិនដឹងក្រមនីតិវិធីរដ្ឋប្បវេណីសន្មតអាកប្បកិរិយានោះថាជាការតវ៉ាចំពោះអង្គហេតុនោះ[25]ហើយចំពោះករណីដែលភាគីមិនឆ្លើយអ្វីទាំងអស់វិញ ត្រូវចាត់ទុកថា ភាគីបានសារភាពអំពីអង្គហេតុ

[23] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ១០៣។

[24] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ១២៣ កថាខណ្ឌទី២។

[25] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៩៦ កថាខណ្ឌទី២។

នោះ លើកលែងតែក្នុងករណីដែលតុលាការយល់ឃើញថា ភាគីនោះបានតវ៉ាចំពោះអង្គហេតុនោះ ដោយគិតពិចារណាអំពីអាកប្បកិរិយាទាំងស្រុងរបស់ភាគីនោះ។[26]

ហេតុនេះហើយ អង្គហេតុដែលភាគីឆ្លើយថាមិនបានដឹង នឹងក្លាយទៅជាចំណុចវិវាទ។ ផ្ទុយទៅវិញ ប្រសិនបើពុំមានការឆ្លើយតបទេ ត្រូវចាត់ទុកថាជាការសារភាព ហើយអង្គហេតុនោះ នឹងមិនមែនជាចំណុចវិវាទឡើយ។ តាមគោលការណ៍នៃការទាញហេតុផល អង្គហេតុដែលភាគីសារភាព (រួមទាំងអង្គហេតុដែលសន្មតថាបានសារភាព) មិនចាំបាច់ធ្វើការបញ្ជាក់ ដោយភស្តុតាងឡើយ។[27]

- **ការរៀបចំការអះអាងរបស់ភាគី**

នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការនឹងឱ្យគូភាគីធ្វើសេចក្តីថ្លែងការណ៍ដែលជាមធ្យោបាយតទល់ (ដើមចោទ) ឬការពារខ្លួន ដូចជាការដាក់ពាក្យសុំ ឬសកម្មភាពផ្សេងៗទៀតរបស់គូភាគី។ ការដាក់ពាក្យសុំ និងសកម្មភាពផ្សេងៗដែលគូភាគីបានធ្វើ ហៅថា "ការទាញហេតុផល"។ ពាក្យសុំ ជាសកម្មភាពដែលភាគីស្នើសុំឱ្យតុលាការធ្វើសកម្មភាពជាកំណត់មួយ តាមនីតិវិធីច្បាប់ដូចជាចេញសាលក្រម ឬចេញដីកាសម្រេច ឬពិនិត្យភស្តុតាង ឬពាក្យសុំផ្ទេរសមត្ថកិច្ច ជាអាទិ៍។

សកម្មភាពដែលភាគីធ្វើការរៀបរាប់ ឬបញ្ចេញមតិយោបល់ ឬការយល់ឃើញរបស់ខ្លួនទៅកាន់តុលាការនៅក្នុងកាលបរិច្ឆេទនៃកិច្ចនីតិវិធី ហៅថា "សេចក្តីថ្លែងការណ៍"។ ប្រសិនបើ សកម្មភាពដែលភាគីធ្វើការរៀបរាប់ ឬបញ្ចេញមតិយោបល់ ឬការយល់ឃើញរបស់ខ្លួន ពាក់ព័ន្ធនឹងអង្គហេតុទៅកាន់តុលាការហៅថា "សេចក្តីថ្លែងការណ៍អំពីអង្គហេតុ"។ ប្រសិនបើ សកម្មភាពដែលភាគីធ្វើការរៀបរាប់ ឬបញ្ចេញមតិយោបល់ ឬការយល់ឃើញរបស់ខ្លួន ពាក់ព័ន្ធនឹងផ្លូវច្បាប់ទៅកាន់តុលាការ ហៅថា "សេចក្តីថ្លែងការណ៍អពីអង្គច្បាប់"។ នៅក្នុងចំណោមសេចក្តីថ្លែងការណ៍ទាំងនេះ សេចក្តីថ្លែងការណ៍ទាំងឡាយណាដែលមិនឆ្លើយតបនឹងសេចក្តីថ្លែងការណ៍របស់ភាគីម្ខាងទៀត ហើយបានរៀបរាប់អំពីអង្គហេតុឯករាជ្យ ឬមតិយោបល់តាមផ្លូវច្បាប់ ហៅថា "ការអះអាង"។

ជាគោលការណ៍ នីតិវិធីបណ្តឹងត្រូវឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់ ដើម្បីវិនិច្ឆ័យអំពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិសារធាតុរបស់គូភាគីដែលបានទាមទារ តាមរយៈការអះអាងអង្គហេតុ ហេតុនេះអង្គហេតុដែលមិនបានអះអាងដោយភាគី តុលាការមិនអាចយកមកធ្វើជាមូលដ្ឋាននៃសាលក្រមបាននោះទេ ហៅថា "គោលការណ៍នៃការទាញហេតុផល"។[28]

នៅក្នុងការអះអាងរបស់ភាគី ភាគីនឹងធ្វើការអះអាងនូវអង្គហេតុទាំងអស់ ដោយពុំគិតអំពីអង្គហេតុមាន ឬគ្មានប្រយោជន៍តាមផ្លូវច្បាប់ដែលពាក់ព័ន្ធនឹងការទាមទារឡើយ ដូចនេះតុលាការត្រូវរៀបចំការអះអាងរបស់

[26] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៩៦ កថាខណ្ឌទី១។

[27] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ១២៣ កថាខណ្ឌទី២។

[28] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៩៥។

ភាគី ដោយរៀបចំចំណុចដែលភាគីមានទំនាស់ ឬវិវាទនឹងគ្នា និងឱ្យភាគីធ្វើការបំភ្លឺនូវចំណុចវិវាទនោះ ដោយដកការអះអាងអំពីអង្គហេតុដែលមិនមានប្រយោជន៍ចំពោះការសម្រេចអំពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិដែលជាកម្មវត្ថុនៃបណ្តឹង និងប្រមូលយកនូវអង្គហេតុទាំងឡាយណា ដែល ភាគីធ្វើការអះអាងដូចគ្នា ដោយចាត់ទុកថាជា "អង្គហេតុដែលគ្មានវិវាទ" ដាក់ដោយឡែក ដើម្បីផ្ទៀងផ្ទាត់ និងរៀបចំការអះអាងរបស់គូភាគី ដោយកំណត់អង្គហេតុណាខ្លះជាអង្គហេតុមានវិវាទ (កំណត់ចំណុចវិវាទ) និងអង្គហេតុណាខ្លះជាអង្គហេតុគ្មានវិវាទ។ នៅពេលកំណត់បែបនេះបាន តុលាការនឹងមានភាពច្បាស់លាស់អំពីបញ្ហារបស់គូភាគី ឬបង្រួមបញ្ហាពិតប្រាកដរបស់គូភាគី ហើយអាចធ្វើការវិនិច្ឆ័យឱ្យចំបញ្ហានោះ ទើបស្របនឹងទ្រឹស្តី "តុលាការត្រូវរ៉ាប់រងបណ្តឹងឱ្យបានឆាប់រហ័ស និងត្រូវចេញសាលក្រមដែលអាចបញ្ចប់វិវាទជាក់ស្តែង" ។

អង្គហេតុដែលគ្មានវិវាទ គឺជាអង្គហេតុដែលភាគីបានសារភាពនៅចំពោះមុខតុលាការ និងអង្គហេតុដែលតុលាការយល់ឃើញថាមានភាពជាក់ស្តែង។[29]

➢ **ការរៀបចំចំណុចវិវាទ**

ចំណុចវិវាទ ជាចំណុចដែលភាគី "មិនស្របគ្នា" ចំពោះ "អង្គហេតុចម្បង" ណាមួយ ដែលត្រូវបានអះអាងដោយភាគី។ តុលាការមិនអាចសម្រេចសេចក្តីអំពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលភាគីបានអះអាងនោះទេ ប្រសិនបើគ្មានការបំភ្លឺអំពីទំនាក់ទំនងអង្គហេតុនៃរឿងក្តី ទោះបីជាដើមចោទបានដាក់ពាក្យបណ្តឹងចំពោះចុងចម្លើយ ដោយអះអាងអំពីសិទ្ធិ ឬកាតព្វកិច្ចដែលចុងចម្លើយត្រូវបំពេញក៏ដោយ ក៏មិនអាចសម្រេចបានថា សិទ្ធិទាមទារនោះ មានអត្ថិភាព ឬគ្មាននោះដែរ ពីព្រោះការទាមទារ ជាសិទ្ធិអរូបី ហើយសិទ្ធិនេះអាចត្រូវបានទទួលស្គាល់តាមរយៈការអះអាងអង្គហេតុចម្បង ហើយភាពខ្វែងគ្នានៃអង្គហេតុចម្បងរបស់គូភាគី គឺជា **ចំណុចវិវាទ**។

អង្គហេតុចម្បង ជាអង្គហេតុលម្អិតដែលត្រូវនឹងលក្ខខណ្ឌច្បាប់ ហើយនាំឱ្យកកើតអានុភាពគតិយុត្ត (អង្គហេតុកើតសិទ្ធិ អង្គហេតុរារាំងសិទ្ធិ អង្គហេតុរលត់សិទ្ធិ និងអង្គហេតុទប់ស្កាត់សិទ្ធិ)។ តួនាទីអង្គហេតុចម្បងនៅក្នុងនីតិវិធីបណ្តឹង អាចជា៖ ១.អង្គហេតុកកើតសិទ្ធិ (អង្គហេតុដែលជាមូលហេតុនៃការទាមទារ) ជាទូទៅអះអាងដោយដើមចោទ ២.អង្គហេតុតវ៉ា(ជាទូទៅអះអាងដោយចុងចម្លើយ) ៣.អង្គហេតុតវ៉ាតប (ជាទូទៅអះអាងដោយដើមចោទ) និង ៤.អង្គហេតុតវ៉ាតបតប (ជាទូទៅអះអាងដោយចុងចម្លើយ) ជាអាទិ៍។

**នៅក្នុងនីតិវិធីបណ្តឹង សកម្មភាពរបស់ចុងចម្លើយឆ្លើយតបនឹងដើមចោទ អាចត្រូវបាកំណត់តាមសកម្មភាព ដូចខាងក្រោយ៖**

[29] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ១២៣ កថាខណ្ឌទី២។

**ក. ការបដិសេធអង្គហេតុ៖** នៅពេលដើមចោទអះអាងអង្គហេតុគាំទ្រពាក្យបណ្តឹង ជាអាទិ៍ នៅក្នុងកិច្ចនៃនីតិវិធីណាមួយ ប្រសិនបើចុងចម្លើយធ្វើសេចក្តីថ្លែងការណ៍ផ្ទុយពីអង្គហេតុរបស់ដើមចោទ គេហៅសកម្មភាពនេះថា "ការបដិសេធអង្គហេតុ"។

**ខ. ការទទួលស្គាល់អង្គហេតុ៖** នៅពេលដើមចោទអះអាងអង្គហេតុគាំទ្រពាក្យបណ្តឹង ជាអាទិ៍ នៅក្នុងកិច្ចនៃនីតិវិធីណាមួយ ប្រសិនបើចុងចម្លើយធ្វើសេចក្តីថ្លែងការណ៍ស្របនឹងអង្គហេតុរបស់ដើមចោទគេហៅសកម្មភាពនេះថា "ការទទួលស្គាល់អង្គហេតុ"។

**គ. ការឆ្លើយថាមិនដឹង៖** នៅពេលដើមចោទអះអាងអង្គហេតុគាំទ្រពាក្យបណ្តឹង ជាអាទិ៍ នៅក្នុងកិច្ចនៃនីតិវិធីណាមួយ ប្រសិនបើចុងចម្លើយធ្វើសេចក្តីថ្លែងការណ៍ថាមិនដឹងអំពីអង្គហេតុរបស់ដើមចោទ ឬស្របនឹងអង្គហេតុរបស់ដើមចោទ ប៉ុន្តែមានអានុភាពរំលត់ គេហៅសកម្មភាពនេះថា "ការតវ៉ាអំពីអង្គហេតុ"។

**ឃ. ការនៅស្ងៀម៖** នៅពេលដើមចោទអះអាងអង្គហេតុគាំទ្រពាក្យបណ្តឹង ជាអាទិ៍ នៅក្នុងកិច្ចនៃនីតិវិធីណាមួយ ប្រសិនបើចុងចម្លើយនៅស្ងៀម គេហៅសកម្មភាពនេះថា "ការសារភាពអំពីអង្គហេតុ" លើកលែងតែតុលាការពិចារណាអំពីដំណើរការក្តី និងខ្លឹមសារនៃរឿងក្តីទាំងមូល ហើយយល់ឃើញថា ភាគីនោះបានតវ៉ាអំពីអង្គហេតុ។

នៅក្នុងនីតិវិធីបណ្តឹង (ទ្រឹស្តីអង្គហេតុចម្បង) ការបដិសេធ និងការតវ៉ា មានខ្លឹមសារខុសគ្នា៖

ការតវ៉ាសំដៅលើអង្គហេតុតវ៉ា គឺជាអង្គហេតុដែលកើតឡើងស្របគ្នា នឹងអង្គហេតុដែលជាមូលហេតុនៃការទាមទារ (អង្គហេតុកកើតសិទ្ធិ) ហើយអានុភាពគតិយុត្តនៃអង្គហេតុតវ៉ា អាចជាការរារាំង ឬការរំលត់ ឬឧបសគ្គនៃសិទ្ធិនូវការកើតឡើងអានុភាពគតិយុត្តនៃអង្គហេតុដែលជាមូលហេតុនៃការទាមទារ។

អង្គហេតុដែលមិនស្របគ្នានឹងមូលហេតុនៃការទាមទារ គឺជាការបដិសេធ មិនមែនជាអង្គហេតុវ៉ានោះទេ ដូចជា ដើមចោទទាមទារឱ្យបង់ប្រាក់ថ្លៃលក់ ផ្អែកលើកិច្ចសន្យាលក់ទិញរថយន្ត ប៉ុន្តែចុងចម្លើយឆ្លើយតបវិញថា មិនមែនជាកិច្ចសន្យាលក់ទិញនោះទេ គឺជាអំណោយ។ ការអះអាងរបស់ចុងចម្លើយបែបនេះហៅថា "ការបដិសេធអង្គហេតុ" ដែលជាមូលហេតុនៃការទាមទារ មិនមែនជា "អង្គហេតុតវ៉ា" នោះទេ។

នៅក្នុងនីតិវិធីបណ្តឹង (ទ្រឹស្តីអង្គហេតុចម្បង) ការទទួលខុសត្រូវក្នុងការបញ្ជាក់ភស្តុតាង គឺជាបន្ទុករបស់ភាគីដែលបានអះអាងអង្គហេតុចម្បង ដែលនាំឱ្យខ្លួនកកើតសិទ្ធិ ហើយភាគីម្ខាងទៀតបដិសេធលើកលែងតែអង្គហេតុនោះមានលក្ខណៈជាក់ស្តែងដូចជា ដើមចោទទាមទារឱ្យបង់ប្រាក់ថ្លៃលក់ ផ្អែកលើកិច្ចសន្យាលក់ទិញរថយន្ត ប៉ុន្តែចុងចម្លើយឆ្លើយតបវិញថា មិនមែនជាកិច្ចសន្យាលក់ទិញនោះទេ គឺជាអំណោយ។ ក្នុងករណីនេះ អ្នកទទួលខុសត្រូវក្នុងការបញ្ជាក់ភស្តុតាង គឺដើមចោទ។[30]

[30] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ១២៣ កថាខណ្ឌទី២។

➢ **ការរៀបចំពិនិត្យភស្តុតាង**

ការរៀបចំភស្តុតាង គឺជាការប្រមូលនូវភស្តុតាងដែលពាក់ព័ន្ធនឹងចំណុចវិវាទ បន្ទាប់ពីបានស្តាប់ការអះអាងរបស់គូភាគី សម្រាប់ជាមូលដ្ឋានឱ្យគូភាគីធ្វើការបំភ្លឺ និងសម្រាប់ជាមូលដ្ឋានក្នុងការវិនិច្ឆ័យរបស់តុលាការនៅពេលធ្វើការទាញហេតុផលដោយផ្ទាល់មាត់។ ការរៀបចំភស្តុតាង មិនមែនជានីតិវិធីពិនិត្យភស្តុតាងនោះទេ ពោលគឺតុលាការស្តាប់ពីការអះអាងរបស់ ភាគី និងកំណត់ពីចំណុចវិវាទ ដែលភាគីនៃបណ្តឹងមិនស្របគ្នា ហើយរៀបចំភស្តុតាងដែលពាក់ព័ន្ធនឹងចំណុចវិវាទនៃបណ្តឹង តុលាការអាចពិនិត្យភស្តុតាងជាឯកសារបាន ឬការចាត់ចែងថែរក្សាភស្តុតាង ដូចជាការសាកសួរសាក្សីដែលមានជំងឺធ្ងន់ធ្ងរដែលអាចមានគ្រោះថ្នាក់ដល់ជីវិត ជាអាទិ៍។[31]

នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី បានកំណត់អំពីមធ្យោបាយផ្ទុកភស្តុតាងដែលមានចំនួន ០៥ ប្រភេទដូចជាៈ

(ក). **ការសាកសួរសាក្សី**

ប្រសិនបើចំណុចវិវាទត្រូវបញ្ជាក់ដោយភស្តុតាងជាសាក្សី ភាគីដែលទទួលខុសត្រូវក្នុងការបញ្ជាក់ ត្រូវដាក់ពាក្យស្នើសុំសាកសួរសាក្សី ដែលត្រូវធ្វើឡើងដោយ កំណត់ឱ្យបានច្បាស់លាស់ទៅលើសាក្សីមួយណាដែលមានចំណុចសារជាតុមួយចំណាយណដូចជាៈ ១.បញ្ជាក់ឱ្យបានច្បាស់លាស់ទៅលើអត្តសញ្ញាណសាក្សី និង ២.បញ្ជាក់អំពីចំណុចដែលត្រូវសួរសាក្សិ (បញ្ជីសំណួរ) ។ ភាគីដែលស្នើសុំសាកសួរសាក្សី ត្រូវភ្ជាប់ជាមួយនូវឯកសារដែលកំណត់អំពីចំណុចដែលត្រូវសាកសួរ។ សាក្សីត្រូវទទួលការកោះហៅយ៉ាងតិច ពីរ សប្តាហ៍ មុនថ្ងៃសាកសួរ។ នៅក្នុងដីកាកោះហៅសាក្សី ត្រូវសរសេរនូវកំណត់សំគាល់ឱ្យបានច្បាស់ ហើយត្រូវភ្ជាប់មកជាមួយនូវឯកសារដែលកំណត់អំពីចំណុចសាកសួរដូចជាៈ ១.ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់ភាគី ២.ពេលវេលា និងទីកន្លែងដែលត្រូវចូលខ្លួន និង ៣.ទណ្ឌកម្មដែលកំណត់ដោយច្បាប់ នឹងកើតមនា បើមិនចូលខ្លួន។[32]

(ខ). **ការសាកសួរភាគី**

ប្រសិនបើចំណុចវិវាទត្រូវបញ្ជាក់ដោយភស្តុតាង ប៉ុន្តែភាគីយល់ថាភាគីម្ខាងទៀត គប្បីផ្តល់ចម្លើយ ភាគីដែលទទួលខុសត្រូវក្នុងការបញ្ជាក់ ត្រូវដាក់ពាក្យស្នើសុំសាកសួរសាមីភាគី។[33]

តុលាការអាចធ្វើការសាកសួរសាមីភាគីបាន ក្នុងករណីនេះ តុលាការអាចឱ្យភាគីនោះស្បថបាន។ ក្នុងករណីដែលធ្វើការសាកសួរសាមីភាគី បើភាគីនោះពុំចូលខ្លួន ឬបដិសេធនូវការធ្វើសម្បថ ឬ ផ្តល់ចម្លើយ ដោយគ្មានមូលហេតុត្រឹមត្រូវ នោះតុលាការអាចទទួលស្គាល់ថា សេចក្តីអះអាងអំពីចំណុចសាកសួររបស់ភាគីម្ខាងទៀត ជាការពិតបាន។ ប្រសិនបើ ភាគីដែលបានស្បថក្លែងបន្លំសេចក្តីថ្លែងការណ៍ តុលាការអាចពិន័យជាប្រាក់

[31] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ១៦៣ កថាខណ្ឌទី១។

[32] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ១៣៨។

[33] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ១៤១ កថាខណ្ឌទី១។

ចំនួនមិនលើសពី ២.០០០.០០០ (ពីរលាន) រៀលបាន ដោយដីកាសម្រេច ប៉ុន្តែដីកាសម្រេចនេះអាចធ្វើការជំទាស់បាន។[34]

**(គ). កោសលវិច័យ**

ប្រសិនបើចំណុចវិវាទត្រូវបញ្ជាក់ដោយភស្តុតាង ចំពោះភាពមិនប្រក្រតីទៅលើឯកសារជាក់លាក់ណាមួយ ដែលខ្លួនយល់ថាមានប្រយោជន៍ស្របច្បាប់ក្នុងការបំភ្លឺចំណុចវិវាទ ភាគីដែលទទួលខុសត្រូវក្នុងការបញ្ជាក់ត្រូវដាក់ពាក្យស្នើសុំធ្វើកោសលវិច័យ ដែលមានចំណុចសារធាតុមួយចំនួនដូចជា៖ ១.ភ្ជាប់ឯកសារដោយកំណត់អំពីចំណុចដែលស្នើសុំធ្វើកោសលវិច័យ និង ២.ផ្ញើឯកសារអំពីចំណុចដែលត្រូវធ្វើកោសលវិច័យទៅអ្នកជំនាញ។ ជាទូទៅ ដើម្បីអាចធ្វើកោសលវិច័យបាន លុះត្រាតែមានឯកសារច្បាប់ដើម។[35] អ្នកជំនាញខាងកោសលវិច័យត្រូវបានចាត់តាំងដោយតុលាការ។ ជនដែលមានចំណេះវិជ្ជា និងបទពិសោធន៍ចាំបាច់ក្នុងការធ្វើកោសលវិច័យ មានករណីយកិច្ចធ្វើកោសលវិច័យ។[36]

**(ឃ). ភស្តុតាងជាឯកសារ**

ប្រសិនបើចំណុចវិវាទត្រូវបញ្ជាក់ដោយភស្តុតាងជាឯកសារ ភាគីដែលទទួលខុសត្រូវក្នុងការបញ្ជាក់ ត្រូវដាក់ពាក្យស្នើសុំពិនិត្យភស្តុតាងជាឯកសារ ដែលមានចំណុចសារធាតុមួយចំនួនដូជា៖ ១.ផ្តល់ឯកសារដែលសាមីភាគីមាន ឬ ២.ដាក់ពាក្យសុំទៅតុលាការបង្គាប់ឱ្យម្ចាស់ឯកសារផ្តល់នូវឯកសារមកតុលាការ។ ក្នុងករណីដែលយល់ឃើញថា ចាំបាច់ តុលាការអាចឃាត់ទុកនូវឯកសារដែលបានផ្តល់មក ឬផ្ញើមកបាន។[37] ក្នុងករណីដែលការស្នើសុំឱ្យពិនិត្យភស្តុតាងជាឯកសារដែលសរសេរជាភាសាបរទេស ភាគីដែលស្នើសុំត្រូវភ្ជាប់មកជាមួយនូវសេចក្តីបកប្រែត្រង់ចំណុចដែលខ្លួនសុំឱ្យពិនិត្យនោះ។

ជាទូទៅ ឯកសារដែត្រូវបានធ្វើឡើងដោយមន្ត្រីរាជការនៅក្នុងមុខនាទី ដោយផ្អែកទៅលើទម្រង់ និងខ្លឹមសារនៃឯកសារនោះត្រូវបានសន្មតថាជាឯកសារសាធារណៈ ដែលបានធ្វើឡើងដោយត្រឹមត្រូវ ដូចជាវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ដែលបានធ្វើ និងចេញដោយ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាអាទិ៍ ត្រូវបានចាត់ទុកថាជាឯកសារសាធារណៈដែលបានធ្វើឡើងដោយត្រឹមត្រូវ (តុលាការមានទំនុកចិត្ត)។[38]

---

[34] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ១៤០។

[35] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ១៤៣។

[36] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ១៤៤ កថាខណ្ឌទី១ និងទី២។

[37] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ១៤៨។

[38] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ១៥៥ កថាខណ្ឌទី២។

### (ង). ការត្រួតពិនិត្យវត្ថុដែលជាកម្មវត្ថុ

ប្រសិនបើចំណុចវិវាទត្រូវបញ្ជាក់ដោយភស្តុតាងជាវត្ថុ ភាគីដែលទទួលខុសត្រូវក្នុងការបញ្ជាក់ ត្រូវដាក់ពាក្យស្នើសុំឱ្យត្រួតពិនិត្យវត្ថុ ដែលមានចំណុចសារធាតុមួយចំនួនដូចជា៖ ១.ផ្ញើមកនូវវត្ថុដែលត្រូវត្រួតពិនិត្យ ឬ ២.ដាក់ពាក្យសុំទៅតុលាការបង្គាប់ឱ្យម្ចាស់វត្ថុផ្តល់នូវវត្ថុមកតុលាការ។ ក្នុងករណីតតិយជនមិនព្រមធ្វើតាមដីកាសម្រេចបង្គាប់ឱ្យបង្ហាញ តុលាការអាចពិន័យជាប្រាក់ចំនួនមិនលើសពី ២.០០០.០០០ (ពីរលាន) រៀលបាន ដោយដីកាសម្រេច ប៉ុន្តែដីកាសម្រេចនេះអាចធ្វើការជំទាស់បាន។[39] ជាទូទៅ វត្ថុដែលត្រូវត្រួតពិនិត្យសម្រាប់ជាមធ្យោបាយផ្ទុកភស្តុតាង អាចជាកាំបិត ឬឧបករណ៍ប្រព្រឹត្តបទល្មើសផ្សេងៗ ជាអាទិ៍ (ករណីទាមទារប្រាក់ ផ្អែកលើអំពើអនីត្យានុកូល)។

**ឧទាហរណ៍៖** X បានឱ្យ Y ខ្ចីប្រាក់ចំនួន ២០លានរៀល នៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០០ ហើយ X មិនទាន់បានទទួលប្រាក់សំណងវិញនៅឡើង បើទោះបីជាកាលកំណត់ត្រូវសង បានមកដល់ថ្ងៃទី១០ ខែធ្នូម្ល៉េះក្តី។ ក្នុងករណីនេះ ប្រសិនបើ X បានដាក់ពាក្យបណ្តឹងទាមទារឱ្យសងប្រាក់ ២០លានរៀលនោះ ហើយ Y បានថ្លែងថា គាត់មិនបានខ្ចីប្រាក់ពី X ចំនួន ២០លានរៀលនោះទេ នៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០០ នោះទេ បញ្ហាដែលថាតើកិច្ចសន្យាខ្ចីប្រាប់ចំនួន ២០លានរៀល ត្រូវបានធ្វើឡើងរវាង X និង B កាលពីថ្ងៃទី១០ ខែសីហា ឆ្នាំ២០០០ មែន ឬមិនមែននោះ នឹងក្លាយទៅជាចំណុចវិវាទនៃរឿងក្តី។ ក៏ប៉ុន្តែ នៅក្នុងករណីជាក់ស្តែង ចំណុចវិវាទពិតប្រាកដ (ចំណុចវិវាទស្នូល) មិនចាត់ទុកថាបានបញ្ជាក់តែដោយចំណុចនេះឡើង។ ប្រសិនបើ X បំភ្លឺអំពីកាលៈទេសៈដែលនាំទៅដល់ការខ្ចីប្រាក់ ព្រមទាំងរឿងរ៉ាវលំអិតអំពីពេលវេលា ដែល X បានឱ្យប្រាក់ទៅ Y ខ្ចី ជាអាទិ៍ផងដែរ។ ជាលទ្ធផល ក្នុងការឆ្លើយតបទៅនឹងការបង្គាប់ឱ្យបំភ្លឺ A បានថ្លែងថា តាមការពិតគឺ Z ដែលជាកូនប្រុសច្បងរបស់ Y ទេ ដែលបានមកកាន់ការិយាល័យរបស់ខ្លួន ហើយសុំខ្ចីប្រាក់ ក្នុងនាមរបស់ Y ពោលគឺមិនមែន Y ជាអ្នកខ្ចីដោយផ្ទាល់ឡើយ។ X បានប្រគល់មូលប្បទានប័ត្រលើទឹកប្រាក់ចំនួន ២០លានរៀល ទៅឱ្យ Z ដោយសាថា Z មានលិខិតប្រគល់សិទ្ធិតំណាងក្នុងនាមរបស់ Y ហើយ X ជឿទុកចិត្តលើលិខិតនោះ។ តុលាការ ត្រូវបង្គាប់ឱ្យ Y ធ្វើការឆ្លើយតបចំពោះការអះអាងលើអង្គហេតុបែបនេះ របស់ X ។ ហេតុដូច្នេះ នៅក្នុងករណីនេះ ចំណុចវិវាទពិតប្រាកដនៃរឿងក្តី គឺនៅត្រង់ថាតើមានអង្គហេតុដែល Y បានប្រគល់សិទ្ធិអំណាចឱ្យ Z ធ្វើជាអ្នកតំណាងរបស់ខ្លួនដែរឬទេ។ ជាងនេះទៅទៀត ក្នុងករណីដែលតុលាការបានបង្គាប់ឱ្យ X ដាក់លិខិតប្រគល់សិទ្ធិតំណាងក្នុងនាមរបស់ Y ដែលខ្លួនបានទទួលពី Z នោះ និង បានបង្គាប់ឱ្យ Y ធ្វើការបញ្ជាក់អំពីបញ្ហានេះ ប្រសិនបើ Y បានបដិសេធអំពីភាពត្រឹមត្រូវនៃហត្ថលេខា នោះចំណុចវិវាទពិតប្រាកដ កាន់តែត្រូវបានបង្រួមតូចរហូតដល់ភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវ នៃហត្ថលេខានៅលើលិខិតប្រគល់សិទ្ធិនោះហើយ។

អាស្រ័យហេតុនេះ តុលាការ ធ្វើការកំណត់នូវចំណុចវិវាទនៃរឿងក្តីនេះ តាមរយៈការបង្គាប់ឱ្យភាគីធ្វើការបំភ្លឺអំពីអង្គហេតុផ្សេងៗ ដែលពាក់ព័ន្ធទៅនឹងអង្គហេតុដែលជាមូលហេតុផ្ទាល់នៃការបង្កើតសិទ្ធិ ដែលដើមចោទ

[39] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ១៦២។

បានអះអាង និង អំពីរឿងរ៉ាវលំអិតនៃរឿងក្តី និងតាមរយៈការបង្គាប់ឱ្យភាគីធ្វើការបន្ថែម កែប្រែ ឬដកចេញនូវការអះអាងរបស់ខ្លួន។ តាមរយៈមុខងារនេះ ចំណុចវិវាទពិតប្រាកដត្រូវបានកំណត់ និង ត្រូវបានទទួលស្គាល់រួមគ្នាដោយតុលាការ និងភាគីទាំងសងខាង។

បន្ទាប់ពីបានកំណត់នូវចំណុចវិវាទពិតប្រាកដហើយ តុលាការត្រូវកំណត់នូវភស្តុតាងពាក់ព័ន្ធនឹងចំណុចវិវាទនោះ ដែលត្រូវធ្វើការពិនិត្យ។ យោងតាមឧទាហរណ៍ខាងលើនេះ អាចយល់បានថា ភស្តុតាងដែលត្រូវពិនិត្យប្រែប្រួលទៅតាមអ្វីដែលជាចំណុចវិវាទ។ ក្នុងករណីដែលសុពលភាពនៃកិច្ចសន្យាខ្ចីបរិភោគ គឺជាចំណុចវិវាទនោះលិខិតកិច្ចសន្យានោះ និង សាក្សីដែលបាននៅកន្លែងចុះកិច្ចសន្យា គឺជាភស្តុតាងដ៏សំខាន់។ រីឯក្នុងករណីដែលអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិតំណាងដែលប្រគល់ឱ្យ Z គឺជាចំណុចវិវាទវិញនោះចាំបាច់ត្រូវធ្វើការសាកសួរ Z ក្នុងឋានៈជាសាក្សី។ ម៉្យាងវិញទៀត ប្រសិនបើភាពត្រឹមត្រូវរៃហត្ថលេខារបស់ Y នៅលើលិខិតប្រគល់សិទ្ធិ គឺជាចំណុចវិវាទវិញនោះ ការធ្វើកោលសវិច័យទៅលើអក្សរដៃ គឺជាការពិនិត្យភស្តុតាងយ៉ាងសំខាន់។ ចំណុចនេះក៏បញ្ជាក់ផងដែរ អំពីសារៈសំខាន់នៃការរៀបចំការអះអាង និង ការរៀបចំចំណុចវិវាទ នៅក្នុងការជម្រះក្តីលើបណ្តឹង។

### (ខ) សកម្មភាពបណ្តឹងដែលអាចធ្វើបាន នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការអាចធ្វើសកម្មភាពចាំបាច់នានា ដើម្បីរៀបចំការអះអាងរបស់ភាគី កំណត់ចំណុចវិវាទ និង រៀបចំភស្តុតាងដែលត្រូវពិនិត្យនៅពេលទាញហេតុផលដោយផ្ទាល់មាត់។ ប៉ុន្តែក៏មានការដាក់កម្រិតមួយចំនួនទៅលើសកម្មផាពដែលអាចអនុញ្ញាតឱ្យធ្វើការបានដែរ ដោយសារថានីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ មិនបើកជាសាធារណៈ។ តុលាការអាចស្តាប់ពាក្យសុំ និង ការអះអាងរបស់ភាគីសងខាង ហើយអាចចេញដីកាសម្រេចទៅលើការស្នើសុំឱ្យពិនិត្យភស្តុតាង (ឧទាហរណ៍ ដីកាសម្រេចទទួលយក ឬ មិនទទួលយកនូវភស្តុតាងដែលត្រូវបានស្នើសុំឱ្យពិនិត្យ ដីកាសម្រេចបង្គាប់ឱ្យធ្វើកោសលវិច័យ ដីកាសម្រេចបង្គាប់ឱ្យផ្តល់ឯកសារ[40] ជាអាទិ៍ ព្រមទាំងដីកាសម្រេចផ្សេងទៀត ដែលក្រមនីតិវិធីរដ្ឋប្បវេណីអនុញ្ញាតឱ្យធ្វើ ក្រៅពីកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ (សេចក្តីសម្រេចអំពីការអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យធ្វើការបន្ថែម ឬ ផ្លាស់ប្តូរកម្មវត្ថុនៃបណ្តឹង ដីកាសម្រេចអំពីការអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យចូលរួមអន្តរាគមន៍ ជាអាទិ៍។[41] ម៉្យាងទៀត តុលាការក៏អាចធ្វើការពិនិត្យទៅលើភស្តុតាងជាឯកសារ ត្រឹមកម្រិតដែលចាំបាច់ដើម្បីរៀបចំចំណុចវិវាទ និងភស្តុតាងបានដែរ។[42]

ជាមូលដ្ឋាន ការពិនិត្យភស្តុតាង ត្រូវធ្វើឡើងនៅពេលធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ដែលត្រូវបើកជាសាធារណៈ ក៏ប៉ុន្តែដើម្បីកំណត់ចំណុចវិវាទពិតប្រាកដ តាមរយៈការរៀបចំការអះអាងរបស់ភាគី តុលាការ

[40] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ១២៦ ១៤៣ និង១៥២។

[41] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៤៥ កថាខណ្ឌទី១ និងមាត្រា៨៤ កថាខណ្ឌទី៤។

[42] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ១០៦។

ចាំបាច់ត្រូវធ្វើការពិនិត្យលើឯកសារដែលភាគីបានដាក់ ហើយការពិនិត្យភស្តុតាងជាឯកសារនេះ ត្រូវធ្វើឡើងដោយចៅក្រមអានឯកសារនោះ ហេតុដូច្នេះហើយ អត្ថន័យនៃការពិនិត្យ ភស្តុតាងជាឯកសារនេះ នៅក្នុងសាលសវនាការជាសាធារណៈមិនសំខាន់ដូចការសាកសួរសាក្សីនោះទេ។ ហេតុនេះហើយបានជាក្រមនីតិវិធិរដ្ឋប្បវេណីអនុញ្ញាតឱ្យតុលាការ អាចធ្វើការពិនិត្យភស្តុតាងជាឯកសារ នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបានត្រឹមកម្រិតដែលចាំបាច់ដើម្បីរៀបចំចំណុចវិវាទ។

**ឧទាហរណ៍៖** ក្នុងករណីដែលចុងចម្លើយតវ៉ាចំពោះអង្គហេតុនៃការបង្កើតកិច្ចសន្យាលក់ទិញ ហើយព្រមជាមួយគ្នានោះ ចុងចម្លើយអះអាងថា ទោះបីជាការបង្កើតកិច្ចសន្យាលក់ទិញនោះ ត្រូវបានទទួលស្គាល់ក៏ដោយ ក៏ខ្លួនលុបចោលកិច្ចសន្យានោះ ដោយហេតុថាការបង្ហាញឆន្ទៈបង្កើតកិច្ចសន្យានោះ ត្រូវបានធ្វើឡើងដោយការឆបោក ប្រសិនបើការបង្កើតកិច្ចសន្យាលក់ទិញនោះ ត្រូវបានទទួលស្គាល់ ដោយពិនិត្យលិខិតកិច្ចសន្យានោះដែលដើមចោទដាក់ទៅតុលាការ នោះតុលាការអាចប្រើវិធីនេះដើម្បីរៀបចំចំណុចវិវាទបាន។ ក៏ប៉ុន្តែចំពោះការពិនិត្យភស្តុតាង ដូចជាការសាកសួរសាក្សី និងកោសលវិច័យជាអាទិ៍ មិនអាចធ្វើឡើងបាននៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលទេ។

### (គ) ការបំបែក និងរួមបញ្ចូលរឿងក្តី នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នៅក្នុងដំណើរការនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ប្រសិនបើយល់ឃើញថាចាំបាច់ តុលាការអាចបំបែករឿងក្តីមួយ ទៅជារឿងក្តីផ្សេងៗ ហើយធ្វើការជម្រះក្តីលើរឿងក្តីទាំងនោះដោយដាច់ពីគ្នាបាន។ នេះហៅថា ការបំបែករឿងក្តី។[43]

**ឧទាហរណ៍៖** ប្រសិនបើនៅក្នុងបណ្តឹងតែមួយ ដើមចោទបានទាមទារឱ្យចុងចម្លើយសងប្រាក់កំចីផង និងបង់ប្រាក់ថ្លៃលក់ទិញផង[44] តុលាការ អាចបំបែកការទាមទារឱ្យបង់ប្រាក់ថ្លៃលក់ទិញ ចេញពីបណ្តឹងនោះ ហើយធ្វើការជម្រះដាច់ដោយឡែកបាន។

បញ្ច្រាសទៅវិញ តុលាការក៏អាចរួមបញ្ចូលរឿងក្តីផ្សេងៗ ដែលកំពុងត្រូវបានចាត់ការនៅក្នុងតុលាការតែមយយ ហើយធ្វើការជម្រះក្តីសរុប ដោយនីតិវិធីតែមួយបានដែរ។ នេះហៅថា ការរួមបញ្ចូលរឿងក្តី ។ ទោះបីជាក្នុងករណីដែលការទាមទារពីរយ៉ាង ត្រូវបានដាក់ក្នុងបណ្តឹងតែមួយក៏ដោយ ប្រសិនបើការទាមទារនីមួយៗ មានខ្លឹមសារពាក់ព័ន្ធគ្នាតែបន្តិចបន្តួច ហើយការជំនុំជម្រះលើការទាមទារមួយ អាចនឹងធ្វើបានឆាប់ជាការទាមទារមួយទៀត នោះជាការសមស្របដែលត្រូវបំបែករឿងក្តី។[45] ម៉្យាងវិញទៀត ក្នុងករណីដែលរឿងក្តីជាច្រើនដែល

[43] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៩៩ កថាខណ្ឌទី១។

[44] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៧៧។

[45] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៩៩ កថាខណ្ឌទី១។

មានខ្លឹមសារទាក់ទងគ្នា កំពុងត្រូវបានចាត់ការដាច់ដោយឡែកពីគ្នា ជាញឹកញាប់វាជារឿងសមហេតុផលក្នុងការជំនុំជម្រះរឿងក្តីទាំងអស់នេះរួមគ្នា តាមរយៈការរួមបញ្ចូលរឿងក្តី។ [46]

**២.១.១.៤ ដីកាសម្រេចដែលមិនមែនជាសាលក្រម**

ដីការសម្រេច គឺជាសេចក្តីសម្រេចដែលតុលាការ ឬ ចៅក្រមអាចធ្វើដោយមិនឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់ ហើយមិនមែនជាសាលក្រម។[47] ជាគោលការណ៍ ការចេញដីកាសម្រេចមិនចាំបាច់ឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់ទេ ព្រោះថាដីកាសម្រេច តែចំណុចបន្ទាប់បន្សំនៃនីតិវិធីប៉ុណ្ណោះ។ ច្បាប់បានទុកលទ្ធភាពឱ្យចៅក្រមសម្រេចថា តើត្រូវឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់ ឬអត់ ដោយយោងតាមករណីនីមួយៗ ហើយទោះបីជាមិនឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់ក៏ដោយ តុលាការអាចសួរភាគីបានពោលគឺ តុលាការផ្តល់ឱកាសឱ្យភាគីធ្វើសេចក្តីថ្លែងការណ៍ដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរទាក់ទងនឹងចំណុចដែលត្រូវសម្រេច ដោយដីកាសម្រេច។[48] ផ្ទុយទៅវិញ ជាគោលការណ៍សាលក្រម ត្រូវសម្រេចដោយឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់ លើកលែងតែករណីពិសេសដែលមានបញ្ញត្តិក្នុងច្បាប់។

ដីកាសម្រេចនឹងមានអានុភាពលុះត្រាតែបានជូនដំណឹងតាមវិធីដែលទទួលស្គាល់ថាសមរម្យ។[49] ហេតុនេះ ចំពោះដីកាសម្រេចធ្វើដោយផ្ទាល់មាត់ចំពោះមុខភាគី ដីកាសម្រេចនឹងបង្កើតអានុភាពអនុវត្តភ្លាម នៅពេលដែលតុលាការ ឬ ចៅក្រមសម្រេចសេចក្តីនោះ។ ចំពោះដីកាសម្រេចដែលត្រូវធ្វើជាលាយលក្ខណ៍អក្សរចៅក្រមត្រូវចុះហត្ថលេខា ហើយជូនដំណឹងពីដីកាសម្រេចនោះទៅដល់ភាគីអ្នកពាក់ព័ន្ធ ហើយមានអានុភាពភ្លាមតែម្តង លើកលែងតែករណីផ្សេងកំណត់ដោយច្បាប់។[50] នៅពេលជូនដំណឹងអំពីដីកាសម្រេច ក្រឡាបញ្ជីត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់នូវហេតុការណ៍ និងវិធីនៃការជូនដំណឹងនោះដាក់នៅក្នុងសំណុំរឿង។[51]

**ឧទាហរណ៍៖** ចំពោះដីកាសម្រេចដាស់តឿន កំណត់ថាដីកាសម្រេចដាស់តឿនត្រូវមានអានុភាព នៅពេលដែលបានបញ្ជូនទៅដល់កូនបំណុល។

ដីកាសម្រេចដែលមានគោលដៅត្រឹមតែដឹកនាំនីតិវិធីបណ្តឹង អាចលុបចោលនាពេលណាក៏បាន[52] ដោយហេតុថា ដីកាសម្រេចមានពីរប្រភេទគឺ ដីកាដែលមានគោលបំណង ចាត់ការលើការដឹកនាំ នីតិវិធីបណ្តឹង និង ដីកាដែលមានគោលបំណងដើម្បីចាត់ចែងចំណុចបន្ទាប់បន្សំក្នុងការវិនិច្ឆ័យបណ្តឹង។

[46] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៩៩ កថាខណ្ឌទី២។
[47] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ១៧៩ កថាខណ្ឌទី២។
[48] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ១១៤ កថាខណ្ឌទី២។
[49] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ២១៣ កថាខណ្ឌទី១។
[50] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ២១៣ កថាខណ្ឌទី១។
[51] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ២១៣ កថាខណ្ឌទី៣។
[52] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ២១៤។

**ឧទាហរណ៍៖** ដីកាសម្រេចអំពីពាក្យសុំដីសុំពិនិត្យភស្តុតាង មានអានុភាពសម្រាប់តែភាគីដែលពាក់ព័ន្ធប៉ុណ្ណោះ។

ចំពោះការប្ដឹងជំទាស់ដីកាសម្រេចវិញ មិនសុទ្ធតែអាចប្ដឹងជំទាស់បាននោះទេ គឺលុះត្រាតែមានច្បាប់ចែងអនុញ្ញាតឱ្យប្ដឹងជំទាស់បាន ទើបអាចប្ដឹងជំទាស់បាន។[53] ក្រមនីតិវិធីរដ្ឋប្បវេណីមិនអនុញ្ញាតឱ្យប្ដឹងជំទាស់រាល់ដីកាសម្រេចទាំងអស់នោះបានទេ ព្រោះថាក្នុងករណីខ្លះការអនុញ្ញាតឱ្យប្ដឹងជំទាស់ អាចធ្វើឱ្យអូសបន្លាយនីតិវិធីឥតប្រយោជន៍។ ហេតុនេះហើយ ដីកាសម្រេចដែលសម្រេចថា ការដកហូត ឬ បណ្ដឹងជិតចិត្តមានមូលហេតុត្រឹមត្រូវនោះ មិនអាចប្ដឹងឧបាស្រ័យឡើង។[54] ដូចគ្នាដែរចំពោះ ដីកាសម្រេចបែងចែករឿងក្ដី ឬ កែប្រែលំដាប់បែងចែករឿងក្ដី ក្រមនីតិវិធីរដ្ឋប្បវេណីពុំបានចែងអំពីការហាមឃាត់ ឬ អនុញ្ញាតការប្ដឹងជំទាស់នោះទេ ហេតុនេះបានន័យថាពុំអាចប្ដឹងជំទាស់បានឡើយ។

ការប្ដឹងជំទាស់ត្រូវដាក់ពាក្យទៅតុលាការដើមនៅក្នុងអំឡុងពេលមួយសប្ដាហ៍ គិតចាប់តាំងពីថ្ងៃទទួលដំណឹងអំពីដីកាសម្រេច។[55] តុលាការដើមត្រូវធ្វើឱ្យបានឆាប់រហ័សនូវពាក្យបណ្ដឹងជំទាស់ និង សំណុំរឿងទៅតុលាការនៃបណ្ដឹងជំទាស់។ ក្នុងករណីដែលពុំបានសរសេរច្បាស់លាស់ អំពីមូលហេតុនៃការទាមទារឱ្យតុលាការលុបចោល ឬផ្លាស់ប្ដូរនូវដីកាសម្រេចដើមក្នុងពាក្យបណ្ដឹងជំទាស់ទេ ម្ចាស់បណ្ដឹងជំទាស់គប្បីដាក់លិខិតជាលាយលក្ខណ៍អក្សរ ដែលសរសេរអំពីចំណុចនោះទៅតុលាការនៃបណ្ដឹងជំទាស់នៅក្នុងអំឡុងពេលពីរសប្ដាហ៍ គិតចាប់តាំងពីថ្ងៃដែលបានដាក់ពាក្យបណ្ដឹងជំទាស់នោះ។ អំឡុងពេលមួយសប្ដាហ៍នេះ មិនអាចពន្យាបានឡើយ។ បណ្ដឹងជំទាស់ត្រូវផ្អាកអានុភាពនៃដីកាសម្រេចដើម។ តុលាការដែលសម្រេចលើបណ្ដឹងជំទាស់ចេញដីកាសម្រេចមិនអាចប្ដឹងជំទាស់បានទៀតទេ។[56] បានន័យថា ដីកាសម្រេចពុំអាច ត្រូវបានប្ដឹងជំទាស់លើកទី២បានឡើយ។[57]

### ២.១.២ សកម្មភាពភាគី

ការត្រៀមរៀបចំសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ ត្រូវចាប់ផ្ដើមដោយសេចក្ដីថ្លែងការណ៍អំពីពាក្យបណ្ដឹង របស់ដើមចោទ និងអំពីខ្លឹមសារនៃសាលក្រមដែលចោទទាមទារ (នៅក្នុងករណីដាក់ស្ដែង ដើម្បីសាកល្បងធ្វើការផ្សះផ្សាចាំបាច់ត្រូវដឹងជាមុនអំពីខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ)។ ដូច្នេះមុននឹងសាកល្បងធ្វើការផ្សះផ្សា តុលាការអាចបង្គាប់ឱ្យដើមចោទ ធ្វើសេចក្ដីថ្លែងការណ៍អំពីពាក្យបណ្ដឹងបាន។ ក្នុងករណីបែបនេះ តុលាការមិនចាំបាច់ឱ្យដើមចោទធ្វើសេចក្ដីថ្លែងការណ៍អំពីបណ្ដឹងម្ដងទៀតនៅក្រោយពេលសាកល្បងធ្វើការផ្សះផ្សាទេ)។ ដោយសារថា សាលក្រមដែលដើមចោទទាមទារ មានសរសេរនៅក្នុងខ្លឹមសារ

[53] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ២៥៩ កថាខណ្ឌទី២ និងទី៣។
[54] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៣០។
[55] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៣០៣។
[56] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៣០៥។
[57] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ២៥៩ កថាខណ្ឌទី៣។

នៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការ ក្នុងពាក្យបណ្ដឹង[58] ហេតុនេះហើយ ពាក្យសុំនេះ ត្រូវធ្វើឡើងក្នុងរូបភាពជាសេចក្ដីថ្លែងការណ៍អំពីពាក្យបណ្ដឹង។

ដោយសេចក្ដីថ្លែងការណ៍នេះ កម្មវត្ថុចម្បងសម្រាប់ការត្រៀមរៀបចំនៅពេលបន្តបន្ទាប់ទៀត ត្រូវបានកំណត់។ មានន័យថា នីតិវិធីជាបន្តបន្ទាប់ទៅទៀត ត្រូវរៀបចំឡើងដោយយោងទៅលើករណីដែលថា តើតុលាការ គួរចេញសាលក្រមដែលដើមចោទទាមទារ ឬមិនគួរ។ នៅពេលដែលធ្វើសេចក្ដីថ្លែងការណ៍អំពីពាក្យបណ្ដឹងហើយ លើកលែងតែករណីដែលចុងចម្លើងទទួលស្គាល់ការទាមទារ[59] ជាធម្មតា ចុងចម្លើយតែងតែសុំឱ្យតុលាការចេញសាលក្រមប្រានចោលនូវការទាមទាររបស់ដើមចោទ ដោយអះអាងថា ការទាមទារនោះពុំមានមូលដ្ឋានត្រឹមត្រូវ ឬ ដាក់ពាក្យសុំឱ្យតុលាការចេញសាលក្រមលើកបណ្ដឹងចោល ដោយអះអាងថា ការបំពេញល័ក្ខខណ្ឌក្នុងបណ្ដឹង មិនបានគ្រប់គ្រាន់ (ប្រសិនបើបានដាក់ឯកសារចម្លើយ ពាក្យសុំនេះក៏នឹងត្រូវធ្វើឡើង ក្នុងរូបភាពជាសេចក្ដីថ្លែងការណ៍អំពីឯកសារចម្លើយនោះដែរ)។ ពាក្យសុំទាក់ទងទៅនឹងរឿងក្ដីតែម្ដង ដែលតុលាការត្រូវឆ្លើយតបតាមរយៈសាលក្រមចុងក្រោយដូចជា ពាក្យសុំរបស់ដើមចោទឱ្យចេញសាលក្រតាមពាក្យបណ្ដឹង និង ពាក្យសុំរបស់ចុងចម្លើយឱ្យលើកចោលបណ្ដឹង ឬ ឱ្យប្រានចោលការទាមទាររបស់ដើមចោទ គេហៅថា ពាក្យសុំលើអង្គសេចក្ដីនៃរឿងក្ដី។

បន្ទាប់ពីបានដាក់ពាក្យសុំលើអង្គសេចក្ដីនៃរឿងក្ដីហើយ ដើមចោទនឹងធ្វើសេចក្ដីថ្លែងការណ៍គាំទ្រពាក្យសុំរបស់ខ្លួន ហើយចុងចម្លើយក៏នឹងធ្វើសេចក្ដីថ្លែងការណ៍គាំទ្រពាក្យសុំរបស់ខ្លួនដែរ។ សេចក្ដី-ថ្លែងការណ៍របស់ដើមចោទ គេហៅថា មធ្យោបាយតទល់ (វិធីតទល់) រីឯសេចក្ដីថ្លែងការណ៍របស់ចុងចម្លើយវិញ គេហៅថា មធ្យោបាយការពារខ្លួន (វិធីការពារខ្លួន)។

### ២.១.២.១ ដើមចោទ

នៅក្នុងចំណោមមធ្យោបាយតទល់របស់ដើមចោទ ជាដំបូង ដើមចោទធ្វើសេចក្ដីថ្លែងការណ៍នូវការអះអាងអំពីសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត ដែលជាការទាមទារតាមផ្លូវបណ្ដឹង។ ប៉ុន្តែ ដោយសារថា អត្ថិភាព ឬ នត្ថិភាព នៃសិទ្ធិជាក់លាក់ណាមួយ មិនអាចទទួលស្គាល់ដោយផ្ទាល់បាន ហេតុនេះហើយ តុលាការត្រូវប្រើប្រាស់នូវវិធីធ្វើសេចក្ដីសន្និដ្ឋានតាមភាពសមហេតុផល ដើម្បីធ្វើការកំណតនូវអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិនោះ។ មានន័យថា ជាដំបូងត្រូវកំណត់ថា តើសិទ្ធិនោះត្រូវបានទទួលស្គាល់ថាបានបង្កើតឡើងពីមុនមកដែរឬទេ ហើយប្រសិនបើសិទ្ធិនោះត្រូវបានទទួលស្គាល់ថាបានបង្កើតឡើង នោះត្រូវកំណត់ថា តើសិទ្ធិនោះត្រូវបានទទួលស្គាល់ថាបានរលត់នាពេលក្រោយមកដែរឬទេ។

ប្រសិនបើសិទ្ធិនោះ ត្រូវបានទទួលស្គាល់ថាបានបង្កើតឡើង តែមិនត្រូវបានទទួលស្គាល់ថាបានរលត់នាពេលក្រោយមកទេ សិទ្ធិនោះត្រូវបានវិនិច្ឆ័យថាមានអត្ថិភាពនៅពេលបច្ចុប្បន្ន។ ហេតុនេះហើយ ដើម្បីឱ្យ

---

[58] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៧៥ កថាខណ្ឌទី២។

[59] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ២២១ និង ២២២។

តុលាការសម្រេចថាសិទ្ធិដែលជាខ្លឹមសារនៃការទាមទាររបស់ខ្លួន មានអត្ថិភាព ដើមចោទត្រូវធ្វើការអះអាងអំពីអង្គហេតុមួយឆ្លើយតបទៅនឹងល័ក្ខខណ្ឌតាមផ្លូវច្បាប់ ដើម្បីឱ្យសិទ្ធិនោះមានអានុភាពតាមផ្លូវច្បាប់ (អង្គហេតុផ្ទាល់)។

ក្រៅពីចំណុចទាំងអស់នេះ ដើម្បីមានភាពច្បាស់លាស់ក្នុងការគាំទ្រការទាមទារ ដើមចោទអាចត្រូវបានតុលាការបង្គាប់ឱ្យដាក់ភស្តុតាង ប្រសិនបើចុងចម្លើយបដិសេធអង្គហេតុ ជាអាទិ៍។ ម្យ៉ាងវិញទៀត ដើមចោទ ក៏អាចស្នើសុំទៅតុលាការឱ្យចេញដីកាសម្រេចបង្គាប់ឱ្យធ្វើកោសលវិច័យ ឬដីកាសម្រេច ឬកិច្ចផ្សេងៗទៀត ដែលក្រមនីតិវិធីរដ្ឋប្បវេណីអនុញ្ញាត ដូចជាការស្នើសុំកែប្រែ ឬបន្ថែម ឬផ្លាស់ប្តូរកម្មវត្ថុនៃបណ្តឹង ជាអាទិ៍។

ប្រសិនបើតុលាការបង្គាប់ឱ្យដើមចោទបង្ហាញភស្តុតាងជាឯកសារ ដើមចោទត្រូវយក ភស្តុ-តាងនោះមកដាក់នៅតុលាការ ដើម្បីតុលាការអាចពិនិត្យភស្តុតាងជាឯកសារនោះ ត្រឹមកម្រិតចាំបាច់ដើម្បីរៀបចំចំណុចវិវាទ ដូចជាក្នុងករណីចុងចម្លើយតវ៉ាចំពោះអង្គហេតុនៃការបង្កើតកិច្ចសន្យាលក់ទិញ រថយន្ត ដោយយល់ឃើញថា មិនមែនជាការលក់ទិញ គឺជាអំណោយ (ការបដិសេធអង្គហេតុ) និងបានបន្ថែមថា ទោះបីកិច្ចសន្យាលក់ទិញត្រូវបានទទួលស្គាល់ក៏ដោយ ក៏ផុតអាជ្ញាយុកាលនៃការទាមទារ (អង្គហេតុតវ៉ា) ក្នុងស្ថានភាពបែបនេះប្រសិនបើកិច្ចសន្យាលក់ទិញត្រូវបានទទួលស្គាល់ ដោយពិនិត្យទៅលើលិខិតកិច្ចសន្យាដែលដើមចោទដាក់ទៅតុលាការ នោះតុលាការអាចប្រើវិធីនេះ ដើម្បីរៀបចំចំណុចវិវាទ។ ប៉ុន្តែការពិនិត្យភស្តុតាងជា ការសាកសួរសាក្សី ឬការស្នើសុំធ្វើកោសវិច័យ ជាអាទិ៍ មិនអាចធ្វើបានឡើយ នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល។

### ២.១.២.២ ចុងចម្លើយ

ដើម្បីមានភាពងាយស្រួលក្នុងការដឹកនាំនីតិវិធី និងមានភាពច្បាស់លាស់ក្នុងការឆ្លើយតប ឬអនុវត្តសិទ្ធិបង្រួមបញ្ហា កំណត់ចំណុចវិវាទពិតប្រាកដ នៅពេលបញ្ជូនពាក្យបណ្តឹងទៅចុងចម្លើយ តុលាការតែងតែបង្គាប់ឱ្យចុងចម្លើយដាក់ឯកសារត្រៀមលើកដំបូងមកតុលាការ គេហៅឯកសារនេះថា "ឯកសារចម្លើយ" ដើម្បីធ្វើការឆ្លើយតបនឹងបណ្តឹង។(លេខយោង)១០១ អំពីចំណុចសារជាតុដែលត្រូវសរសេរនៅក្នុងឯកសារចម្លើយត្រូវមានដូចជា ទី១ ការឆ្លើយតបចំពោះខ្លឹមសារនៃសាលក្រមដែលដើមចោទទាមតារឱ្យតុលាការចេញ ទី២ ការទទួលស្គាល់ ឬមិនទទួលស្គាល់នូវអង្គហេតុដែលសរសេរនៅក្នុងពាក្យបណ្តឹង និងទី៣ អង្គហេតុតវ៉ា (ប្រសិនបើមាន) ហើយអាចភ្ជាប់ជាភស្តុតាងមកជាមួយក៏បាន (ប្រសិនបើមាន ក្នុងករណីចុងចម្លើយបានលើកឡើងអំពីអង្គហេតុតវ៉ា ហើយចង់បញ្ជាក់ភស្តុតាងចំពោះអង្គហេតុតវ៉ា)។[60]

ប្រសិនបើចុងចម្លើយបានដាក់ឯកសារចម្លើយមកតុលាការតាមការកំណត់ តុលការអាចបញ្ជូនឯកសារចម្លើយនេះទៅដើមចោទ ដើម្បីឱ្យដើមចោទធ្វើការឆ្លើយតប។ ឯកសាររបស់ដើមចោទ ដែលត្រូវឆ្លើយតបនឹងឯក-សារចម្លើយរបស់ចុងចម្លើយ[61] ត្រូវបានហៅថា "ឯកសារត្រៀមលើកទី១ របស់ដើមចោទ"។ ឯកសារត្រៀមលើក

[60] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ១០១។

[61] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ១០១។

ទី១ របស់ដើមចោទមានសារសំខាន់ក្នុងការគាក់តែងឡើង នៅពេលធ្វើឯកសារចម្លើយរបស់ចុងចម្លើយ បាន លើកឡើងអំពីអង្គហេតុតវ៉ា ក្នុងករណីបែបនេះ ដើម្បីមានភាពច្បាស់លាស់ គប្បីដើមចោទធ្វើឯកសារត្រៀមលើក ទី១ របស់ដើមចោទ (តុលាការអាចបង្គាប់ឱ្យដាក់ ឬដើមចោទអាចដាក់ដោយឆន្ទៈផ្ទាល់ខ្លួនក៏បាន បើដើមចោទ បានទទួលឯកសារចម្លើយ) នូវចំណុចសារធាតុមួយចំនួនដូចជា ទី១ ការទទួលស្គាល់ ឬមិនទទួលស្គាល់អង្គ ហេតុតវ៉ា ទី២ ការទទួលស្គាល់ ឬមិនទទួលស្គាល់អង្គហេតុដែលពាក់ព័ន្ធ និងទី៣ អង្គហេតុតវ៉ាតប (ប្រសិនបើ មាន) ហើយអាចភ្ជាប់ភស្តុតាងមកជាមួយ ក៏បាន (ប្រសិនបើមាន ក្នុងករណីដើមចោទបានលើកឡើងអំពីអង្គ ហេតុតវ៉ាតប ហើយចំបញ្ជាក់ភស្តុតាងចំពោះអង្គហេតុតវ៉ាតប)។

ប្រសិនបើ ដើមចោទមិនទទួលស្គាល់អង្គហេតុតវ៉ាដែលជាមធ្យោបាយការពារខ្លួននេះ ចុងចម្លើយត្រូវស្នើ សុំឱ្យពិនិត្យភស្តុតាង ដើម្បីបញ្ជាក់អំពីអង្គហេតុនេះ។

### ២.១.២.៣ ពេលវេលាដែលត្រូវដាក់មធ្យោបាយតទល់ ឬការពារខ្លួន

ភាគី ត្រូវដាក់មធ្យោបាយតទល់ ឬ ការពារខ្លួន នៅពេលសមរម្យ ទៅតាមដំណាក់កាលនៃរឿងក្ដី។[62] នេះគឺជានិមិត្តរូបរួមមួយនៃគោលការណ៍ជាមូលដ្ឋាន នៃក្រមនីតិវិធីរដ្ឋប្បវេណី ដែលថា ភាគីត្រូវអនុវត្តបណ្ដឹង រដ្ឋប្បវេណី ដោយសុចរិត និងស្មោះត្រង់។ ក្នុងករណីដែលមូលហេតុសមរម្យពិសេស ភាគីអាចដាក់មធ្យោបាយ តទល់ ឬ ការពារខ្លួន នៅពេលណាក៏បាន មុនពេលដែលការវិនិច្ឆ័យលើបណ្ដឹងត្រូវបានបញ្ចប់ (គឺ មុនពេលដែល ការទាញហេតុផលដោយផ្ទាល់មាត់ត្រូវបានបញ្ចប់)។ ប៉ុន្តែ ប្រសិនបើពុំមានមូលហេតុពិសេសទេ ភាគីត្រូវដាក់ មធ្យោបាយតទល់ ឬ ការពារខ្លួននៅពេលសមរម្យទៅតាមដំណាក់កាលនៃការជម្រះក្ដី។ ពេលវេលាសមរម្យ សំដៅទៅលើឱកាស ឬដំណាក់កាលនៅក្នុងនីតិវិធីដែលត្រូវបានសង្ឃឹមថា គួរដាក់មធ្យោបាយតទល់ ឬ ការពារ ខ្លួន ដើម្បីដោះស្រាយវិវាទ ឱ្យបានលឿន និងត្រឹមត្រូវ។

ដោយសារថា នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គឺជានីតិវិធីធ្វើឡើងដើម្បីបំភ្លឺជាមុន នូវចំណុច វិវាទ ដោយត្រូវរៀបចំការអះអាងរបស់ភាគី និងរៀបចំភស្តុតាងពាក់ព័ន្ធនឹងចំណុចវិវាទនោះ ដែលត្រូវពិនិត្យនៅ ក្នុងការទាញហេតុផលដោយផ្ទាល់មាត់ ដើម្បីអាចរៀបចំការជម្រះក្ដីឱ្យមានប្រសិទ្ធិភាព និងដោយសមូហវិធី នៅក្នុងទាញហេតុផលដោយផ្ទាល់មាត់ ហេតុនេះហើយ ភាគីត្រូវដាក់មធ្យោបាយតទល់ ឬការពារខ្លួនទាំងអស់ នៅក្នុងដំណាក់កាលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនេះ លើកលែងតែក្នុងកាលៈទេសៈដែលមិន ទាន់អាចដាក់បាននៅពេលនេះ។ ដើម្បីឆ្លើយតបទៅនឹងការទាមទារនេះ ភាគីត្រូវធ្វើការស្រាវជ្រាវជាមុន ឱ្យបាន ហ្មត់ចត់ អំពីទំនាក់ទំនងអង្គហេតុចំពោះសាក្សី ឬភស្តុតាងដទៃទៀត។ ហេតុនេះហើយ ក្រោយពីបានបញ្ចប់ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលហើយ ជាគោលការណ៍ ភាគីមិនអាចដាក់មធ្យោបាយតទល់ ឬ ការពារ ខ្លួនថ្មីទៀត នៅពេលធ្វើការទាញហេតុផលដោយផ្ទាល់មាត់បានឡើយ។[63]

---

[62] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៥៣។

[63] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ១០៨។

នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ភាគីត្រូវលើកឡើងនូវការអះអាងរបស់ខ្លួន ឱ្យបានទាន់ពេលវេលា ត្រូវឆ្លើយតបទៅនឹងការអះអាងរបស់ភាគីម្ខាងទៀត ហើយត្រូវធ្វើការស្នើសុំឱ្យពិនិត្យភស្តុតាងចំពោះអង្គហេតុដែលមានវិវាទ។ ចំពោះមធ្យោបាយតទល់ ឬការពារខ្លួន ដែលបានដាក់ទៅតុលាការ យឺតយ៉ាវមិនត្រូវនឹងពេលសមរម្យ ដោយចេតនា ឬ ដោយកំហុសដ៏ធ្ងន់ធ្ងររបស់ភាគី តុលាការអាចចេញដីកាសម្រេចលើកចោលមធ្យោបាយតទល់ ឬ ការពារខ្លួនោះបាន តាមពាក្យសុំរបស់ភាគីម្ខាងទៀត ឬ ដោយឆន្ទានុសិទ្ធិរបស់ខ្លួន ប្រសិនបើតុលាការយល់ឃើញថា ការដាក់មធ្យោបាយនោះ ធ្វើឱ្យមានការយឺតយ៉ាវក្នុងការបញ្ចប់នីតិវិធីនៃបណ្ដឹង។[64] នេះក៏ព្រោះថា ប្រសិនបើអនុញ្ញាតឱ្យ ភាគីណាម្ខាងដាក់មធ្យោបាយតទល់ ឬ ការពារខ្លួន ក្រោយពេលវេលាសមរម្យ ដោយមានបំណង ឬចេតនាធ្វើការអូសបន្លាយនីតិវិធីនៃបណ្ដឹង នោះវាមិនត្រឹមតែធ្វើឱ្យរំខាន់ដល់ភាគីម្ខាងទៀតប៉ុណ្ណោះទេ វាថែមទាំងជាបន្ទុកមួយដ៏ធ្ងន់សម្រាប់តុលាការផងដែរ ដែលការណ៍នេះនឹងធ្វើឱ្យប៉ះពាល់ដល់ប្រសិទ្ធិភាពនៃប្រព័ន្ធតុលាការទាំងមូលតែម្តង។ ក្នុងករណីដែលគោលគំនិត និងអត្ថន័យនៃមធ្យោបាយតទល់ ឬ ការពារខ្លួន ដែលភាគីបានដាក់មានភាពមិនច្បាស់លាស់ ហើយតុលាការបានទាមទារឱ្យបំភ្លឺ តែភាគីមិនផ្ដល់ការបំភ្លឺចាំបាច់ ឬ មិនបង្ហាញខ្លួនតាមកាលបរិច្ឆេទដែលបានកំណត់ឱ្យបំភ្លឺទេ តុលាការអាចលើកចោលនូវមធ្យោបាយតទល់ ឬ ការពារខ្លួននោះបាន។[65]

### ២.១.២.៤ ការដកពាក្យបណ្ដឹងរបស់ភាគី

ការដកពាក្យបណ្ដឹង គឺជាសកម្មភាពដកមួយភាគ ឬ ទាំងស្រុងនូវពាក្យសុំទាទារឱ្យចេញសាលក្រមតាមរយៈបណ្ដឹងដោយដើមចោទ។ បណ្ដឹងគឺជាសកម្មភាពដែលដើមចោទទាមទារឱ្យតុលាការចេញសាលក្រមដែលមានខ្លឹមសារកំណត់មួយ ហេតុនេះហើយ ការដកពាក្យបណ្ដឹងនោះ កំណត់ជាគោលការណ៍អាចធ្វើទៅបានតែដោយឆន្ទៈរបស់ដើមចោទប៉ុណ្ណោះ។[66]

ដើមចោទអាចដកពាក្យបណ្ដឹងពេលណាក៏បាន រហូតដល់ពេលដែលសាលក្រមចុងក្រោយចូលជាស្ថាពរ។ ក៏ប៉ុន្តែក្រោយពីចុងចម្លើយបានដាក់ឯកសារត្រៀមអំពីអង្គសេចក្ដី មានន័យថា អំពីការទាមទាររបស់ដើមចោទ ឬបានធ្វើសេចក្ដីថ្លែងការណ៍អំពីអង្គសេចក្ដីក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដើម្បីដកពាក្យបណ្ដឹង ចាំបាច់ត្រូវមានការយល់ព្រមពីចុងចម្លើយ។[67] ប្រសិនបើពុំមានការយល់ព្រមពីចុងចម្លើយនោះទេ ការដកពាក្យបណ្ដឹងពុំមានអានុភាពនោះទេ។ នេះគឺដោយសារតែចុងចម្លើយឆ្លើយតបទៅនឹងការទាមទាររបស់ដើមចោទ មានន័យថាចុងចម្លើយក៏មានផលប្រយោជន៍ក្នុងការទទួលសាលក្រមឈ្នះក្តីចំពោះបណ្ដឹងនោះដែរ ដូច្នេះហើយ ការទទួលស្គាល់នូវការបំបាត់នូវផលប្រយោជន៍របស់ចុងចម្លើយ តាមឆន្ទៈរបស់ដើមចោទតែប៉ុណ្ណោះ វានឹងមានភាពផ្ទុយនឹងសមភាព និងយុត្តិធម៌សម្រាប់ចុងចម្លើយ។ ការដកពាក្យបណ្ដឹង គឺជាសកម្មភាពបណ្ដឹង

[64] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៩៤ កថាខណ្ឌទី១។

[65] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៩៤ កថាខណ្ឌទី២។

[66] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ២១៧ កថាខណ្ឌទី១។

[67] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ២១៧ កថាខណ្ឌទី២។

របស់ដើមចោទ ដែលត្រូវបានធ្វើឡើងនៅក្នុងនីតិវិធីនៃបណ្តឹង។ ហេតុនេះហើយត្រូវបែងចែកឱ្យដាច់ពីការព្រមព្រៀងដកពាក្យបណ្តឹងដែលភាគីទាំងសងខាងធ្វើឡើងក្រៅពីនីតិវិធីបណ្តឹង។ ការដកពាក្យបណ្តឹងតាមផ្លូវបណ្តឹងនាំឱ្យ ការចាត់ការបណ្តឹងនឹងត្រូវរលាយ ផ្ទុយទៅវិញ ការព្រមព្រៀមដកពាក្យបណ្តឹងក្រៅនីតិវិធីបណ្តឹង វាគ្រាន់តែជាកិច្ចសន្យាមួយតាមផ្លូវនីតិវិធីឯកជនប៉ុណ្ណោះ ហេតុនេះហើយ ពុំអាចបង្កើតនូវអានុភាពតាមផ្លូវច្បាប់ ដូចជាការរំលាយការចាត់ការបណ្តឹងជាអាទិ៍។ បន្ថែមពីនេះទៀតការដកពាក្យបណ្តឹង ជាគោលការណ៍ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ។[68] ក៏ប៉ុន្តែនៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល អាចដកពាក្យបណ្តឹងផ្ទាល់មាត់ក៏បានដែរ។[69] ពេលដែលមានការដកពាក្យបណ្តឹងដោយផ្ទាល់មាត់ ក្រឡាបញ្ជីត្រូវចុះអំពីការដកពាក្យបណ្តឹងនៅក្នុងកំណត់ហេតុនៃ នីតិវិធីត្រៀមសម្រាប់ការទាញហេតុ ដើម្បីកុំឱ្យមានការវិវាទនាពេលក្រោយ។ កាលបរិច្ឆេទនៃការផ្សះផ្សា គឺជាផ្នែកមួយនៃ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល។ ហេតុនេះហើយ ក្នុងករណីដែលមានការដកពាក្យបណ្តឹងដោយផ្ទាល់មាត់ នៅកាលបរិច្ឆេទនៃការផ្សះផ្សា ចាំបាច់ត្រូវចុះនូវចំណុចនៅក្នុងកំណត់ហេតុ(កំណត់ហេតុសះជា)។

ក្នុងករណីដែលចាំបាច់មានការយល់ព្រមពីចុងចម្លើយដើម្បីដកពាក្យបណ្តឹង ហើយទោះជាចុងចម្លើយមិនយល់ព្រមជាក់ស្តែងក៏ដោយក៏ត្រូវចាត់ទុកដូចជាមានការយល់ព្រមដែរ ដូចក្នុងករណីខាងក្រោម៖

- ករណីដែលដើមចោទដាក់លិខិតដកពាក្យបណ្តឹងជាលាយលក្ខណ៍អក្សរទៅតុលាការ ក្រឡាបញ្ជីត្រូវធ្វើការបញ្ជូននូវលិខិតនេះទៅឱ្យចុងចម្លើយ។[70] ប្រសិនបើចុងចម្លើយមិនបានតវ៉ាក្នុងអំឡុងពេលពីរសប្តាហ៍ គិតចាប់ពីថ្ងៃដែលបានទទួលនូវការបញ្ជូនលិខិតនោះទេ ត្រូវចាត់ទុកថាបានយល់ព្រមចំពោះការដកពាក្យបណ្តឹងនេះហើយ។[71]

- ក្នុងករណីដែលដើមចោទបានដកពាក្យបណ្តឹងដោយផ្ទាល់មាត់នៅកាលបរិច្ឆេទនៃ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ កាលបរិច្ឆេទនៃការផ្សះផ្សា តែចុងចម្លើយអវត្តមាននៅកាលបរិច្ឆេទនោះ ក្រឡាបញ្ជីត្រូវធ្វើការបញ្ជូនឯកសារចម្លងនៃកំណត់ហេតុដែលបានចុះសេចក្តីថ្លែងការណ៍ អំពីការដកពាក្យបណ្តឹងនោះទៅឱ្យចុងចម្លើយ។ ក្នុងករណីដែលចុងចម្លើយមិនបានតវ៉ាក្នុងអំឡុងពេល ពីរសប្តាហ៍ ពីថ្ងៃដែលបានទទួលការបញ្ជូននោះ ក៏ត្រូវចាត់ទុកថាចុងចម្លើយបានយល់ព្រមនឹងការដកពាក្យបណ្តឹងនោះដែរ។[72]

[68] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ២១៧ កថាខណ្ឌទី៣ វាក្យខណ្ឌទី១។
[69] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ២១៧ កថាខណ្ឌទី៣ វាក្យខណ្ឌទី២។
[70] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ២១៧ កថាខណ្ឌទី៤ វាក្យខណ្ឌទី១។
[71] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ២១៧ កថាខណ្ឌទី៥ វាក្យខណ្ឌទី១។
[72] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ២១៧ កថាខណ្ឌទី៣ វាក្យខណ្ឌទី២។

- ក្នុងករណីដែលដើមចោទបានដកពាក្យបណ្ដឹងដោយផ្ទាល់មាត់នៅកាលបរិច្ឆេទត្រៀមសម្រាប់ការទាញហេតុផល ហើយចុងចម្លើយមានវត្តមាននៅកាលបរិច្ឆេទនោះ ប្រសិនបើចុងចម្លើយមិនបានតវ៉ាក្នុងអំឡុងពេល ពីរសប្ដាហ៍ គិតពីកាលបរិច្ឆេទនោះ ត្រូវចាត់ទុកថាចុងចម្លើយបានយល់ព្រមនឹងការដកពាក្យបណ្ដឹងនោះ។

ប្រសិនបើដើមចោទបានដកពាក្យបណ្ដឹងមុនពេលចប់កាលបរិច្ឆេទនៃការទាញហេតុផលលើកដំបូង ភាគីអាចទាមទារឱ្យតុលាការសងមកវិញនូវចំនួនពាក់កណ្ដាលនៃពន្ធដាក់ពាក្យបណ្ដឹងដែលខ្លួនបានបង់។[73]

## ២.២ កំណត់ហេតុស្ដីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នៅរាល់កាលបរិច្ឆេទនីមួយៗនៃ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការត្រូវបង្គាប់ឱ្យក្រឡាបញ្ជីធ្វើកំណត់ហេតុ ហៅថាកំណត់ហេតុស្ដីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល។[74] នៅក្នុងការធ្វើកំណត់ហេតុ ស្ដីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលមានចំណុចសំខាន់ៗមួយចំនួនដូចជា៖ ១.ចំណុចជារូបមន្តនៃកំណត់ហេតុស្ដីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ២.ចំណុចសារធាតុនៃកំណត់ហេតុស្ដីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និង ៣.ការប្ដឹងតវ៉ាចំពោះសេចក្ដីកត់ត្រានៃកំណត់ហេតុ។

### ២.២.១ ចំណុចជារូបមន្តនៃកំណត់ហេតុស្ដីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នៅក្នុងកំណត់ហេតុស្ដីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ត្រូវកត់ត្រានូវចំណុចសំខាន់ៗដូចខាងក្រោម៖

ក. សញ្ញាណនៃរឿងក្ដី

ខ. ឈ្មោះចៅក្រម និង ក្រឡាបញ្ជី

គ. ឈ្មោះភាគី អ្នកតំណាង អ្នកជំនួយការ និងអ្នកបកប្រែដែលបានបង្ហាញខ្លួន

ឃ. ពេលវេលា និង ទីកន្លែង

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ និង ក្រឡាបញ្ជី ត្រូវចុះហត្ថលេខាលើកំណត់ហេតុនោះ។[75]

[73] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៦១ កថាខណ្ឌទី៨ ចំណុចខ។

[74] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ១០៩។

[75] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ១១០។

### ២.២.២ ចំណុចសារធាតុនៃកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នៅក្នុងកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ក្រឡាបញ្ជីត្រូវកត់ត្រាសេចក្តីសង្ខេបអំពីសកម្មភាពដែលបានធ្វើឡើងនៅកាលបរិច្ឆេទនីមួយៗ ហើយជាពិសេស ត្រូវកត់ត្រាឱ្យបានច្បាស់លាស់នូវចំណុចដូចខាងក្រោម[76] ៖

ក. ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ និងចម្លើយឆ្លើយតបរបស់ចុងចម្លើយចំពោះការទាមទារនោះ។

ខ. ខ្លឹមសារនៃអង្គហេតុដែលបានអះអាង និងការស្នើសុំឱ្យពិនិត្យភស្តុតាង។

គ. ការទទួលស្គាល់ ឬ មិនទទួលស្គាល់របស់ភាគី ចំពោះអង្គហេតុដែលបានអះអាងដោយភាគីម្ខាងទៀត និង ការទទួលស្គាល់របស់ភាគី ឬ មិនទទួលស្គាល់ចំពោះភាពត្រឹមត្រូវនៃឯកសារ។

ឃ. ការដកពាក្យបណ្តឹង ការផ្សះផ្សា ការលះបង់ការទាមទារ និង ការទទួលស្គាល់ការទាមទារ។

ង. ចំណុចដែលតុលាការបានបង្គាប់ឱ្យកត់ត្រា និង ចំណុចដែលតុលាការអនុញ្ញាតឱ្យកត់ត្រា តាមការទាមទាររបស់ភាគី។

ច. ការសម្រេចសេចក្តីដែលបានធ្វើឡើងនៅកាលបរិច្ឆេទនោះ ដោយមិនធ្វើជាលាយល័ក្ខណ៍អក្សរ។

### ២.២.៣ ការប្តឹងតវ៉ាចំពោះសេចក្តីកត់ត្រានៃកំណត់ហេតុ

ក្នុងករណីដែលភាគី ឬអ្នកដទៃទៀតដែលពាក់ព័ន្ធ ប្តឹងតវ៉ាចំពោះសេចក្តីកត់ត្រានៅក្នុងកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនោះ ត្រូវកត់សេចក្តីប្តឹងតវ៉ានេះ នៅក្នុងកំណត់ហេតុនោះ។ ភាពត្រឹមត្រូវក្នុងការអនុវត្តតាមបញ្ញត្តិទាក់ទងនឹងរបៀបធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល អាចបញ្ជាក់បាន ដោយកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលតែប៉ុណ្ណោះ លើកលែងតែក្នុងករណីដែលកំណត់ហេតុនោះ បានបាត់ ឬ បានវិនាស។[77]

## ២.៣ សមត្ថកិច្ចដឹកនាំនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

ក្នុងករណីការជម្រះក្តីដោយចៅក្រមតែម្នាក់ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលត្រូវស្ថិតក្រោមការដឹកនាំរបស់ចៅក្រមនោះផ្ទាល់។ ប៉ុន្តែប្រសិនបើ ការជម្រះក្តីដោយក្រុមប្រឹក្សាជំនុំជម្រះវិញនោះ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ត្រូវស្ថិតក្រោមការដឹកនាំរបស់ប្រធានក្រុមប្រឹក្សាជំនុំជម្រះ ដោយអនុវត្ត

[76] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ១១១។

[77] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ១១៣។

សិទ្ធិដឹកនាំនីតិវិធីក្នុងនាមជាក្រុមប្រឹក្សា។ ម៉្យាងទៀត ដើម្បីរក្សារសណ្ដាប់ធ្នាប់នៅក្នុងដំណើរការដឹកនាំនីតិវិធី ចៅក្រម ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ អាចអនុញ្ញាតឱ្យជនណាម្នាក់មានសិទ្ធិនិយាយ និងហាមមិនឱ្យជនណាម្នាក់និយាយបាន។[78] នៅដំណាក់កាលជំនុំជម្រះក្ដីលើកទី១ (សាលាដំបូង) រឿងក្ដីត្រូវទទួលបន្ទុកជំនុំជម្រះដោយចៅក្រមមួយរូប។[79] ប៉ុន្តែក្នុងករណីដែលការជំនុំជម្រះមានការដោះស្រាយដោយក្រុមប្រឹក្សាការជំនុំជម្រះនៃចៅក្រមមានចំនួនបីរូប ប្រសិនបើរឿងក្ដីនោះ ជារឿងក្ដីដែលមានកម្មវត្ថុនៃបណ្ដឹងមិនតិចជាង ៥លានរៀល។[80]

នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី មិនបានកំណត់ទីតាំងច្បាស់លាស់សម្រាប់ការធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនោះទេ។ ម៉្យាងទៀតនីតិវិធីនេះ មិនចាំបាច់ធ្វើក្នុងសាលសវនាការទេ ហើយតុលាការមានឆន្ទានុ-សិទ្ធិក្នុងការអនុញ្ញាត ឬមិនអនុញ្ញាតឱ្យនរណាម្នាក់ចូលស្ដាប់នៅពេលធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុនោះបាន។ សព្វថ្ងៃនេះនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលប្រព្រឹត្តទៅនៅក្នុងបន្ទប់ផ្ទាល់របស់ចៅក្រម ឬ ក្រុមប្រឹក្សាជំនុំជម្រះតែម្ដង។[81]

[78] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៨៩ កថាខណ្ឌទី២។
[79] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ២៣ កថាខណ្ឌទី១។
[80] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ២៣ កថាខណ្ឌទី២។
[81] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ២៧ កថាខណ្ឌទី២។

# ជំពូកទី៣

## ការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

# ជំពូកទី៣
# ការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

## ៣.១ សកម្មភាពដែលត្រូវបំពេញនៅពេលបញ្ចប់ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នៅពេលនីតិវិធីត្រៀមសម្រាប់ទាញហេតុផលត្រូវបានបញ្ចប់ តុលាការត្រូវបញ្ជាក់អំពីអង្គហេតុដែលត្រូវបំភ្លឺជាមួយភាគី(៣.១.១) បន្ទាប់មកត្រូវធ្វើការកំណត់កាលបរិច្ឆេទ នៃការទាញហេតុផលផ្ទាល់មាត់(៣.១.២)។

### ៣.១.១ ការបញ្ជាក់អំពីអង្គហេតុដែលត្រូវបំភ្លឺ

ពេលដែលបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដោយបានបញ្ចប់នូវការរៀបចំចំណុចវិវាទ និងភស្តុតាងរួចហើយ តុលាការត្រូវបញ្ជាក់ជាមួយភាគីទាំងសងខាង អំពីអង្គហេតុដែលត្រូវធ្វើការបញ្ជាក់ តាមរយៈការពិនិត្យភស្តុតាង នៅពេលធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ដែលនឹងធ្វើបន្ទាប់ពីនោះ។[82] បានន័យថា តុលាការ និង ភាគីសងខាង ត្រូវធ្វើការបញ្ជាក់ថាតើអង្គហេតុណាខ្លះដែលជាចំណុចវិវាទហើយ ដែលត្រូវក្លាយជាកម្មវត្ថុនៃការពិនិត្យភស្តុតាង ហើយតុលាការ និងភាគីសងខាង ត្រូវមានការទទួលស្គាល់រួមគ្នាចំពោះបញ្ហានេះ ដើម្បីអាចធ្វើការពិនិត្យភស្តុតាងដោយសមូហវិធី នៅពេលទាញហេតុផលដោយ ផ្ទាល់មាត់បាន។[83]

### ៣.១.២ ការកំណត់កាលបរិច្ឆេទលើកទីមួយនៃការទាញហេតុផលដោយផ្ទាល់មាត់

នៅពេលដែលបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការត្រូវកំណត់កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ហើយត្រូវកោះហៅភាគីទាំងសងខាង ឱ្យមកចូលរួម នៅកាលបរិច្ឆេទដែលបានកំណត់នោះ។[84] ជាគោលការណ៍ នីតិវិធីទាញហេតុផលដោយផ្ទាល់លមាត់ នឹងប្រព្រឹត្តឡើង បន្ទាប់ពីនីតិវិធីដ៏សំខាន់ គឺនីតិវិធីត្រៀមសម្រាប់ការទាញផលត្រូវបានបញ្ចប់សព្វគ្រប់ដោយតុលាការ។

## ៣.២ អានុភាពនៃការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

បន្ទាប់ពីបានបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលហើយ ភាគីមិនអាចដាក់មធ្យោបាយតទល់ ឬការពារខ្លួនថ្មីទៀត នៅដំណាក់កាលនៃការទាញហេតុផលដោយផ្ទាល់មាត់ ដែលត្រូវធ្វើឡើងនៅពេលបន្ទាប់មកបានទេ។ ប្រសិនបើអនុញ្ញាតឱ្យភាគីអាចដាក់មធ្យោបាយតទល់ ឬការពារខ្លួននៅក្រោយការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបាន នោះការដែលត្រូវកំណត់ចំណុចវិវាទឱ្យច្បាស់តាមរយៈការរៀបចំនូវការអះអាងរបស់ភាគី និងការបង្រួមភស្តុតាងដែលត្រូវពិនិត្យ នឹងពុំមានន័យខ្លឹមសារអ្វីឡើយ ហើយតុលាការនិងធ្វើការលើកចោលនូវមធ្យោបាយតទល់ ឬមធ្យោបាយការពារខ្លួននោះ ក៏ប៉ុន្តែមានករណីខ្លះត្រូវបានលើកលែងផងដែរ ។

[82] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ១០៧។
[83] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ១២៧។
[84] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ១១៣។

### ៣.២.១ ការលើកចោលមធ្យោបាយតទល់ ឬការពារខ្លួនថ្មី

មធ្យោបាយតទល់ ឬការពារខ្លួន ត្រូវបានដាក់ឱ្យតុលាការនៅពេលណាមួយដែលសមរម្យ ទៅតាមដំណើរការនៃបណ្តឹង។[85] នោះមានន័យថាតុលាការអាចលើកចោលមធ្យោបាយតទល់ ឬ ការពារខ្លួនរបស់ភាគីដែលបានដាក់យឺតយ៉ាវ មិនត្រូវនិងពេលសមរម្យ ។

ក. ចំពោះមធ្យោបាយតទល់ ឬ ការពារខ្លួនដែលបានដាក់ទៅតុលាការយឺតយ៉ាវមិនត្រូវនឹងពេលសមរម្យ ដោយចេតនា ឬ ដោយកំហុសដ៏ធ្ងន់ធ្ងររបស់ភាគី តុលាការអាចចេញដីកាសម្រេចលើកចោលមធ្យោបាយតទល់ ឬ ការពារខ្លួនបានតាមពាក្យសុំ ឬ ដោយឆន្ទានុសិទ្ធិរបស់ខ្លួន ប្រសិនបើតុលាការយល់ឃើញថា ការដាក់មធ្យោបាយនោះ ធ្វើឱ្យមានការយឺតយ៉ាវក្នុងការបញ្ចប់នីតិវិធីនៃបណ្តឹង ។

ខ. បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះត្រូវយកមកអនុវត្តដែរ ចំពោះមធ្យោបាយតទល់ ឬ ការពារខ្លួនដែលមានអត្ថន័យមិនច្បាស់លាស់ ក្នុងករណីដែលភាគីមិនបានធ្វើការ បំភ្លឺចាំបាច់ ឬ មិនបង្ហាញខ្លួនតាមកាលបរិច្ឆេទដែលបានកោះហៅឱ្យមកបំភ្លឺទេ ។[86]

### ៣.២.២ ករណីលើកលែងចំពោះការដាក់មធ្យោបាយតទល់ ឬការពារខ្លួនថ្មី

តុលាការអាចទទួលការករណីលើកទទួលករណីលើកលែងបានចំពោះករណីដែលមធ្យោបាយនោះ ទាក់ទងនិងចំណុចដូចជា ៖

ក. ទាក់ទងនិងចំណុចដែលតុលាការត្រូវធ្វើការស្រាវជ្រាវដោយឆន្ទានុសិទ្ធិរបស់ខ្លួន ។

**ឧទាហរណ៍៖** ការបញ្ជាក់អំពី អត្ថិភាព ឬនត្ថិភាពនៃសមត្ថកិច្ចតុលាការ និងអត្ថិភាព ឬនត្ថិភាពនៃមូលហេតុដក ហូតសមត្ថកិច្ចជំនុំជម្រះក្តី ជាអាទិ៍។[87]

ខ.មធ្យោបាយ ដែលមិនធ្វើឱ្យមានការយឺតយ៉ាវដល់នីតិវិធីបណ្តឹង។

**ឧទាហរណ៍៖** ភាគីស្នើសុំឱ្យតុលាការពិនិត្យភស្តុតាង ដែលអាចពិនិត្យភ្លាមៗបានដូចជា ឯកសារដែលភាគីមាននៅពេលនីតិវិធី ឬសាក្សីដែលភាគីនាំមកជាមួយក្នុងកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់តែម្តង ។

គ. ករណីដែលភាគីបានធ្វើសេចក្តីបញ្ជាក់ដំបូងថា ខ្លួនមិនអាចដាក់មធ្យោបាយនោះនៅមុនពេល បញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបាន ដោយគ្មានកំហុស ។

[85] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៩៣។

[86] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៩៤។

[87] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ១៦។

**ឧទាហរណ៍៖** ភាគីស្នើសុំឱ្យ តុលាការពិនិត្យភស្តុតាងដែលទើបនឹងរកឃើញ និងបានអះអាងអង្គហេតុដែលកើតឡើង នៅក្រោយពេលបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល។[88]

តុលាការនឹងធ្វើការសម្រេចទទួលយកនូវមធ្យោបាយតទល់ ឬការពារខ្លួនតាមរយៈដីកាសម្រេច។ ក្នុងករណី ភាគីបានដាក់មធ្យោបាយតទល់ ឬការពារខ្លួន នៅមុនកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ តុលាការនឹងធ្វើដីកាសម្រេចជាលាយលក្ខណ៍អក្សរ ហើយជូនដំណឹងអំពីដីកាសម្រេចនេះទៅកាន់ភាគី។ នៅក្នុងការ ជូនដំណឹងអំពីដីកាសម្រេច តុលាការនឹងបង្គាប់ឱ្យក្រឡាបញ្ជី ចាត់ចែងធ្វើដីកាបញ្ជូននេះ ដើម្បីបានរបាយការណ៍ ស្តីពីការបញ្ជូន ដាក់ចូលក្នុងសំណុំរឿង។ ប៉ុន្តែប្រសិនបើភាគីបានដាក់មធ្យោបាយតទល់ ឬការពារខ្លួន នៅកាល បរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់តុលាការនឹងចេញដីកាសម្រេចដោយផ្ទាល់មាត់ ហើយជូនដំណឹង ទៅកាន់ភាគី នូវកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់នោះតែម្តង។

**ឧទាហរណ៍៖** អត្ថិភាព ឬ នត្ថិភាព នៃសមត្ថកិច្ចរបស់តុលាការ ឬ អត្ថិភាព រ នត្ថិភាពនៃមូលហេតុ នៃការដកហូតសមត្ថកិច្ចជំនុំជម្រះជាអាទិ៍។

[88] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ១០៨។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានសិក្សាស្រាវជ្រាវអំពីប្រធានបទ **នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល** រួចមកយើងយល់ឃើញថា នៅក្នុងដំណាក់កាលនេះគឺមានសារៈសំខាន់ណាស់នៅក្នុងនីតិវិធីជំនុំជម្រះលើកទី១ ដើម្បីបង្រួមអង្គហេតុ កំណត់ចំណុចវិវាទ រៀបចំសេចក្តីអះអាងរបស់គូរភាគី និងរៀបចំភស្តុតាង សម្រាប់ឱ្យតុលាការងាយស្រួលក្នុងការដោះស្រាយ និងរហ័សក្នុងការបញ្ចប់វិវាទ។ នៅក្នុងនីតិវិធីនេះដែរ ភាគីក៏អាចដាក់មធ្យោបាយតទល់ ឬមធ្យោបាយការពារខ្លួន ទៅតុលាការបានដែរនៅក្នុងពេលវេលាមួយដែលសមរម្យ ។

នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការត្រូវរៀបចំសេចក្តីអះអាងរបស់ភាគី បំភ្លឺនូវចំណុចវិវាទនៃរឿងក្តី ដែលភាគីមិនយល់ស្របគ្នានិងរៀបចំភស្តុតាងដែលទាក់ទងនឹងចំណុចវិវាទនៃរឿងក្តីនោះ ដើម្បីធ្វើការវិនិច្ឆ័យរឿងក្តីនៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់បានល្អិតល្អន់។ ម្យ៉ាងវិញទៀត ចំពោះការដាក់មធ្យោបាយតទល់ ឬការពារខ្លួនដោយភាគីត្រូវដាក់ឱ្យតុលាការអោយទាន់ពេលវេលាទៅតាមដំណើរនៃនីតិវិធីដោយគោរពគោលការណ៍ស្មោះត្រង់និងសុចរិត។ ដោយហេតុថាបញ្ហានៃការមិនគោរពភាពស្មោះត្រង់ នេះតែងតែកើតមានជាញឹកញាប់ ដែលភាគីណាមួយមិនគោរពគោលការណ៍ស្មោះត្រង់ ឬសុចរិតតែងតែឆ្លៀតឱកាសធ្វើសកម្មភាពផ្សេងនៅពេល ដែលតុលាការព្រមទទួលយកនូវសកម្មភាពទាំងនោះ ហើយបានបង្កឲ្យមានភាពខូចខាតប្រយោជន៍ធ្ងន់ធ្ងរទៅលើភាគីម្ខាងទៀត។ សកម្មភាពទាំងនោះបាន បង្កឲ្យភាគីម្ខាងទៀតមិនអាចមានឱកាសសម្រាប់ការពារខ្លួន ឬការតទល់ ហើយទោះបីជាយ៉ាងនេះក្តី ក៏សិទ្ធិនៃការដាក់មធ្យោបាយការពារ ឬតទល់ត្រូវបានទទួលស្គាល់ចំពោះភាគីដែលសុចរិត បើទោះបីជានីតិវិធីត្រៀមសម្រាប់ការទាញហេតុផលត្រូវបានបញ្ចប់ហើយក៏ដោយ។ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនេះមានសារៈសំខាន់ណាស់នៅក្នុងនីតិវិធីរដ្ឋប្បវេណី ពីព្រោះដើម្បីឈានដល់ការទាញ ហេតុផលដោយផ្ទាល់មាត់ឲ្យប្រព្រឹត្តទៅមានភាពរលូន និងល្អប្រសើរនោះត្រូវធ្វើយ៉ាងណាឱ្យនីតិវិធី ត្រៀមសម្រាប់ការទាញហេតុផលមានភាពច្បាស់លាស់ និងគោរពតាមបញ្ញត្តិច្បាប់ដែលមានចែងនៅ ក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ។

នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ក៏ជាមូលដ្ឋានដែលនាំឱ្យតុលាការចេញសាលក្រម ឱ្យឆ្លើយតបជាមួយនឹងការអះអាងរបស់ភាគីផងដែរ។ ប្រសិនបើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដំណើរការដោយមិនមានភាពច្បាស់លាស់ទេ តុលាការក៏មិនអាចបន្តនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ ដោយធ្វើការពិនិត្យភស្តុតាងជាសមូហវិធី ហើយត្រូវបង្វិលនីតិវិធីត្រឡប់ទៅនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលឡើងវិញ ដើម្បីផ្តល់យុត្តិធម៌ជូនភាគី ហើយក៏ជាមូលហេតុដែលនាំឱ្យនីតិវិធីយឺតយ៉ាវផងដែរ។ ដូច្នេះហើយដើម្បីចៀសវាងការអូសបន្លាយពេលវេលា និងការផ្តល់យុត្តិធម៌ជូនភាគីមានការយឺតយ៉ាវ គឺទាមទារឱ្យតុលាការត្រូវយកចិត្តទុកដាក់ខ្ពស់ក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដើម្បីស្វែងរកចំណុចស្នូលនៃវិវាទ។ ប្រសិនបើតុលាការបានធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបានល្អ ពោលគឺតុលាការកំណត់បានចំណុចវិវាទនៃរឿងក្តីបាន ហើយតុលាការបានរៀបចំភស្តុតាងដែលទាក់ទង នឹងចំណុចវិវាទនោះបាន នោះដំណើរការនៃការទាញហេតុផលដោយ

ផ្ទាល់មាត់ នឹងមានភាពឆាប់រហ័ស ដំណើរការមានភាពងាយស្រួល ការដោះស្រាយរឿងក្តីមានគោល អាចផ្តល់យុត្តិធម៌ជូនភាគីបាន និងមិនកកស្ទះសំណុំរឿងនៅក្នុងតុលាការ។

សរុបសេចក្តីមក នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដែលយើងខ្ញុំបានលើកមកបកស្រាយ នេះពិតជាមានសារៈសំខាន់ណាស់ ។ យើងខ្ញុំសង្ឃឹមថាការបកស្រាយនេះ និងបានជួយជាជំនួយស្មារតីនៅពេលបានជួបបញ្ហានៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងអាចជាពន្លឺបំភ្លឺដល់អ្នកសិក្សាគ្រប់រូបដើម្បីបំពេញនៅចំណុចខ្វះខាតនៅក្នុងនីតិនេះជាក់ជាពុំខាន ។

# អនុសាសន៍

# អនុសាសន៍

តាមរយៈការសិក្សាស្រាវជ្រាវកន្លងមក បានឱ្យយើងសង្កេតឃើញថា បច្ចុប្បន្ននេះនៅក្នុងប្រទេសកម្ពុជាយើង ការរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ នៅមិនទាន់បានយល់ដឹងផ្នែកច្បាប់ ក៏ដូចជានីតិវិធីច្បាប់ឱ្យបានទូលំទូលាយនៅឡើយទេ។ ជម្លោះនៅក្នុងរឿងក្ដីរដ្ឋប្បវេណីកើតមានច្រើនជាបន្តបន្ទាប់ ទាំងរឿងអង្គសេចក្ដី រឿងក្ដីរក្សាការពារ ក៏ដូចជារឿងក្ដីអនុវត្តដោយបង្ខំជាអាទិ៍។ ថ្វីត្បិតតែច្បាប់បានបង្កើតឡើងក៏ពិតមែន តែប្រជាពលរដ្ឋនៅមិនទាន់បានជ្រួតជ្រាបអំពីច្បាប់នោះ ច្បាប់ក៏នៅមិនទាន់អាចធានាបាននូវសន្តិសុខសង្គម ដែលជាហេតុធ្វើឱ្យកើតមានជម្លោះនៅក្នុងរឿងក្ដីរដ្ឋប្បវេណី។

នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីបានចែងច្បាស់អំពីដំណាក់កាល និងចំណុចត្រូវអនុវត្តន៍គ្រប់ដំណាក់កាលនៃនីតិវិធី។ ថ្វីត្បិតតែនៅក្នុងទ្រឹស្ដីនៃក្រមមិនមានជួបបញ្ហា ប៉ុន្តែការអនុវត្តជាក់ស្ដែង តែងតែជួបនូវបញ្ហាមួយចំនួនដែលក្នុងនាមយើងជាងនិស្សិត យល់ឃើញថាគួរមានការកែលំអ ដើម្បីរក្សាជំនឿទុកចិត្តពីសាធារណៈជន ពិសេសមានប្រសិទ្ធិភាពខ្ពស់នូវក្នុងការដោះស្រាយបញ្ហារឿងក្ដីដែលសាធារណៈជនបានកំពុងតែជួបប្រទះ និងដើម្បីជួយសម្រួលដល់ការដោះស្រាយ និងជម្រះក្ដីរបស់តុលាការឱ្យកាន់តែឆាប់រហ័ស និងដោយយុត្តិធម៌។ ប្រព័ន្ធតុលាការក៏ដូចជាភាគី គប្បីមានការចូលរួមដោះស្រាយបញ្ហាដែលមានកើតមានឡើងដូចជា៖

- តុលាការ និងភាគីគប្បីអនុវត្តនីតិវិធីតុលាការឱ្យបានត្រឹមត្រូវនៅក្នុងការអនុវត្តនីតិវិធី តុលាការត្រូវដឹកនាំចាត់ចែងនីតិវិធីឱ្យមានប្រសិទ្ធភាព ដោយប្រើប្រាស់នូវ ចំណេះដឹង និងបទពិសោធន៍របស់ខ្លួន។

- តុលាការ គប្បីបញ្ចេញ អាកប្បកិរយា និងពាក្យសម្ដីឱ្យសមរម្យទៅកាន់គូភាគី ទាំងភាគីដើមចោទ និងភាគីចុងចម្លើយ ព្រមទាំងបុគ្គលដែលពាក់ព័ន្ធផងដែរ ដោយហេតុថានៅក្នុងពេលធ្វើនីតិវិធី ប្រសិនបើ តុលាការបង្ហាញនូវអាកប្បកិរិយាមិនសមរម្យទៅកាន់ភាគីណាមួយ ភាគីនោះនឹងយល់ថា តុលាការមានការលម្អៀងទៅកាន់ភាគីម្ខាងទៀត ពិសេសភាគីដែលយល់ថា ខ្លួននឹងចាញ់ក្ដី ហើយមានចេតនាទុច្ចរិតអូនបន្លាយពេលវេលា និងយកបញ្ហានេះមកធ្វើជាកម្មវត្ថុប្ដឹងមកតុលាការ បើទោះបីជាតុលាការបានអនុវត្តនីតិវិធីត្រឹមត្រូវក៏ដោយ។

- តុលាការ និងភាគី គប្បីសហការគ្នា និងមានចំណាត់ការទៅលើរឿងក្ដីឱ្យបានឆាប់រហ័ស និងដោយយុត្តិធម៌ ដើម្បីកុំឱ្យមានការកកស្ទះសំណុំរឿង និងអាចឱ្យតុលាការមានពេលវេលាគ្រប់គ្រាន់សម្រាប់រឿងក្ដីផ្សេងទៀត។

- ការជម្រះក្ដីត្រូវធានាឱ្យបានច្បាស់ថា ធ្វើឡើងដោយគោរពតាមគោលការណ៍ចំពោះមុខ ដើម្បីធានាឱ្យបាននូវ តម្លាភាព និងទំនុកចិត្តពីសាធារណជន។

# ឯកសារយោង

# ឯកសារយោង


១. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើប្រើប្រាស់ជាផ្លូវការដោយព្រះរាជក្រម ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣។

២. ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

៣. សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី ដែលរៀបចំដោយក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី និងគណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីរបស់ក្រសួងយុត្តិធម៌ ឆ្នាំ២០០៧។

៤. សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគទី១ ស្តីពីនីតិវិធីបណ្តឹង ដែលរៀបចំដោយក្រុមការងារជប៉ុនដែលទទួលបន្ទុកធញវើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី និងក្រសួងយុត្តិធម៌ ឆ្នាំ២០០៨។

៥. ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤។

៦. អនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងឆ្នាំ ២០១៦។

៧. សៀវភៅមេរៀនស្តីពី នីតិវីធីជម្រះក្តីលើកទី១ របស់លោកមេធាវី អ៊ីវ ប៉ូលី ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០២១។

៨. សៀវភៅស្តីអំពី នីតិវិធីរដ្ឋប្បវេណី រៀបរៀងដោយសាស្ត្រាចារ្យ ហ៊ឺ សោភា។

៩. សៀវភៅស្តីអំពី នីតិវិធីជម្រះក្តីលើកទី១ របស់លោកមេធាវី ប៉ោយ ហ៊ុយ ឆ្នាំ២០១៩។

១០.វចនានុក្រមសម្តេចសង្ឃរាជ ជួន ណាត។

១១. គម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ ក្រសួងយុត្តិធម៌ រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ គណមេធាវីនៃព្រះរាជណាចក្រកម្ពុជា សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ឆ្នាំ២០១៥, *មេរៀនក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១,* ភ្នំពេញ។

១២.គម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ ក្រសួងយុត្តិធម៌ រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ គណមេធាវីនៃព្រះរាជណាចក្រកម្ពុជា សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ឆ្នាំ២០១៥, *មេរៀនក្រមរដ្ឋប្បវេណី និងក្រមនីតិវីធីរដ្ឋប្បវេណី ភាគ២,* ភ្នំពេញ។

# ឧបសម្ព័ន្ធ

# <u>**បញ្ជីឧបសម្ព័ន្ធ**</u>

- ឧបសម្ព័ន្ធទី១៖ លិខិតប្រគល់សិទ្ធិជូនមេធាវីតំណាងដោយអាណត្តិ
- ឧបសម្ព័ន្ធទី២៖ លិខិតអញ្ជើញមេធាវី និងដីកាកោះហៅភាគីរបស់តុលាការ
- ឧបសម្ព័ន្ធទី៣៖ របាយការណ៍អំពីការបញ្ជូនរបស់តុលាការ
- ឧបសម្ព័ន្ធទី៤៖ ពាក្យសុំលើកពេលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល
- ឧបសម្ព័ន្ធទី៥៖ ពាក្យសុំបញ្ចូលភស្តុតាង និងសាក្សី
- ឧបសម្ព័ន្ធទី៦៖ កំណត់ហេតុសះជា
- ឧបសម្ព័ន្ធទី៧៖ កំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

# ឧបសម្ព័ន្ធ១

## លិខិតប្រគល់សិទ្ធិជូនមេធាវីតំណាងដោយអាណត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## លិខិតប្រគល់សិទ្ធិជូនមេធាវីតំណាងដោយអាណត្តិ

យើងខ្ញុំឈ្មោះ .............. ភេទប្រុស ថ្ងៃខែឆ្នាំកំណើត៖......កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខៈ...... និងឈ្មោះ ........ភេទស្រី ថ្ងៃខែឆ្នាំកំណើត៖ .......... ទីលំនៅបច្ចុប្បន្នស្ថិតនៅ............។ ខេត្តពោធិ៍សាត់។

**សូមប្រគល់សិទ្ធិជូន**

លោកមេធាវី ........... អត្តលេខ ១៨៣៨ និងមេធាវី ..........................អត្តលេខ.............. ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងជាមេធាវីនៅ .................. មានអាសយដ្ឋាននៅ ............................. ដើម្បីធ្វើជាមេធាវីតំណាងដោយអាណត្តិឱ្យយើងខ្ញុំពាក់ព័ន្ធនឹង ..............................................

នៅក្នុងការប្រគល់សិទ្ធិតំណាងដោយអាណត្តិនេះ លោកមេធាវីមានសិទ្ធិដូចខាងក្រោម៖

- មានសិទ្ធិអំណាចពេញលេញក្នុងការធ្វើសកម្មភាពតំណាងដោយអាណត្តិឱ្យយើងខ្ញុំ ក្នុងដំណើរការបណ្តឹង ឬការសម្របសម្រួលចរចាដោះស្រាយជាមួយនឹងភាគីពាក់ព័ន្ធ ។
- មានសិទ្ធិក្នុងការដាក់លិខិតបំភ្លឺ ឬបកស្រាយ លិខិតអន្តរាគមន៍ និងលិខិតនានាផ្សេងទៀត ឬធ្វើការសម្របសម្រួលក្នុងនាមយើងខ្ញុំ ជាមួយភាគីពាក់ព័ន្ធ និងអាជ្ញាធរមានសមត្ថកិច្ច ។
- ការដាក់ពាក្យបណ្តឹង ការធ្វើបណ្តឹងតប ការដកបណ្តឹង ការកែប្រែបណ្តឹង ការបន្ថែមកម្មវត្ថុបណ្តឹង ការផ្សះផ្សារ ការសម្របសម្រួល ឬការទទួលស្គាល់ការទាមទារ ឬការដកខ្លួនចេញពីបណ្តឹង ដែលខ្លួនចូលអន្តរាគមន៍ ឬ ទទួលបណ្តឹង។
- ដាក់ពាក្យសុំរក្សាការពារ កែប្រែពាក្យសុំរក្សាការពារ ការបន្ថែមកម្មវត្ថុក្នុងពាក្យសុំរក្សាការពារ ការដាក់ពាក្យសុំអនុវត្តដីការក្សាការពារ។
- មានសិទ្ធិជ្រើសតាំងអនុតំណាង ដើម្បីជួយ និងសហការក្នុងការងារទាំងឡាយដែលការពារ និងផ្តល់ប្រយោជន៍ដល់រូបខ្ញុំ។

រាល់សោហ៊ុយចំណាយលើការបង់ពន្ធផ្សេងៗ និងការចំណាយលើសេវានានាពាក់ព័ន្ធនឹងសំណុំរឿងខាងលើ ជាបន្ទុករបស់ខ្ញុំ។ក្នុងករណីមិនបានគោរពតាមកាតព្វកិច្ច យើងខ្ញុំសុខចិត្តទទួលខុសត្រូវរាល់ការបាត់បង់ផលប្រយោជន៍ដោយខ្លួនឯង។

លិខិតនេះ មានសុពលភាពអនុវត្តចាប់ពីកាលបរិច្ឆេទផ្តិតមេដៃនេះតទៅ រហូតដល់មានការសម្រេចថ្មី ។

រាជធានីភ្នំពេញ, ថ្ងៃទី....... ខែ........... ឆ្នាំ២០២៣

**ស្នាមមេដៃស្តាំអ្នកប្រគល់សិទ្ធិ**

បានឃើញ និងយល់ព្រម
ធ្វើជាមេធាវីតំណាងដោយអាណត្តិឱ្យឈ្មោះ .... និងឈ្មោះ .....
ថ្ងៃ............... ខែ............... ឆ្នាំ......... ចត្វាស័ក ពុទ្ធស័ករាជ២៥៦៦
ត្រូវនឹងថ្ងៃទី...... ខែ............ ឆ្នាំ២០២៣

**ហត្ថលេខា និងត្រា**

# ឧបសម្ព័ន្ធទី ២

## លិខិតអញ្ជើញមេធាវី

## និង

## ដីកាកោះហៅភាគី

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងរាជធានីភ្នំពេញ**

សំណុំរឿងរដ្ឋប្បវេណី
លេខ :
ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៧

# លិខិតអញ្ជើញ

យើង ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ។

អញ្ជើញលោក ជាមេធាវីតំណាងដោយអាណត្តិឲ្យឈ្មោះ ។

មានការិយាល័យស្ថិតនៅផ្ទះលេខ២៧ ផ្លូវលេខ១០០៧ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

ឲ្យចូលទៅកាន់សាលាដំបូងរាជធានីភ្នំពេញ **បន្ទប់ "ព"** (ជាន់ទី៤) ។

នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៧ វេលាម៉ោង ៨:៣០ នាទី ព្រឹក។

ដើម្បីៈ ចូលរួមនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ។

ពីដំណើររឿងៈ ប្តឹងសុំទាមទារប្រាក់។

សាមីខ្លួនត្រូវអញ្ជើញតាមដីកាកោះនេះឲ្យបានទាន់ពេលវេលា និងយកលិខិតផ្សេងៗ ដែលទាក់ទងរឿងខាងលើមកជាមួយផង ប្រសិនបើមាន ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី 17 ខែកក្កដា ឆ្នាំ២០១៧

ចៅក្រម

17/07/17

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**

សំណុំរឿងរដ្ឋប្បវេណី
លេខ :
ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៧

# ដីកាកោះ

យើង ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ។

អញ្ជើញឈ្មោះ ៖ ៖ ភេទប្រុស ជាភាគីដើមចោទ។

មានទីលំនៅសព្វថ្ងៃភូមិប្រការ សង្កាត់ព្រៃស ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

ឲ្យចូលទៅកាន់សាលាដំបូងរាជធានីភ្នំពេញ **បន្ទប់ "ព"** (ជាន់ទី៤) ។

នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៧ វេលាម៉ោង ៨:៣០ នាទី ព្រឹក។

ដើម្បី: ចូលរួមនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ។

ពីដំណើររឿង: ប្តឹងសុំទាមទារប្រាក់។

សាមីខ្លួនត្រូវអញ្ជើញតាមដីកាកោះនេះឲ្យបានទាន់ពេលវេលា និងយកលិខិតផ្សេងៗ ដែលទាក់ទងរឿងខាងលើមកជាមួយផង ប្រសិនបើមាន ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី.13. ខែកក្កដា ឆ្នាំ២០១៧

**ចៅក្រម**

13/07/17

# ឧបសម្ព័ន្ធទី ៣

## របាយការណ៍អំពីការបញ្ជូន

សាលាដំបូងខេត្តកណ្ដាល

## របាយការណ៍ពីការបញ្ជូន

ប្រអប់ខាងក្រោមត្រូវបំពេញដោយក្រឡាបញ្ជី

| |
|---|
| កាលបរិច្ឆេទផ្ញើចេញ: ថ្ងៃទី ..... ខែ មករា ឆ្នាំ ២០២១<br>សំណុំរឿងរដ្ឋប្បវេណី លេខ: ១៦៣ ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០២០<br>ឈ្មោះឯកសារដែលត្រូវបញ្ជូន: សេចក្ដីប្រកាសស្ដីពី ការបញ្ជូន<br><br>ឈ្មោះអ្នកទទួលបន្ទុកកិច្ចការបញ្ជូន: លោកស្រី សិត សុនី<br>អាសយដ្ឋានអ្នកទទួលបន្ទុកកិច្ចការបញ្ជូន: សាលាដំបូងខេត្តកណ្ដាល<br>ឈ្មោះជនដែលត្រូវទទួលការបញ្ជូន: លោក មេឃុំយាង ស្រុក ពួក ខេត្ត សៀមរាប (ដើម្បីបិទផ្សាយ) |

ហត្ថលេខា ឬស្នាមមេដៃអ្នកទទួលឯកសារជាក់ស្ដែង: ..........................................................................................

ប្រអប់ខាងក្រោមនេះត្រូវបំពេញដោយអ្នកប្រតិបត្តិការបញ្ជូន (កត្តាប្រៃសណីយ៍ អាជ្ញាសាលា ឬក្រឡាបញ្ជី)

| | |
|---|---|
| ទីកន្លែងដែលបានធ្វើការបញ្ជូន: ........................................................................................................................ | |
| ការបរិច្ឆេទនៃការបញ្ជូន: ថ្ងៃទី.................... ខែ..................... ឆ្នាំ..................... វេលាម៉ោង ..................... ព្រឹក-រសៀល | |
| **វិធីជាក់ស្ដែងក្នុងការបញ្ជូន** | |
| ☐ ១ | បានប្រគល់ជូនជនដែលត្រូវទទួលការបញ្ជូនដោយផ្ទាល់ដៃ |
| | ☐ ខ្ញុំបាទពន្យល់ជូនជនដែលត្រូវទទួលការបញ្ជូន នូវខ្លឹមសារសង្ខេបនៃឯកសារដែលបានបញ្ជូន ពីព្រោះជននោះមិនចេះអានអក្សរ ។ |
| ☐ ២ | បានប្រគល់ឯកសារទៅអ្នកដែលមានការយល់ដឹងសមរម្យចំពោះការទទួលឯកសារនេះ ពីព្រោះខ្ញុំមិនបានជួបអ្នកដែល ត្រូវទទួលការបញ្ជូនដោយផ្ទាល់នៅទីកន្លែងដែលត្រូវបញ្ជូននោះទេ ។ |
| | ☐ អ្នកបម្រើ ☐ អ្នកផ្សេងដែលធ្វើការនៅទីនោះ ☐ អ្នកនៅជាមួយ |
| | ឈ្មោះ: ........................................................................................................................ |
| ☐ ៣ | ឯកសារត្រូវបានទុកនៅឯទីកន្លែងត្រូវធ្វើការបញ្ជូន ដោយហេតុថាបុគ្គលខាងក្រោមនេះមិនព្រមទទួលការបញ្ជូនដោយគ្មានហេតុផល ។ |
| | ☐ ជនដែលត្រូវទទួលការបញ្ជូន ☐ អ្នកបម្រើ<br>☐ អ្នកនៅជាមួយ ☐ អ្នកផ្សេងដែលធ្វើការនៅទីនោះ: |
| | ឈ្មោះ: ........................................................................................................................ |
| ☐ ខ្ញុំបាទបានបញ្ជូនឯកសារតាមនីតិវិធីដូចខាងលើ | |
| ☐ ខ្ញុំមិនអាចធ្វើការបញ្ជូនឯកសារខាងលើនេះបានសម្រេចទេ ពីព្រោះនៅទីកន្លែងដែលត្រូវបញ្ជូន ខ្ញុំមិនបានជួបជនដែលទទួលការបញ្ជូន ឬជនដែលមានការយល់ដឹងសមរម្យក្នុងការទទួលឯកសារនេះ ។ | |
| កាលបរិច្ឆេទធ្វើរបាយការណ៍: ថ្ងៃទី........................... ខែ........................... ឆ្នាំ.............................. | |
| ឈ្មោះ និងហត្ថលេខារបស់អ្នកធ្វើរបាយការណ៍:........................ សិត សុនី ........................ | |

# ឧបសម្ព័ន្ធទី ៤

## ពាក្យសុំលើកពេល នីតិវិធីត្រៀមទាញហេតុផលផ្ទាល់មាត់

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**<u>ពាក្យសុំលើកពេលនីតិវិធីត្រៀមទាញហេតុផលផ្ទាល់មាត់</u>**

ខ្ញុំមេធាវី ............ អត្តលេខ........... សមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងជាមេធាវីនៅ ...................... មានអាសយដ្ឋានស្ថិតនៅ....................... ជាមេធាវីតំណាងដោយអាណត្តិឱ្យឈ្មោះ .............. ក្នុងសំណុំរឿងរដ្ឋប្បវេណីលេខៈ ...... ចុះថ្ងៃទី.....ខែ......... ឆ្នាំ....... របស់សាលាដំបូងខេត្តពោធិ៍សាត់។

**សូមគោរពជូន**

**ឯកឧត្តម ប្រធានសាលាដំបូងខេត្តពោធិ៍សាត់**

**កម្មវត្ថុៈ** ស្នើសុំលើកពេលចូលរួមនីតិវិធីត្រៀមទាញហេតុផលផ្ទាល់មាត់ នៅក្នុងសំណុំរឿងរដ្ឋប្បវេណីលេខៈ ......... ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៣ ដែលនឹងប្រព្រឹត្តទៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២៣ វេលាម៉ោងៈ០៩ ព្រឹក នៅសាលាដំបូងខេត្តពោធិ៍សាត់។

**យោងៈ**
- សំណុំរឿងរដ្ឋប្បវេណីលេខៈ ...... ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៣ របស់សាលាដំបូងខេត្តពោធិ៍សាត់។
- លិខិតអញ្ជើញមេធាវី ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៣ របស់សាលាដំបូងខេត្តមណ្ឌលគិរី។
- លិខិតប្រគល់សិទ្ធិជូនមេធាវីតំណាងដោយអាណត្តិ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៣ ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបថា នៅកាលបរិច្ឆេទ ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២៣ វេលាម៉ោង០៩ព្រឹក ខ្ញុំបាទជាប់រវល់ចូលរួមនិតិវិធីទាញហេតុផលផ្ទាល់មាត់ ក្នុងសំណុំរឿងរក្សាការពារលេខៈ ........ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២២ នៅសាលាដំបូងខេត្តមណ្ឌលគិរី ហើយមិនអាចសុំលើកពេលបាន ដែលជាហេតុមិនអាចតំណាងកូនក្តីចូលរួមនីតិវិធីត្រៀមទាញហេតុផលផ្ទាល់មាត់ នៅក្នុងសំណុំរឿងខាងលើបានទេ។ ដូចនេះ ខ្ញុំបាទស្នើសុំលើកពេលចូលរួមនីតិវិធីនីតិត្រៀមទាញហេតុផលផ្ទាល់មាត់ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២៣ វេលាម៉ោងៈ០៩ព្រឹក ទៅកាលបរិច្ឆេទនាពេលក្រោយទៀត។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមប្រធាន** មេត្តាពិនិត្យ និងអនុញ្ញាតដោយសេចក្តីអនុគ្រោះ។

សូម **ឯកឧត្តមប្រធាន** ទទួលនូវការគោរពពីខ្ញុំ៕

ថ្ងៃច័ន្ទ ២ កើត ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧

ត្រូវនឹងថ្ងៃទី១៩ ខែឧមិថុនា ឆ្នាំ២០២៣

**ហត្ថលេខា និងត្រា**

# ឧបសម្ព័ន្ធទី ៥

## ពាក្យសុំបញ្ចូលភស្តុតាង និងសាក្សី

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យសុំបញ្ចូលភស្តុតាង

ខ្ញុំឈ្មោះ ........ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ........... មានទីលំនៅបច្ចុប្បន្ននៅ ......... ជា ដើមចោទ នៅក្នុងសំណុំរឿងរដ្ឋប្បវេណីលេខៈ ........ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៣ របស់សាលាដំបូងខេត្តពោធិ៍សាត់។

**សូមគោរពជូន**

**ឯកឧត្តម ប្រធានសាលាដំបូងខេត្តពោធិ៍សាត់**

**កម្មវត្ថុ:** សុំដាក់បញ្ចូលភស្តុតាង និងសាក្សីបន្ថែម នៅក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ .... ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៣ របស់សាលាដំបូងខេត្តពោធិ៍សាត់។

**យោង:** - សំណុំរឿងរដ្ឋប្បវេណីលេខៈ ...... ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៣ របស់សាលាដំបូងខេត្តពោធិ៍សាត់។

តបតាមកម្មវត្ថុ និងយោងខាងលើ យើងខ្ញុំ សូមដាក់ជូន **ឯកឧត្តម ប្រធាន** មេត្តាពិនិត្យលើភស្តុតាង និងសាក្សីបន្ថែម នៅក្នុងសំណុំរឿងរដ្ឋប្បវេណីខាងលើ ដែលមានដូចខាងក្រោមៈ

**ក. ភស្តុតាងជារូបថតៈ**

១. ***រូបថត ចំនួន ១១ សន្លឹក (រូបថតផ្លូវ និងរូបថតដើមតាង៉ែន និងជន្លង់ម្រេច ដែលត្រូវបានរងផលប៉ះពាល់ពីការឈូសឆាយកសាងផ្លូវ)៖*** រូបថតនេះ បានថតនៅក្នុងខែកុម្ភៈ ឆ្នាំ២០២០ អំឡុងពេលដែលអាជ្ញាធរឈូសឆាយកសាងផ្លូវនៅចំពីលើទីតាំងដីរបស់យើងខ្ញុំ ដែលជាការពុះជ្រៀកដីចេញជាពីរប្លង់។ រូបថតនេះ ចង់បញ្ជាក់ជូនតុលាការថា យើងខ្ញុំ ជាសហដើមចោទ បានដាំដំណាំពេញដីទាំងពីរប្លង់ ដែលរួមទាំងដាំនៅលើដីផ្លូវ មុនពេលអាជ្ញាធរឈូសឆាយកសាងផ្លូវពុះជ្រៀកពីលើទីតាំងដី និងបែងចែកប្លង់ដីជាពីរ។ ភស្តុតាងនេះ ចង់បញ្ជាក់ជូនតុលាការផងដែរថា នៅពេលទិញដីពីសហចុងចម្លើយ គឺយើងខ្ញុំមិនបានដឹងថា ដីនោះមានពីរប្លង់ ហើយត្រូវអាជ្ញាធរកសាងផ្លូវពុះជ្រៀកពីលើទីតាំងដីនោះទេ ហើយយើងខ្ញុំបានដាំដំណាំភ្លាមៗពេញដីទាំងអស់ ក្រោយទូទាត់ប្រាក់បង់ផ្តាច់ថ្លៃលក់ទិញឱ្យទៅសហចុងចម្លើយ ហើយសហចុងចម្លើយមិនបានធ្វើសកម្មភាពរារាំង ឬហាមឃាត់យើងខ្ញុំមិនឱ្យដាំតាង៉ែននៅលើប្លង់ដីលេខ នោះទេ។ ភស្តុតាងនេះ ក៏បញ្ជាក់ជូណតុលាការផងដែរអំពីដំណាំដែលខូចខាតដោយសារការធ្វើផ្លូវ ដោយរួមមាន ដើមតាង៉ែនអាយុជិត ០៥ឆ្នាំ ប្រមាណជា ១២០ ដើម ត្រូវបានឈូសចោល (ក្នុងនោះមានប្រមាណជា ៣០ ដើម នៅលើប្លង់ក្បាលដីលេខ 1410) និងដំណាំម្រេច អាយុប្រមាណ ០៣ឆ្នាំ ឈូសឆាយខូចអស់ ៤៦០ ជន្លង់/

ដើម ហើយក៏មានដើមខ្នុរ និងដើមត្នោតមួយចំនួនទៀតផងដែរ។ ប្រសិនបើយើងខ្ញុំ បានដឹងជាមុនថា ដីមានពីរប្លង់ ហើយអាជ្ញាធរនឹងធ្វើផ្លូវពុះជ្រៀកលើដីរបស់យើងខ្ញុំបែបនេះ យើងខ្ញុំក៏នឹងមិនដាំដំណាំចំទីតាំងនៃគម្រោងធ្វើផ្លូវរបស់អាជ្ញាធរដែរ ព្រោះបានធ្វើឱ្យយើងខ្ញុំរងផលប៉ះពាល់ និងខូចខាតផលដំណាំ គិតជាប្រាក់អស់ប្រហាក់ប្រហែល ៣០ លានរៀល។

២. *"រូបថតដើមតាង៉ែននៅពេលបច្ចុប្បន្ន ចំនួន០៥ សន្លឹក"៖* រូបថតនេះ ចង់បញ្ជាក់ជូនតុលាការអំពីដំណាំតាង៉ែន ដែលបានដាំដុះនៅលើដីទាំងពីរប្លង់ គិតចាប់តាំងពីបានទិញភ្លាមៗ ហើយយើងខ្ញុំចូលកាន់កាប់ ប្រើប្រាស់ និងអាស្រ័យផលរហូតមកដល់បច្ចុប្បន្ន។ ដំណាំ "**តាង៉ែន**" ត្រូវបានដាំនៅលើដីមួយផ្នែកធំ និងដីមួយផ្នែកតូចជាប់មាត់អូរ ដាំស្រូវ និងដាំដំឡូង។ រូបថតនេះ ចង់បង្ហាញជូនតុលាការ ឱ្យបានដឹងថា រហូតមកដល់ពេលនេះ ដំណាំ"**តាង៉ែន**" មានអាយុកាលជិត ០៨ ឆ្នាំ និងបានប្រមូលផលរៀងរាល់ឆ្នាំ (ប្រហែលជា ០៥ រដូវកាលហើយ)។ ភស្តុតាងនេះ ក៏ចង់បញ្ជាក់ជូនតុលាការផងដែរ អំពីការកាន់កាប់ដោយសុចរិត និងការអាស្រ័យផលលើផលដំណាំដែលបានដាំនៅក្នុងទីតាំងប្លង់ដីលេខ15060404-1410 ទាំងមូល ដោយគ្មានឧបសគ្គ គ្មានការរារាំង ឬការហាមឃាត់ណាមួយកើតឡើងក្នុងរយៈពេលជិត ០៨ ឆ្នាំមកនេះ ពីសំណាក់សហចុងចម្លើយ។

**ខ. ភស្តុតាងជាសាក្សី ដែលសុំឱ្យតុលាការកោះហៅ៖**

៣. ឈ្មោះ ........ ជាអាជ្ញាធរថ្នាក់ភូមិប្រម៉ោយ មានទីលំនៅរស់នៅ........៖ បុគ្គលរូបនេះ ជាសាក្សីសំខាន់ ដែលអាចបញ្ជាក់ជូនតុលាការបានអំពីចេតនាសុចរិតរបស់ សហចុងចម្លើយ ដែលបានមានបំណងសហការផ្ទេរកម្មសិទ្ធិលើប្លង់ដីទាំងពីរប្លង់ មកឱ្យយើងខ្ញុំ ដោយពេលនោះ ឈ្មោះ ..... បានយកលិខិតរបស់លោកមេធាវី ..... ដែលជាលិខិត "ជូនដំណឹងស្តីអំពីការធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិដី" ឱ្យទៅសហចុងចម្លើយ ហើយសហចុងចម្លើយម្នាក់ឈ្មោះ ........... បានអានលិខិតជូនដំណឹងដោយយកចិត្តទុកដាក់ និងបានប្រគល់អត្តសញ្ញាណប័ណ្ណទាំងពីរនាក់ ឱ្យមកឈ្មោះ ......... ដើម្បីយកទៅឱ្យអាជ្ញាធរសុរិយោដី បំពេញព័ត៌មានក្នុងទម្រង់ផ្ទេរកម្មសិទ្ធិប្លង់ដីទាំងពីរប្លង់ឱ្យមកសហដើមចោទ។

អាស្រ័យដូចបានជម្រាបជូនខាងលើនេះ សូម **ឯកឧត្តមប្រធាន** មេត្តាពិនិត្យ និងសម្រេចតាមនីតិវិធីច្បាប់ជាធរមាន។

សូម **ឯកឧត្តម ប្រធាន** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីយើងខ្ញុំ ៕

ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២៣

**ស្នាមមេដៃខាងស្តាំ**

# ឧបសម្ព័ន្ធទី ៦

## កំណត់ហេតុសះជា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកោះកុង**

សំណុំរឿងរដ្ឋប្បវេណី លេខ ៣៥

ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២២

# កំណត់ហេតុស្តីពីការសះជា

*ឆ្នាំពីរពាន់ម្ភៃបី ខែវិច្ឆិកា ថ្ងៃទីម្ភៃមួយ វេលាម៉ោង ប្រាំបួន និង សូន្យ នាទី ព្រឹក*

យើង **ឡេា ត្រឹម** ចៅក្រមនៃសាលាដំបូងខេត្តកោះកុង អមដោយលោក **លក ឧត្តម** ជាក្រឡាបញ្ជីនៃសាលាដំបូងខេត្តកោះកុង។

**ដើមចោទ៖** ឈ្មោះ [redacted] ភេទស្រី កើតថ្ងៃទី២០ ខែតុលា ឆ្នាំ១៩៧៧ ជនជាតិខ្មែរ អាសយដ្ឋានបច្ចុប្បន្ន ភូមិចាំយាម ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង។

**ចុងចម្លើយ៖** ឈ្មោះ [redacted] ៖ ភេទប្រុស កើតថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៦០ ជនជាតិខ្មែរ អាសយដ្ឋានបច្ចុប្បន្ន ភូមិចាំយាម ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង។

**ក-ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ**

បង្គាប់ឲ្យចុងចម្លើយធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិអចលនវត្ថុ មានក្បាលដីលេខ ១០ លេខ ១២ និងលេខ ២០ ស្ថិតនៅក្នុងភូមិចាំយាម ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង [redacted] ឈ្មោះ [redacted] ផ្អែកលើកិច្ចសន្យាទិញលក់ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៨។

**ខ-អង្គហេតុចាំបាច់ដើម្បីបញ្ជាក់ការទាមទារ៖**

**១-អង្គហេតុ**

កាលពីថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៨ ដើមចោទឈ្មោះ [redacted] ជាភាគីអ្នកទិញ បានចុះកិច្ចសន្យាទិញដីឡូតិ៍ ៣(បី)ឡូតិ៍ ស្ថិតនៅភូមិចាំយាម ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង ពីចុងចម្លើយឈ្មោះ [redacted] ជាភាគីអ្នកលក់ ក្នុងតម្លៃសរុប ៧៦.០០០ (ប្រាំពីរម៉ឺនប្រាំមួយពាន់) ដុល្លារអាម៉េរិក ហើយដើមចោទ បានធ្វើការកក់ប្រាក់ចំនួន ៥.០០០ (ប្រាំពាន់) ដុល្លារអាម៉េរិក ឲ្យទៅចុងចម្លើយ នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៨ ដើម្បីឲ្យចុងចម្លើយធ្វើនីតិវិធីរត់ការផ្ទេរប័ណ្ណកម្មសិទ្ធិពីឈ្មោះចុងចម្លើយទៅឲ្យដើមចោទ ដោយរាល់ការចំណាយលើការផ្ទេរប័ណ្ណកម្មសិទ្ធិនេះជាកាតព្វកិច្ចរបស់អ្នកលក់។ លុះពេលដើមចោទ បានកក់ប្រាក់ចំនួន ៥.០០០ (ប្រាំពាន់) ដុល្លារអាម៉េរិក ឲ្យទៅចុងចម្លើយ នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៨ រួចហើយ បែរជាចុងចម្លើយមិនព្រមផ្ទេរប័ណ្ណកម្មសិទ្ធិពីឈ្មោះចុងចម្លើយមកឲ្យដើមចោទឡើយ។

[redacted]

# ឧបសម្ព័ន្ធទី ៧

## កំណត់ហេតុស្តីពី នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្ដាល

## កំណត់ហេតុស្ដីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

រឿងក្ដី ៖ ប្ដឹងសុំរំលាយកិច្ចសន្យាទិញ-លក់ដីនិងផ្ទះ ។
សំណុំរឿងលេខ៖ ១០០៤ ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០១៧ ។
ទីកន្លែង ៖ សាលាដំបូងខេត្តកណ្ដាល ថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០២០
វេលាម៉ោង ប្រាំបួន សាមសិបនាទី ៩,០០ព្រឹក បានធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដូចតទៅ:

ចៅក្រម៖ លោក ចៅក្រមសាលាដំបូងខេត្តកណ្ដាល
ក្រឡាបញ្ជី ៖ លោកស្រី ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្ដាល

ភាគីដែលបង្ហាញខ្លួនជាអាទិ៍ ៖

-ដើមចោទឈ្មោះ ភេទប្រុស អាយុ៦៦ឆ្នាំ និងប្រពន្ធឈ្មោះ អាយុ ៦៦ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នភូមិតាក្ដុលត្បូង សង្កាត់តាក្ដុល ក្រុងតាខ្មៅ ខេត្តកណ្ដាល ។

មានតំណាងដោយអាណត្តិ៖ គ្មាន

-ចុងចម្លើយឈ្មោះ តេង សុត្ថា ភេទប្រុស អាយុ៣៥ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នភូមិផ្ទះលេខ១៦ ផ្លូវ២ ភូមិតាខ្មៅ១ សង្កាត់ តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល ។

-មានតំណាងដោយអាណត្តិ៖ លោក ជាមេធាវី អត្តលេខ: ១៥៨៣
-មានតំណាងដោយអាណត្តិ៖ លោក ជាមេធាវី អត្តលេ: ៥៦០
-មានតំណាងដោយអាណត្តិ៖លោក ជាមេធាវី អត្តលេខ: ២១៨៦T(កម្មសិក្សា)

-ដើមចោទឈ្មោ បានធ្វើសេចក្ដីថ្លែងការណ៍ថា ៖ ខ្ញុំបាទសូមរក្សាខ្លឹមសារដូចមានក្នុងពាក្យបណ្ដឹងចុះថ្ងៃទី១៣ ខែវិច្ឆិកាឆ្នាំ២០២០ទុកជាបានការដដែល ។ ខ្ញុំបាទសូមបញ្ជាក់បន្ថែមថា នៅថ្ងៃដែលខ្ញុំបាទបានចុះកិច្ចសន្យាទិញ-លក់ដីនិងផ្ទះរហូតមកដល់អំឡុងដើមខែមិថុនា ឆ្នាំ ២០១៩ ខ្ញុំបាទបានទទួលប្រាក់កក់សរុបចំនួន៤លើកដែលមានទឹកប្រាក់ចំនួនសរុប ៧៥០០០$ (ប្រាំពីរម៉ឺនប្រាំពាន់ដុល្លារអាមេរិក )

-ក្នុងការប្រគល់ប្រាក់ខាងលើ ពេលខ្លះខ្ញុំបាទបានទទួលប្រាក់តាមរយៈផ្ទាល់ដៃមិនបានសរសេរជាលាយលក្ខណ៍អក្សរទេ និងពេលខ្លះខ្ញុំបាទទទួលដោយមានឯកសារទទួលនិងប្រគល់ត្រឹមត្រូវ ។

-មូលហេតុបានជាខ្ញុំបាទបានទទួលប្រាក់ខាងលើ ពីចុងចម្លើយមិនតាមកាលបរិច្ឆេទកំណត់ដូចក្នុងកិច្ចសន្យាទិញ-លក់ដីនិងផ្ទះ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៩ ត្រង់ចំណុចប្រកា ៤ ដែលភាគីចុង

ចម្លើយត្រូវបង់ប្រាក់ថ្លៃលក់ដីនិងផ្ទះ ដែលនៅសល់ចំនួនបង្គ្រប់ គឺដោយសារតែភាគីចុងចម្លើយបានអះអាងថាគាត់ពុំមានលទ្ធភាពនិងហើយគាត់សំណូមពរអោយខ្ញុំបាទ ផ្ទេកម្មសិទ្ធិអោយទៅភាគីចុងចម្លើយ ដើម្បីគាត់យកទៅដាក់បញ្ចាំនៅធនាគារ ដើម្បីយកប្រាក់មកបង់បង្គ្រប់អោយថ្លៃទិញដីនិងផ្ទះ ដោយមានធ្វើកិច្ចសន្យាខ្ចីប័ត្រកម្មសិទ្ធិ (ដី-ផ្ទះ )ចុះថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ២០១៩ ។

-នៅថ្ងៃទី១៣ ខែ មិថុនាឆ្នាំ ២០១៩ ជាថ្ងៃចុះកិច្ចសន្យាខ្ចីប័ត្រកម្មសិទ្ធិ (ដី-ផ្ទះ )ដែលចុងចម្លើយបានប្រគល់មូលប្បទានបត្រដែលមានលេខ៣៣៥៧១២មានទឹកប្រាក់ចំនួន៥០០០០$(ប្រាំម៉ឺនដុល្លារអាមេរិក )សំរាប់ឲ្យខ្ញុំបាទបើកប្រាក់នៅថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ២០១៩ នៅធនាគារវឌ្ឍនៈអាស៊ីចំកាត់។លុះដល់ពេលកំណត់ខ្ញុំបាទទៅបើកប្រាក់ខាងធនាគារបានបញ្ជាក់ប្រាប់ខ្ញុំថា ពុំមានសាច់ប្រាក់ទេ បន្ទាប់មកទៀតខ្ញុំបាទបានព្យាយាមទាក់ទងទៅគាត់តែទាក់ទងមិនបានរហូតមកដល់ពេលនេះ ។

-សេចក្តីថ្លែងការណ៍លោក **ខៀវ ចាន់** និងលោក **ម៉ែន លន់** ជាមេធាវី តំណាងដោយអាណត្តិឲ្យចុងចម្លើយថាភាគីខាងយើងខ្ញុំសុំប្រានចោលទាំងស្រុងរបស់ដើមចោទដូចមាននៅក្នុងពាក្យបណ្តឹងដោយមូលហេតុថា:

-កូនក្តីយើងខ្ញុំពុំមានចេតនាក្នុងការគេចវេសក្នុងការទទួលខុសត្រូវអនុវត្តកាតព្វកិច្ចក្នុងកិច្ចសន្យានោះទេ ជាក់ស្តែងរហូតមកដល់ពេលនេះកូនក្តីយើងខ្ញុំបានបង់ជូនទៅភាគីដើមបណ្តឹងចំនួនទៅ៤ដង ដែលមានទឹកប្រាក់ស្មើនឹង៧៥០០០$ (ប្រាំពីរម៉ឺនប្រាំ ពាន់ដុល្លារអាមេរិក )រួចហើយ ការខកខានមិនបានបង់ប្រាក់តាមកាលបរិច្ឆេទតាមកិច្ចសន្យាកន្លងមកដោយសារបញ្ហាសេដ្ឋកិច្ចធ្លាក់ចុះជំងឺរាតត្បាតកូវីដ១៩ ដោយដាក់លក់ផ្ទះមួយកន្លែងអាជីវកម្មផ្សេងៗមិនដំណើរការ។ ចំពោះការទំនាក់ទំនងមិនបានគឺមិនត្រឹមត្រូវទេ ដោយហេតុថា កូនក្តីយើងខ្ញុំមានលំនៅដ្ឋាននៅជិតផ្ទះដើមបណ្តឹងអ្នកភូមិជាមួយគ្នាលើសពីនេះ ដើមបណ្តឹងបានដាក់ពាក្យបណ្តឹងពីរឿងព្រហ្មទណ្ឌមកសាលាដំបូងខេត្តកណ្តាលទាក់ទងទៅនឹងសែកអត់លុយកាលពីខែកញ្ញាឆ្នាំ២០២០កន្លងទៅ ។

<u>សំណូមពរ៖</u>

១-អនុញ្ញាតិឲ្យបញ្ចប់កិច្ចសន្យាទិញ-លក់ដីនិងផ្ទះ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៩ លុះត្រាតែភាគីដើមបណ្តឹងផ្ទេប្បវេណីបង្វិលប្រាក់កក់សរុបចំនួន៧៥០០០$(ប្រាំពីរម៉ឺនប្រាំពាន់ដុល្លារអាមេរិក) មកឲ្យកូនក្តីយើងខ្ញុំវិញ ។

២-សុំអនុញ្ញាតិឲ្យភាគីដើមបណ្តឹងទុកពេលវេលាឲ្យកូនក្តីយើងខ្ញុំស្វែងរកលទ្ធភាពសងដោយការលក់ផ្ទះមួយកន្លែងនៅភូមិតាក្តុល សង្កាត់តាក្តុល ក្រុងតាខ្មៅ ខេត្តកណ្តាល ។

ដើមបណ្តឹងបានធ្វើសេចក្តីថ្លែងការណ៍តបវិញថា៖ខ្ញុំពុំយល់ព្រមតាមការអះអាងរបស់លោកមេធាវីតំណាងដោយអាណត្តិចុងចម្លើយដែលបានលើឡើងថា កូនក្តីរបស់គាត់មិនបានអនុវត្តកាតព្វកិច្ចតាមកិច្ចសន្យា គឺដោយសារជំងឺកូវីដរាតត្បាត ពុំមែនជាការពិតទេ ពីព្រោះការអនុវត្តតាមកាតព្វកិច្ចនេះគឺធ្វើមុនពេលបញ្ហាជំងឺកូវីដ១៩រាតត្បាតទៀត ។

ចំណុចវិវាទ៖ សែកអត់លុយ និងមិនគោរពតាមកិច្ចសន្យាទិញ-លក់ដីនិងផ្ទះ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៩។

ចំណុចគ្មានវិវាទៈទទួលស្គាល់ប្រាក់កក់ថ្លៃទិញ-លក់ដីនិងផ្ទះ សរុបចំនួន៧៥០០០$(ប្រាំពីរម៉ឺនប្រាំពាន់ដុល្លារអាមេរិក) ។

តុលាការកំណត់ពេលឲ្យគូភាគីដាក់កស្តុតាងរយៈពេល៤សប្តាហ៍ និងកំណត់កាលបរិច្ឆេទនៅពេលក្រោយដើម្បីបន្តនីតិវិធីសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ ។

បញ្ចប់កំណត់ហេតុនៅវេលាម៉ោងដប់មួយកន្លះព្រឹក ថ្ងៃខែឆ្នាំដូចខាងលើ សរសេរចប់ យើងបានអានសេចក្តីទាំងស្រុងនៃកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល នេះ ឲ្យសាមីខ្លួនស្តាប់ ហើយឆ្លើយថាត្រឹមត្រូវ និងសុខចិត្តផ្តិតម្រាមដៃជាមួយយើង។

| | |
|---|---|
| ក្រឡាបញ្ជី | ចៅក្រម |

| | | | |
|---|---|---|---|
| ដើមចោទ | មេធាវីដើមចោទ | ចុងចម្លើយ | មេធាវីចុងចម្លើយ |